វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*The NGO Forum on Cambodia*

# ការពិនិត្យលើក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ស្តីពីការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា



សិក្សាស្រាវជ្រាវដោយៈ លោក អ៊ូ ស៊ីវហួច និងលោក បណ្ឌិត សុក សាយ

រាជធានីភ្នំពេញ

ខែឧសភា ឆ្នាំ២០១៩

**ការពិនិត្យលើក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណជនក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា**

កាលបរិច្ឆេទបោះពុម្ព៖ ខែឧសភា ឆ្នាំ២០១៩
បោះពុម្ពផ្សាយដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
កម្មវិធីគោលនយោបាយអភិវឌ្ឍន៍ជាតិ
គម្រោងថវិកាជាតិ

សិក្សាស្រាវជ្រាវដោយ៖ លោក អ៊ូ ស៊ីវហួច និង លោកបណ្ឌិត សុក សាយ អ្នកពិគ្រោះការ
រចនាដោយ៖ លោក ភួន យូ អ្នកសម្របសម្រួលសារព័ត៌មាន និងទំនាក់ទំនង

ការបដិសេធការទទួលខុសត្រូវ៖ ទស្សនៈដែលបង្ហាញក្នុងរបាយការណ៍នេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ឬ ប្រភពដែលបានដកស្រង់ និងមិនតំណាងឲ្យទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជានោះទេ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ខែឧសភា ឆ្នាំ២០១៩**

# មាតិកា


សេចក្តីថ្លែងអំណរគុណ....................................................................................................ii

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ....................................................................................iii

សេចក្តីសង្ខេប....................................................................................................................v

ជំពូកទី ១: សេចក្តីផ្តើម.................................................................................................... 1

១.១ មូលហេតុសម្រាប់ការសិក្សា..................................................................................... 1

១.២ គោលបំណងនៃការសិក្សា........................................................................................ 1

១.៣ វិធីសាស្ត្រស្រាវជ្រាវ ................................................................................................... 2

១.៤ ទស្សនទាន "ការចូលរួម" ........................................................................................... 3

១.៥ កង្វះខាតនៃការសិក្សា................................................................................................ 5

១.៦ ទិដ្ឋភាពទូទៅនៃសមិទ្ធិផលកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការចូលរួមដោយការ" អញ្ជើញ" នៅប្រទេសកម្ពុជា ............................................................................................ 7

១.៧ គម្រោងនៃរបាយការណ៍ស្រាវជ្រាវ............................................................................ 10

ជំពូកទី ២: ក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណជននៅប្រទេសកម្ពុជា... 11

២.១ ថ្នាក់ជាតិ.............................................................................................................. 15

២.១ ថ្នាក់ក្រោមជាតិ .................................................................................................... 19

ជំពូកទី៣: បទពិសោធន៍ល្អៗអំពីការចូលរួមជាសាធារណៈក្នុងការគ្រប់ គ្រងហិរញ្ញវត្ថុសាធារណៈនិងដំណើរការថវិកាជាតិនៅប្រទេស ឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន............................................................... 25

៣.១. កំណត់ចំណាំអំពីការប្រៀបធៀបរវាងប្រទេសទាំងពីរនិងប្រទេសកម្ពុជា................................ 25

៣ ២. លទ្ធផលនៃការស្ទង់មតិ.OBS អំពីការចូលរួមជាសាធារណៈ នៅប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន.................................................................................................. 26

ជំពូកទី៤: សេចក្តីសន្និដ្ឋាននិងអនុសាសន៍គន្លឹះៗ.............................................................. 43

ឯកសារយោង..................................................................................................................... 50

ឧបសម្ព័ន្ធ.......................................................................................................................... 53

១.ច្បាប់និងគោលនយោបាយដែលត្រូវបានត្រួតពិនិត្យ ............................................................ 53

២. ទិដ្ឋភាពទូទៅនៃការចូលរួមរបស់សាធារណជនក្នុងការស្ទង់មតិចំហថវិកា ឬ Open Budget Survey55

៣. តារាងអ្នកដែលត្រូវបានសម្ភាសសំខាន់ៗ និងស្ថាប័នរដ្ឋដែលបានពិគ្រោះយោបល់ជាមួយ............ 61

# សេចក្ដីថ្លែងអំណរគុណ

ក្រុមអ្នកសិក្សាស្រាវជ្រាវសូមថ្លែងអំណរគុណចំពោះបុគ្គល និងស្ថាប័នខាងក្រោមដែលបានផ្ដល់ការគាំទ្រដល់ការសិក្សានេះ។ ជាដំបូង យើងខ្ញុំសូមអរគុណចំពោះថ្នាក់ដឹកនាំ និងបុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ដែលរួមមានលោកបណ្ឌិត តឹក វណ្ណារ៉ា នាយកប្រតិបត្តិ លោក អ៊ុក វណ្ណារ៉ា នាយកប្រតិបត្តិរង លោកស៊ុន យូរ៉ា ប្រធានកម្មវិធីគោលនយោបាយអភិវឌ្ឍន៍ជាតិ កញ្ញា អ៊ុច សុវណ្ណាល័យ អ្នកសម្របសម្រួលគម្រោងថវិកាជាតិ និងលោកស្រី រស់ សាអែម ជំនួយការកម្មវិធីគោលនយោបាយអភិវឌ្ឍន៍ជាតិ ដែលបានជួយគាំទ្រដំណើរការស្រាវជ្រាវនេះតាំងពីដើមរហូតដល់ចប់ និងចូលរួមផ្ដល់ធាតុចូល និងមតិយោបល់ដែលមាន សារៈប្រយោជន៍សម្រាប់ការសិក្សានេះ។

ក្រុមអ្នកស្រាវជ្រាវយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមន្ត្រីរាជរដ្ឋាភិបាលមួយចំនួន បុគ្គលិកអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ស្ថាប័នអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ដទៃទៀត និងអ្នកជំនាញផ្នែកកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានផ្ដល់ធាតុចូលបច្ចេកទេស ឯកសារ និងដំបូន្មានផ្សេងៗដែលមានប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាននៃឃុំមួយនៅក្នុងខេត្តកណ្ដាលសម្រាប់ធាតុចូល និងមតិយោបល់របស់ពួកគាត់។

លើសពីនេះទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារថវិកា (Budget Working Group) របស់ អង្គការសង្គមស៊ីវិល និងលោក Javier Castillo-Alvarez អនុព័ន្ធផ្នែកសម្រួលជំនួយបរទេសឱ្យមានប្រសិទ្ធភាព ការគាំទ្រថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់គណៈប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ចំពោះមតិយោបល់ដ៏មានសារៈប្រយោជន៍របស់ពួកគាត់ទៅលើសេចក្ដីព្រាងរបាយណ៍ការស្រាវជ្រាវនេះ។

ជាចុងក្រោយ ក្រុមអ្នកស្រាវជ្រាវយើងខ្ញុំសូមថ្លែងអំណរគុណចំពោះស្ថាប័នរដ្ឋពាក់ព័ន្ធដែលផ្ដល់ជូននូវយោបល់ផ្នែកបច្ចេកទេស និងមតិផ្សេងៗដែលសុទ្ធសឹងតែមានតម្លៃសម្រាប់ការស្រាវជ្រាវនេះ។ ស្ថាប័នទាំងនេះរួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការនៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអាជ្ញាធរសវនកម្មជាតិ។

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ABI | គំនិតផ្តួចផ្តើមឱ្យអង្គការសង្គមស៊ីវិលបានចូលរួមការងារថវិកាជាតិជាមួយស្ថាប័នរដ្ឋ |
| BPA | កិច្ចព្រមព្រៀងភាពជាដៃគូរវាងអង្គការសង្គមស៊ីវិលនិងស្ថាប័នរដ្ឋក្នុងការធ្វើការងារថវិកា |
| COA | គណៈកម្មាធិការសវនកម្ម |
| CDP | ផែនការអភិវឌ្ឍន៍ឃុំ / សង្កាត់ |
| CGAU | អង្គភាពភ្នាក់ងាររដ្ឋាភិបាលកណ្តាល |
| CIP | កម្មវិធីវិនិយោគឃុំ |
| CPA | សវនកម្មដែលមានការចូលរួមពីប្រជាពលរដ្ឋ |
| CSO | អង្គការសង្គមស៊ីវិល |
| DBM | ក្រសួងថវិកានិងការគ្រប់គ្រង |
| DIP | កម្មវិធីវិនិយោគស្រុក |
| GIFT | គំនិតផ្តួចផ្តើមសកលដើម្បីតម្លាភាពសារពើពន្ធ |
| GSPFMPRSC | អគ្គលេខាធិការនៃគណៈកម្មការគ្រប់គ្រងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GPB | ក្របខ័ណ្ឌថវិកាដែលមានការចូលរួមនៅថ្នាក់មូលដ្ឋាន |
| FMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ |
| IBP | អង្គការភាពជាដៃគូថវិកាអន្តរជាតិ |
| ICT | បច្ចេកវិទ្យាគមនាគមន៍តាមបែបព័ត៌មានវិទ្យា |
| IP3 | ផែនការអនុវត្តបីឆ្នាំរំកិល |
| LPRAT | ក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូលដ្ឋាន |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| M&E | ការតាមដាននិងវាយតម្លៃ |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| NA | រដ្ឋសភាជាតិ |
| NAA | អាជ្ញាធរសវនកម្មជាតិ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NEDA | អាជ្ញាធរជាតិសម្រាប់ការអភិវឌ្ឍ និងសេដ្ឋកិច្ច |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NP-NSDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

| | |
|---|---|
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NDPA | ភ្នាក់ងារសម្រាប់ការធ្វើផែនការអភិវឌ្ឍន៍ជាតិ |
| OBI | សន្ទស្សន៍ថវិកាបើកចំហ |
| OBS | ការស្ទង់មតិថវិកាបើកចំហ |
| PFM | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PIP | កម្មវិធីវិនិយោគខេត្ត |
| PFMRP | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFSL | ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ |
| PM | នាយករដ្ឋមន្ត្រី |
| PROCEED | គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| PTWGE | ក្រុមការងារបច្ចេកទេសថ្នាក់ខេត្តលើវិស័យអប់រំ |
| RDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍ថ្នាក់តំបន់ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RPJMN | ផែនការអភិវឌ្ឍន៍ជាតិរយៈពេលមធ្យម |
| RS | យុទ្ធសាស្ត្រចតុកោណ |
| SAB | ក្រុមប្រឹក្សាសវនកម្មរដ្ឋ |
| SAI | ស្ថាប័នសវនកម្មកំពូល |
| Sida | ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| (Sub)- TWG | (អនុ) ក្រុមការងារបច្ចេកទេស |
| UNESCO | អង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់អង្គការសហប្រជាជាតិ |

# សេចក្តីសង្ខេប

ការសិក្សានានាបានបង្ហាញថាការចូលរួមរបស់សាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) បានជួយរួមចំណែកធ្វើឱ្យរដ្ឋាភិបាលកាន់តែមានតម្លាភាពនិងគណនេយ្យភាព ការផ្តល់សេវាសាធារណៈកាន់ តែមានលក្ខណៈល្អប្រសើរឡើង និងបង្កើនទំនុកចិត្តរវាងរដ្ឋាភិបាលនិងប្រជាពលរដ្ឋ។ មកទល់ពេលនេះ ប្រទេសមួយចំនួនបានបង្កើតច្បាប់ គោលនយោបាយ និងយន្តការផ្សេងៗដើម្បីបង្ករលក្ខណៈងាយស្រួលឱ្យមានការចូលរួមពីសាធារណជន និងអង្គការសង្គមស៊ីវិលនៅក្នុងដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែប្រទេសខ្លះទៀតក៏មិនទាន់បង្កើតច្បាប់និងគោលនយោបាយឱ្យបានគ្រប់គ្រាន់ដើម្បីលើកកម្ពស់ការចូលរួមជាសាធារណៈក្នុងវិស័យហិរញ្ញវត្ថុនេះនៅឡើយ។

ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលកំណែទម្រង់មានភាពយឺតយ៉ាវ ជាពិសេសកំណែទម្រង់ដែលជំរុញឱ្យមានការចូលរួមពីសាធារណជននៅក្នុងការសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ។ ជាក់ស្តែងការស្ទង់មតិថវិកាបើកចំហ (OBS) បង្ហាញថាប្រទេសកម្ពុជាទទួលបានពិន្ទុទាបគឺ៨ នៅឆ្នាំ២០១៥ និង៤ នៅឆ្នាំ២០១៧។ ការសិក្សានេះបានរកឃើញថា នៅប្រទេសកម្ពុជាច្បាប់ និងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានបទប្បញ្ញត្តិតិចតួចណាស់ទាក់ទងនឹងការចូលរួមជាសាធារណៈជាពិសេសនៅថ្នាក់ជាតិ។ ទោះយ៉ាងណាក៏ដោយ នេះមិនមែនជាការមើលរំលងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលបានធ្វើ ដើម្បីឱ្យមានភាពប្រសើរឡើងនូវការចូលរួមជាសាធារណៈនៅថ្នាក់ក្រោមជាតិ និងឱ្យមានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលខ្លះៗនៅថ្នាក់ជាតិនោះទេ។ ភ័ស្តុតាងនានាបានបង្ហាញយ៉ាងជាក់ច្បាស់ថាមានការចូលរួមយ៉ាងសកម្មមួយចំនួនពីអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះក្របខ័ណ្ឌច្បាប់ និងគោលនយោបាយនៅថ្នាក់ក្រោមជាតិរិតតែមានលក្ខណៈអំណោយផលជាងថ្នាក់ជាតិ ក្នុងការបង្ករឱ្យមានការចូលរួមពីសាធារណជន។ ក្រៅពីប្រទេសកម្ពុជា ការសិក្សានេះក៏បានពិនិត្យការអនុវត្តល្អៗ ពីបណ្តាប្រទេសមួយចំនួនក្នុងតំបន់ទាក់ទងនឹងការចូលរួមរបស់សាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណនេះផងដែរ។ មេរៀនទាំងអស់ដែលទទួលបានពីការសិក្សាទាំងក្នុងនិងក្រៅប្រទេសអាចនឹងជួយឱ្យប្រទេសកម្ពុជាកាន់តែអាចធ្វើឱ្យកាន់តែប្រសើរឡើងនូវការចូលរួមរបស់សាធារណជនក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ។

ដើម្បីឱ្យការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានលក្ខណៈជាប្រពន្ធ័ស៊ីជំរៅនិង ទូលំទូលាយ រាជរដ្ឋាភិបាលគួរចាប់ផ្តើមពីការកែទម្រង់ក្របខ័ណ្ឌច្បាប់និងគោលនយោបាយដើម្បីលើកកម្ពស់យ៉ាងជាក់លាក់ឱ្យមានការចូលរួមពីសាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ។ ដូច្នេះការសិក្សានេះមានគោលបំណងចំបងពីរ គឺ (១) ធ្វើការវិភាគក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធនឹងការចូលរួមរបស់សាធារណជន ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលក្នុងនោះរួមមានទាំង

ដំណើរការធ្វើថវិកា និង(២) ស្វែងរកច្រកចូលជាក់លាក់ដើម្បីឱ្យមានការចូលរួមរបស់សាធារណជននៅក្នុង ដំណើរការរៀបចំផែនការ ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សំណួរពីរដែលការស្រាវជ្រាវត្រូវឆ្លើយនោះគឺៈ (១) តើក្របខ័ណ្ឌច្បាប់និងគោលនយោបាយរបស់ប្រទេសកម្ពុជា បានផ្តល់ឱកាសអ្វីខ្លះសម្រាប់ការចូលរួមពីសាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ? និង (២) តើ មានវិធីអ្វីខ្លះដែលអាចធ្វើបានដើម្បីផ្តល់ឱកាស និងសក្តានុពលឱ្យសាធារណជនចូលរួមនៅក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ?

ការស្រាវជ្រាវនេះធ្វើឡើងជាបីដំណាក់កាលៈ ដំបូងគឺការពិនិត្យក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ស្តីពីការចូលរួមជាសាធារណៈនៅប្រទេសកម្ពុជាដែលមានស្រាប់ និងការអនុវត្តនៅប្រទេសឥណ្ឌូនេស៊ី និង ប្រទេសហ្វីលីពីន។ បន្ទាប់មកគឺកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នសាធារណៈចំនួនបីដែលធ្វើការលើការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចុងក្រោយគឺសម្ភាសន៍ជាមួយអ្នកជំនាញមួយចំនួនដែលដឹងពីការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) និងអាជ្ញាធរមូលដ្ឋាននិងប្រជាពលរដ្ឋនៅឃុំមួយ។ ទស្សនទាន "ការចូលរួមដោយការអញ្ជើញ" "invited participation" ដែលបង្កើតឡើងដោយគម្រោងគំនិតផ្តួចផ្តើ មសកលដើម្បីតម្លាភាពសារពើពន្ធ (GIFT) ត្រូវបានប្រើដើម្បីធ្វើការវិភាគនៅក្នុងការសិក្សានេះ។ ខាងក្រោមនេះ គឺជាការរកឃើញសំខាន់ៗ ដែលបានមកពីការពិនិត្យក្របខ័ណ្ឌច្បាប់និងគោលនយោបាយ របស់កម្ពុជាទាក់ទង នឹងការចូលរួមរបស់សាធារណជនលើបញ្ហាថវិកា និងការបង្ហាញខ្លះៗពីករណីប្រទេសឥណ្ឌូនេស៊ី និង ប្រទេសហ្វីលីពីន។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមានមាត្រាពីរដែលចែងជាទូទៅស្តីពីការចូលរួមរបស់សាធារណ ជន ប៉ុន្តែច្បាប់កំពូលនេះមិនបានចែងទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះទេ។ ច្បាប់សំខាន់ៗ ផ្សេងទៀតដូចជាច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីសវនកម្ម មិនមានចែងអំពីការចូលរួមរបស់ សាធារណជននោះទេ ទាំងក្នុងលក្ខខណ្ឌទូទៅនិងពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ស្តង់ដារសវន កម្មសាធារណៈមានចែងជាទូទៅស្តីពីការសហការជាមួយវិទ្យាស្ថានស្រាវជ្រាវជាន់ខ្ពស់ និងទំនាក់ទំនងផ្លូវការ ជាមួយអង្គភាពវិជ្ជាជីវៈ ក្នុងដំណើរការសវនកម្ម ប៉ុន្តែមិនមានចែងពីការចូលរួមពីសំណាក់អង្គការសង្គម ស៊ីវិល និងសាធារណជនក្នុងការងារសវនកម្មសាធារណៈទេ។ ចំណែកឯកសារគោលនយោបាយសំខាន់ៗស្តីពីកំណែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏មានចែងតិចតួចស្តីពីការចូលរួមពីសំណាក់អង្គការសង្គមស៊ីវិល និង សាធារណជនដែរ។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ព្រឹទ្ធសភា និងគណៈកម្មការទី២របស់ស្ថាប័ននីតិបញ្ញត្តិទាំងពីរ មានចែងខ្លះៗស្តីពីការពិគ្រោះយោបល់ជាសាធារណៈ។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាមានចែងរហូតទៅដល់លទ្ធ ភាពផ្តល់ព័ត៌មានដល់សាធារណជន ក៏ប៉ុន្តែទាំងរដ្ឋសភានិងព្រឹទ្ធសភា នៅមិនទាន់បានបង្កើត នីតិវិធីលម្អិត និង យន្តការច្បាស់លាស់ ដើម្បីឲ្យសាធារណជនចូលរួមយ៉ាងសកម្មនិងជាប្រព័ន្ធ ជាពិសេសដើម្បីឱ្យពួកគេផ្តល់សក្ខី កម្ម ធាតុចូល និងយោបល់សំខាន់ៗលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឡើយទេ ។

ច្បាប់និងគោលនយោបាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិមានចែងច្រើនជាទូទៅអំពីការចូលរួមពីសាធារណជន ជាពិសេសទាក់ទងនឹងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន កម្មវិធីវិនិយោគ និងសំណើថវិកា និងមានលើកឡើងខ្លះៗពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការតាមដានការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ (M & E) ការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គម្រោងនិងកម្មវិធីមួយចំនួនរបស់ក្រសួងមហាផ្ទៃនិងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុវត្តដោយមានការចូលរួមពីសាធារណជន នៅក្នុងការរៀបចំកម្មវិធីវិនិយោគឃុំសង្កាត់ ការរៀបចំថវិកាឃុំសង្កាត់ប្រចាំឆ្នាំ និងការរៀបចំសំណើគម្រោងដែលផ្អែកលើសមិទ្ធកម្មការងារ។ ទោះជាយ៉ាងណាក៏ដោយ ពុំទាន់មានយន្តការណាមួយដែលអាចឱ្យសាធារណជនដឹងថាតើធាតុចូលរបស់ពួកគេត្រូវបានរាជរដ្ឋាភិបាលប្រើប្រាស់សម្រាប់ការរៀបចំថវិកា តាមដាន និងសវនកម្មដោយរបៀបណាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៅឡើយទេ។

បទពិសោធន៍ពីការចូលរួមរបស់សាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅប្រទេសឥណ្ឌូនេស៊ី និងជាពិសេសនៅប្រទេសហ្វីលីពីន អាចផ្តល់មេរៀនល្អៗមួយចំនួនសម្រាប់ប្រទេសកម្ពុជា។ ប៉ុន្តែការកត់សម្គាល់មួយចំពោះប្រទេសទាំងពីរនេះ គឺថាបើទោះបីជាពិន្ទុការចូលរួមរបស់សាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងការស្ទង់មតិ OBS របស់ប្រទេសទាំងពីរមានភាពប្រសើរជាងពិន្ទុរបស់ប្រទេសកម្ពុជាក៏ដោយ ក៏ប្រទេសទាំងពីរនេះ ជាពិសេសប្រទេសឥណ្ឌូនេស៊ី នៅមានចំណុចជាច្រើនទៀតដែលត្រូវការកែលម្អដើម្បីពង្រឹងការចូលរួមជាសាធារណៈ។ ជាបទពិសោធន៍ ប្រទេសឥណ្ឌូនេស៊ីបានធ្វើរឿងសំខាន់ៗពីរដែលធ្វើឱ្យពិន្ទុលើការចូលរួមរបស់សាធារណជននៅក្នុង OBS កើនឡើង ហើយចំនុចទាំងពីរនេះអាចជាមេរៀនល្អសម្រាប់ប្រទេសកម្ពុជា។ ទីមួយគឺការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលអនុញ្ញាតឱ្យសាធារណជនអាចទទួលបានព័ត៌មានជាសាធារណៈ ក្នុងលក្ខណៈស្របច្បាប់ និងតម្រូវឱ្យស្ថាប័នរដ្ឋនានា (ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) បញ្ចេញព័ត៌មានជាសាធារណៈ។ ទីពីរគឺប្រទេសឥណ្ឌូនេស៊ីបានប្រើប្រាស់យន្តការដែលមានស្រាប់ដើម្បីជំរុញការចូលរួមរបស់សាធារណជន (យ៉ាងហោចណាស់ក្នុងទិដ្ឋភាពបច្ចេកទេសនៃផែនការប្រចាំឆ្នាំ) នៅក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាល។ ការដាក់ឱ្យប្រើនូវ Musrengbang (វេទិកាអភិវឌ្ឍន៍) សម្រាប់គោលបំណងនេះគឺជាឧទាហរណ៍ជាក់ស្តែងមួយ។

ប្រទេសហ្វីលីពីនក៏មានមេរៀនល្អៗមួយចំនួនដែរសម្រាប់ប្រទេសកម្ពុជា។ បើទោះបីជាប្រទេសនេះមិនទាន់មាន ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានក៏ដោយ ក៏រដ្ឋធម្មនុញ្ញនិងច្បាប់ដទៃទៀតរបស់ប្រទេសនេះ បានធានាការចូលរួមជាសាធារណៈក្នុងលក្ខខណ្ឌទូទៅ។ សំខាន់ជាងនេះទៅទៀត ប្រទេសនេះបានបើកឱកាសសម្រាប់ការចូលរួមពីសាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងបានផ្តល់មតិយោបល់ត្រលប់ទៅសាធារណជន តាមរយៈការអនុម័តបទបញ្ជានីតិប្រតិបត្តិ និងការពង្រីកយន្តការដែលមានស្រាប់ដើម្បីសម្រួលឱ្យប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចចូលរួមការសម្រេចរបស់ស្ថាប័នរដ្ឋ (ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន)។ ការប្រើប្រាស់កិច្ចព្រមព្រៀងភាពជាដៃគូថវិកា (BPA) ក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូល

ដ្ឋាន (LPRATs) និងក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់ (RDCs) ក្នុងការរៀបចំថវិកាប្រចាំឆ្នាំ ការតាមដានការអនុវត្តថវិកា និងការផ្តល់មតិយោបល់ត្រលប់គឺជាឧទាហរណ៍ជាក់ស្តែង។ កិច្ចព្រមព្រៀងភាពជាដៃគូថវិកាគឺជាយន្តការដែលអនុញ្ញាតិឱ្យមានភាពជាដៃគូផ្លូវការរវាងក្រសួងនានា សាជីវកម្មរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅថ្នាក់ ជាតិ។ ចំណែកឯក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូលដ្ឋាន ត្រូវមានក្រុមភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន និងអង្គការសង្គមស៊ីវិលមូលដ្ឋានជាសមាជិក និងត្រូវមានតំណាងទាំងសងខាងជាសហប្រធាន។ ក្រសួងថវិកានិងការគ្រប់គ្រង (DBM) ដើរតួនាទីយ៉ាងសំខាន់នៅក្នុងបញ្ហានេះ ហើយការផ្តួចផ្តើមនេះត្រូវបានអនុវត្តក្នុងលក្ខណៈជាជំហានៗ (ដោយចាប់ផ្តើមជាគម្រោងសាកល្បង) និងក្រោយមកពង្រីកដល់គ្រប់ក្រសួង សាជីវកម្មរដ្ឋាភិបាល និងរដ្ឋបាលមូលដ្ឋាន។

ស្ថាប័ននីតិប្បញ្ញត្តិនិងគណៈកម្មការសវនកម្ម (COA) របស់ប្រទេសហ្វីលីពីនក៏បានបង្កើតយន្តការផ្សេងៗដើម្បីសម្រួលដល់ការចូលរួមរបស់សាធារណជននៅក្នុងការសម្រេចចិត្ត និងសកម្មភាពរបស់ស្ថាប័នពីរនេះផងដែរ។ ការសម្រួលទាំងនេះរួមមានការផ្តល់នូវឱកាសឱ្យសាធារណជន ផ្តល់សក្ខីកម្មនិងធាតុចូលក្នុងការជជែកដេញដោលនៅរដ្ឋសភានិងព្រឹទ្ធសភា ការទទួលធាតុចូលពីសាធារណជនសម្រាប់កម្មវិធី ឬ ដំណើរការសវនកម្ម ការផ្តល់របាយការណ៍សង្ខេបនៃធាតុចូលដែលទទួលបាន (ទាំងស្ថាប័ននីតិប្បញ្ញត្តិនិងគណៈកម្មការសវនកម្ម) និងការចូលរួមនៅក្នុងការស៊ើបអង្កេតសវនកម្ម។ ប្រទេសហ្វីលីពីន និងនៅក្នុងកម្រិតតិចតួចនៅប្រទេស ឥណ្ឌូនេស៊ី បានប្រើបច្ចេកវិទ្យាគមនាគមន៍តាមបែបព័ត៌មានវិទ្យា (ICT) (ដូចជាវេបសាយនិងប្រព័ន្ធផ្សព្វផ្សាយសង្គម) ដើម្បីផ្តល់ព័ត៌មានជូនសាធារណជន និងដើម្បីទទួលការចូលរួមពីសាធារណជន។

ឈរលើស្ថានភាពបច្ចុប្បន្ននៃការចូលរួមរបស់សាធារណជន និងក្របខ័ណ្ឌច្បាប់និងគោលនយោបាយរបស់ប្រទេសកម្ពុជា និងការទាញយកមេរៀនពីប្រទេសជិតខាងទាំងពីរ ការសិក្សានេះផ្តល់នូវអនុសាសន៍គន្លឹះៗមួយចំនួនដូចខាងក្រោមសម្រាប់ជាការពិចារណាដើម្បីបង្កើនការចូលរួមរបស់សាធារណជន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជា។

១. ការដែលរាជរដ្ឋាភិបាលមានបំណងធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឱ្យបានមុនឆ្នាំ ២០២០ គឺជាគំនិតផ្តួចផ្តើមនិងឱកាសដ៏ល្អនិងទាន់ពេលវេលា ហើយគួរតែមានការពិចារណាបញ្ចូលនូវការចែងអំពីការចូលរួមជាសាធារណៈ យ៉ាងហោចណាស់ក្នុងវដ្តថវិកានៅក្នុងច្បាប់ថ្មីនោះ។ ប្រទេសហ្វីលីពីន គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយ ព្រោះវាបានទទួលពិន្ទុពេញឬលើមធ្យម សម្រាប់ការចូលរួមជាសាធារណៈដោយសារច្បាប់ និងគោលនយោបាយនានារបស់ប្រទេសនេះមានបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ហើយបញ្ញត្តិទាំងនេះត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋសភា និងព្រឹទ្ធសភា គឺជាតួអង្គយ៉ាងសំខាន់នៅក្នុងការអនុវត្តគំនិតផ្តួចផ្តើមធ្វើវិសោធនកម្មច្បាប់នេះ។

២. ការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជានឹងអាចទទួលបានអត្ថប្រយោជន៍ ពីការអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធទទួលបានព័ត៌មាន ដែលកំពុងរង់ចាំចំណាត់ការបន្តនៅទីស្តីការគណៈរដ្ឋមន្ត្រី។ ជាបទពិសោធន៍ពីប្រទេសឥណ្ឌូនេស៊ី ការចូលរួមជាសាធារណៈរបស់ប្រទេសនេះ មានការប្រសើរឡើងខ្លះៗ បន្ទាប់ពីមានការចេញច្បាប់បែបនេះ។ ក្នុងន័យនេះ គណៈរដ្ឋមន្ត្រីគួរតែជំរុញដំណើរការសេចក្តីព្រាងច្បាប់ នេះបន្តទៀត និងឈានដល់ការអនុម័តនិងអនុវត្តច្បាប់នេះឱ្យបានខ្ជាប់ខ្ជួន។

៣. ខណៈដែលថាការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវការពេលវេលាច្រើននៅក្នុងដំណាក់កាលនេះ ជំហានដែលអាចធ្វើទៅបាន ដែលអាចជួយបង្កើនពិន្ទុការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជានៅក្នុងការស្ទង់មតិ OBS ក្នុងរយៈពេលខ្លីទៅមធ្យម ក៏ដូចជាដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានការចូលរួម គឺការពង្រឹងនិងពង្រីកយន្តការនានាដែលមានស្រាប់។ ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីនបានប្រើប្រាស់យន្តការស្រដៀងនេះដើម្បីបង្កើនការចូលរួមជាសាធារណៈ របស់ខ្លួន។ ខាងក្រោមនេះ គឺជាវិធានការដែលអាចហុចផលបានភ្លាមៗ។

នៅថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល មានលំហច្បាប់និងគោលនយោបាយច្រើនក្នុងការចូលរួមការរៀបចំផែនការអភិវឌ្ឍន៍ ការរៀបចំថវិកា និងក្នុងកម្រិតណាមួយ ការតាមដាននិងវាយតម្លៃ ការអនុវត្ត។ ការអនុវត្តមួយចំនួននៃច្បាប់និងគោលនយោបាយ ដែលមានការចូលរួមបែបនេះបានធ្វើឡើង នៅក្នុងឃុំនិងសង្កាត់មួយចំនួន ដែលមានគម្រោងរបស់ក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាលមួយ ចំនួន។ ឧទាហរណ៍ល្អមួយ គឺការចូលរួមពីសាធារណជនក្នុងការរៀបចំផែនការវិនិយោគឃុំ និងថវិកាឃុំ នៅតាមតំបន់មួយចំនួន។ តម្រូវការសម្រាប់ការចូលរួមជាសាធារណៈក្នុងការបង្កើតសំណើគម្រោងសម្រាប់ គម្រោងវិនិយោគថ្នាក់ក្រោមជាតិ (នៅថ្នាក់ស្រុក) គឺជាបំណងល្អមួយទៀតរបស់រាជរដ្ឋាភិបាលក្នុងការ ជម្រុញការចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ ក្នុងការគ្រប់គ្រងថវិកាសាធារណៈ តាមរយៈការប្រើ ប្រាស់មូលនិធិដែលផ្អែកលើសម្មិទ្ធិកម្មការងារ។ ការអនុវត្តល្អៗដែលមានស្រាប់អាចត្រូវបន្តអនុវត្ត និងពង្រីក ជាលំដាប់។ ទោះជាយ៉ាងណាក៏ដោយ ជាការអនុវត្តជាក់ស្តែង ដោយសារការរៀបចំផែនការវិនិយោគឃុំ និងដំណើរការរៀបចំថវិកាប្រចាំឆ្នាំត្រូវបានអនុវត្តដាច់ដោយឡែកពីគ្នាក្នុងករណីភាគច្រើន គួរមានការចេញ ប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីគោលការណ៍ណែនាំនិងនីតិវិធីក្នុងការ សម្រួលការចូលរួមជាសាធារណៈ នៅក្នុងកិច្ចការថវិកាថ្នាក់ក្រោមជាតិ និងការរៀបចំផែនការវិនិយោគឃុំ សង្កាត់។ ក្នុងពេលបច្ចុប្បន្ន ការគាំទ្រនិងការណែនាំបន្ថែមទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត គោលការណ៍ណែនាំនិងបទបញ្ជាថ្មីៗនានា គឺជាការចាំបាច់។

៤. និង ៥. មេរៀនមួយដែល ថ្នាក់ជាតិអាចរៀនសូត្រពីថ្នាក់ក្រោមជាតិ ដូចដែលបានពិភាក្សានៅក្នុង អនុសាសន៍ទី៣ខាងលើ គឺការប្រើប្រាស់ក្រុមការងារបច្ចេកទេសតាមក្រសួងនានា និង/ឬ អនុក្រុមការងា បច្ចេកទេសតាមអនុវិស័យ និងក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ជាយន្តការដើម្បីពង្រឹងនិងពង្រីកការចូលរួម ជាសាធារណៈ

នៅក្នុងដំណើរការថវិកា ។ ខាងក្រោមនេះ គឺជាគំនិតពីរដែលគួរពិចារណាៈទីមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចជម្រុញការចូលរួមយ៉ាងសកម្មរបស់តំណាងប្រជាពលរដ្ឋ និងអង្គការ សង្គមស៊ីវិល នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទូទាំងវដ្តថវិកា និងលើសពីនេះ តាមរយៈការប្រើប្រាស់ ក្រុមការងារបច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានស្រាប់ ឬយន្តការផ្សេងទៀតដែល សមស្របទៅនឹងគោលបំណងនេះ។ ជាការអនុវត្តជាក់ស្តែង តួនាទីរបស់ក្រុមការងារបច្ចេកទេសសម្រាប់ការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានស្រាប់នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺសម្រាប់តែគាំទ្រដល់ការរៀបចំថវិកា និងមិនមែនសម្រាប់ការពិភាក្សាលើបញ្ហាថវិកានិងការសម្រេចចិត្តលើបញ្ហានេះទេ។ ទោះបីជាយ៉ាង ណាក៏ដោយ ជាមួយនឹងការចូលរួមរបស់តំណាងសាធារណជន និងអង្គការសង្គមស៊ីវិល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចដឹងឮពីកង្វល់និងអាទិភាពរបស់ពួកគេ ដែលអាចយកទៅប្រើសម្រាប់ការកំណត់អាទិភាព ថវិកាប្រចាំឆ្នាំ។ មេរៀនដែលទទួលបានពីការចូលរួមរបស់តំណាងសាធារណជននិងអង្គការសង្គមស៊ីវិល នៅក្នុងក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំថវិកាអាចត្រូវបានពង្រីក ដើម្បីជម្រុញការចូលរួមរបស់សាធារណជន នៅក្នុងផ្នែកផ្សេងទៀតនៃវិស័យហិរញ្ញវត្ថុសាធារណៈ ដូចជាការ ត្រួតពិនិត្យការអនុវត្តថវិកា និងការផ្តល់មតិត្រលប់ជាដើម។ ក្នុងប្រការដែលថាយន្តការក្រុមការងារបច្ចេកទេស សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនមែនជាយន្តការមិនសមស្រប ក្រសួងអាចប្រើប្រាស់ឬពង្រឹង បន្ថែមយន្តការដែលមានស្រាប់រួចហើយ ឬគួរបង្កើតនូវយន្តការសមស្របថ្មីផ្សេងទៀត ដើម្បីគាំទ្រគំនិតផ្តួចផ្តើម នៃការចូលរួមជាសាធារណៈនេះ។ ដើម្បីសម្រេចគោលដៅទាំងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញជា ប្រកាសឬការជូនដំណឹងអំពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការរៀបចំ ថវិកា និងការត្រួតពិនិត្យ ការអនុវត្តថវិកា។

ទី ២ អង្គការសង្គមស៊ីវិលអាចចូលរួមជាមួយក្រសួងពាក់ព័ន្ធនានានិងមន្ទីរជំនាញថ្នាក់ខេត្ត តាមរយៈយន្តការដែលមានស្រាប់។ ជាកាលានុវត្តភាពល្អមួយ នៅតាមក្រសួងពាក់ព័ន្ធ និងមន្ទីរជំនាញ ថ្នាក់ខេត្ត ដែលអនុវត្តថវិកាកម្មវិធី ក្រុមការងារបច្ចេកទេសតាមក្រសួងនានា និងអនុក្រុមការងារបច្ចេកទេស តាម អនុវិស័យនៃក្រសួងសាមី និងក្រុមការងារបច្ចេកទេសរបស់មន្ទីរជំនាញនៅថ្នាក់ ខេត្ត និង/ឬយន្តការសមស្រប ដទៃទៀត បាន និងកំពុងដំណើរការជាស្រេច។ ជាមួយនឹងយន្តការដែលមានស្រាប់នេះ សាធារណជននិង អង្គការសង្គមស៊ីវិលអាចចូលរួមជាមួយក្រសួងនិងមន្ទីរបច្ចេកទេសពាក់ព័ន្ធនៅតាមខេត្ត ដើម្បីចូលរួមចំណែក ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាឧទាហរណ៍ លើការចាត់អាទិភាពថវិកាតាំងពីដើមខែមក ជាពិសេស សម្រាប់វិស័យឬក្រសួងអាទិភាពមួយចំនួន។

អំណេះតទៅមុខ រាជរដ្ឋាភិបាល ក្រោមការផ្តួចផ្តើមគំនិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញអនុក្រឹត្យ មួយស្តីពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈក្នុងការរៀបចំថវិកា និងការតាម ដានការអនុវត្តការចំណាយថវិការបស់ក្រសួងនានា ហើយសាកល្បងគំនិតថ្មីនេះជាមួយក្រសួងអាទិភាព

មួយចំនួន ដូចជាក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាលជាដើម។ ក្នុងអនុក្រឹត្យនេះ ក្រសួងក៏អាចពិចារណាបញ្ចូលការចូលរួមរបស់តំណាងសាធារណជន និងអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត ក្នុងការ រៀបចំ និងការត្រួតពិនិត្យការអនុវត្តថវិការបស់មន្ទីរពាក់ព័ន្ធនានាផងដែរ។

៦. អង្គនីតិប្បញ្ញត្តិនៃប្រទេសឥណ្ឌូណេស៊ីនិងប្រទេសហ្វីលីពីន ទទួលបានពិន្ទុខ្ពស់ជាងមុនបន្ទាប់ពី ការរៀបចំសវនាការជាសាធារណៈ ដែលនីតិប្រតិបត្តិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋអាចចូលរួមក្នុង ការសម្រេចចិត្តរបស់ខ្លួន និងផ្តល់ធាតុចូលដល់ការងារត្រួតពិនិត្យថវិការបស់ពួកគេ ឬការបង្ហាញសំណើ ថវិកាជំនួស។ អង្គនីតិបញ្ញត្តិរបស់ប្រទេសកម្ពុជា ក៏អាចប្រើប្រាស់សវនាការសាធារណៈបែបនេះ ជាមធ្យោបាយដ៏មានសក្តានុពល ដើម្បីបង្កើនការចូលរួមជាសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនផងដែរ។ ក្នុងករណីសំណើរថវិកាប្រចាំឆ្នាំ រដ្ឋសភានិងព្រឹទ្ធសភា អាចពិចារណាការពិភាក្សា ជាមួយអង្គការសង្គមស៊ីវិលនិងសាធារណជន មុនពេលសេចក្តីព្រាងច្បាប់ថវិកាជាតិត្រូវបានបញ្ជូនមកដល់ស្ថាប័នខ្លួន ដូចដែលបានអនុវត្តនៅក្នុងប្រទេសហ្វីលីពីនក៏បាន។ ជាការអនុវត្តជាក់ស្តែង រដ្ឋសភាកម្ពុជា បានប្រើប្រាស់ពេលវេលា តិចជាង រយៈពេល៧សប្តាហ៍ (ពេលវេលាអតិបរមាដូចដែលកំណត់ដោយច្បាប់) សម្រាប់ការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ថវិកាជាតិ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៥) ដូច្នេះ អង្គនីតិបញ្ញត្តិមានពេល វេលាគ្រប់គ្រាន់សម្រាប់ការចូលរួមជាសាធារណៈ ហើយពេលវេលាដែលមាននេះ អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនេះ។ គួរមានកែសម្រួលឡើងវិញនូវបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានិងព្រឹទ្ធសភា ដើម្បីបញ្ចូលគោលការណ៍ណែនាំ និងនីតិវិធីនានាសម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងសវនាការរបស់ខ្លួន និងយន្តការផ្តល់មតិត្រលប់ទៅសាធារណជន និងអង្គការសង្គមស៊ីវិល។ ក្នុងន័យនេះ វិទ្យាស្ថានសភាកម្ពុជា (PIC) អាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ជូនរដ្ឋសភានិងព្រឹទ្ធសភានូវព័ត៌មានសមស្រប តាមរយៈការស្រាវជ្រាវរបស់ខ្លួន។

៧. អាជ្ញាធរសវនកម្មកំពូលរបស់ប្រទេសឥណ្ឌូនេស៊ីនិងប្រទេសហ្វីលីពីន ទទួលបានពិន្ទុខ្ពស់ជាងមុន ដោយសារការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យា។ អាជ្ញាធរសវនកម្មប្រទេសទាំងពីរនេះបានប្រើប្រាស់វេបសាយរបស់ខ្លួន ក៏ដូចជាវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម និងបណ្តាញទូរស័ព្ទបន្ទាន់ដើម្បី ទទួលពាក្យ បណ្តឹងនិងមតិយោបល់របស់សាធារណជន និងដើម្បីផ្តល់មតិត្រឡប់ទៅសាធារណជនវិញសម្រាប់កម្មវិធី សវនកម្ម និងការស៊ើបអង្កេតរបស់ពួកគេ។ ក្នុងរយៈពេលខ្លីទៅមធ្យម អាជ្ញាធរសវនកម្មជាតិនៃកម្ពុជាអាច ពិចារណាកែលម្អវេបសាយរបស់ខ្លួន និងមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត ដើម្បីបង្កើនការទាក់ទង ជាមួយសាធារណជន និងអង្គការសង្គមស៊ីវិល ជាឧទាហរណ៍ ដើម្បីទទួលនូវធាតុចូលសម្រាប់កម្មវិធីសវនកម្ម របស់ខ្លួន ក៏ដូចជាដើម្បីផ្តល់មតិត្រលប់ទៅពួកគេវិញ។ ក្នុងរយៈពេលវែង អាជ្ញាធរសវនកម្មជាតិអាចចេញនូវ គោលការណ៍ណែនាំមួយ ដែលអាចឱ្យសាធារណជននិងអង្គការសង្គមស៊ីវិល ចូលរួមក្នុងសវនកម្មសមិទ្ធិផល ការងាររបស់ខ្លួន ហើយការនេះអាចចាប់ផ្តើមជាគម្រោងសាកល្បងមួយលើវិស័យអទិភាពណាមួយដូចជាវិស័យអប់រំ ឬសុខាភិបាលជាដើម។

៨. នៅប្រទេសកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រើប្រាស់គណនីហ្វេសប៊ុករបស់សម្តេច ដើម្បីទទួល និងឆ្លើយតបចំពោះពាក្យបណ្តឹងនិងសំណូមពរនានាពីប្រជាពលរដ្ឋ ក៏ដូចជាដើម្បីកែប្រែគោលនយោបាយមួយចំនួនក៏មាន (Vong & Hok, 2018) ។ ជាការពិត ស្ទើរតែគ្រប់ស្ថាប័នរដ្ឋទាំងអស់នៅប្រទេសកម្ពុជា មានវេបសាយនិងគណនីហ្វេសប៊ុកផ្ទាល់ខ្លួន។ ហេតុដូច្នេះ ក្រៅពីអាជ្ញាធរជាតិសវនកម្ម ក្រសួងពាក់ព័ន្ធ នានា រដ្ឋសភា និងព្រឹទ្ធសភាកម្ពុជា អាចទាញផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) ដែលមានប្រសិទ្ធិភាពនិងចំណាយទាបនានាបែបនេះ ដើម្បីឱ្យមានការចូលរួមពីសំណាក់សាធារណជន និងអង្គការសង្គមស៊ីវិល នៅក្នុងកិច្ចការរបស់ពួកគេ នៅដំណាក់កាលនានានៃវដ្តថវិកា ក៏ដូចជាការរៀបចំ និងអនុវត្តផែនការឬយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការផ្តល់សេវារបស់ខ្លួន។ ក្នុងករណីនេះ វេបសាយរបស់ពួកគេ ត្រូវការការធ្វើបច្ចុប្បន្នភាពនិងការថែទាំជាប្រចាំ ហើយវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេចាំបាច់ត្រូវ បានប្រើប្រាស់ ដើម្បីឱ្យមានការចូលរួមពីសាធារណជននិងអង្គការសង្គមស៊ីវិល។ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិសវនកម្ម រដ្ឋសភា និងព្រឹទ្ធសភា អាចឆ្លើយតប បានល្អប្រសើរជាងពេលបច្ចុប្បន្ន ជាពិសេសតាមរយៈការប្រើប្រាស់បណ្តាញព័ត៌មានថ្មីនិងបណ្តាញសង្គម នានា និងដើម្បីឱ្យមានការចូលរួមយ៉ាងសកម្មពីសាធារណជន និងអង្គការសង្គមស៊ីវិល នៅក្នុងសកម្មភាព ថវិការបស់ពួកគេ រួមទាំងនៅក្នុងវដ្តថវិកាទាំងមូល វាជាការចាំបាច់ដែលត្រូវមានការកសាងសមត្ថភាពបុគ្គលិក របស់ពួកគេ ជាពិសេសលើជំនាញលើកកម្ពស់តម្លាភាពថវិកា ទំនាក់ទំនងសាធារណៈ និងការប្រើប្រាស់និង ថែរក្សាឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា។ ក្នុងរយៈពេលខ្លីទៅមធ្យមស្ថាប័នទាំងនេះអាច ពិចារណាបញ្ចូលការកសាងសមត្ថភាពបុគ្គលិកនេះ ទៅក្នុងផែនការការងារប្រចាំឆ្នាំ និងផែនការរយៈពេលខ្លីរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ប្រហែលជាអាចជាដៃគូរក្នុងការគាំទ្រស្ថាប័នទាំងនេះនៅក្នុងរឿងនេះ។

# ជំពូកទី ១៖ សេចក្ដីផ្ដើម

## ១.១ មូលហេតុសម្រាប់ការសិក្សា

ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល (CSOs) គួរមានសិទ្ធិនិងឱកាសចូលរួមការពិភាក្សានិងការដេញដោលក្នុងការរៀបចំនិងអនុវត្តគោលនយោបាយសារពើពន្ធ (GIFT, 2018)។ ការចូលរួមរបស់ សាធារណជនអាច ជួយឱ្យពួកគេមានសម្លេងក្នុងការសម្រេចចិត្តដ៏សំខាន់លើគោលនយោបាយផ្សេងៗ ដែលអាចផ្ដល់ផលល្អ ឬបង្កផលប៉ះពាល់ដល់ពួកគេ។ ដូច្នេះការចូលរួមត្រូវបានគេទទួលយកជា បណ្ដើរៗថាជាឧបករណ៍ដែលជួយលើកកម្ពស់តម្លាភាពនិងគណនេយ្យផ្នែកសារពើពន្ធក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ (PFM) ជួយកែលម្អលទ្ធផលនៃគោលនយោបាយសារពើពន្ធនិងការអភិវឌ្ឍ និងនាំមកនូវ "សង្គមមួយដែលមានលក្ខណៈប្រជាធិបតេយ្យកាន់តែប្រសើរជាងមុន និងដែលប្រជាពលរដ្ឋមានសិទ្ធិអំណាចនិងការយល់ដឹងច្រើនជាងមុន"។ មិនតែប៉ុណ្ណោះ ការចូលរួមក៏មានសក្ដានុពលក្នុងការជំរុញឲ្យរដ្ឋាភិបាលកាន់តែមានភាពស្របច្បាប់ និងបង្កើនទំនុកចិត្តពីសាធារណជន (ibid, Capistrano, 2017, Marchessault, nd) ។

ការស្ទង់មតិថវិកាបើកចំហ (OBS) បានបង្ហាញថាកម្រិតនៃការចូលរួមពីសាធារណជន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជានៅមានកំរិតស្ដួចស្ដើងចាប់តាំងពីមានការស្ទង់មតិលើកដំបូងក្នុងឆ្នាំ២០០៨មក។ វិធីសាស្ត្រដ៏មានសក្ដានុពលមួយដើម្បីស្វែងយល់vពីការខ្វះខាតក្នុងការចូលរួមនេះគឺការពិនិត្យមើលមូលដ្ឋានក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្ដីពីការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ តើក្របខ័ណ្ឌច្បាប់និងគោលនយោបាយរបស់ប្រទេសកម្ពុជាបានផ្ដល់ ឱកាសអ្វីខ្លះសម្រាប់ ការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ? តើមានវិធីអ្វីខ្លះដែលអាចផ្ដល់ឱកាស និងសក្ដានុពលឱ្យសាធារណជនចូលរួមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ? របាយការណ៍នេះព្យាយាមឆ្លើយសំណួរទាំងពីរនេះ។

## ១.២ គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងចំបងពីរ គឺ(១) ធ្វើការវិភាគក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធ នឹងការចូលរួមរបស់សាធារណជនក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងដំណើរការធ្វើថវិកា និង(២) ស្វែងរកច្រកចូលជាក់លាក់ដើម្បីឱ្យមានការចូលរួមជាសាធារណៈនៅក្នុងដំណើរការរៀបចំផែនការ ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ១.៣ វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងជាបីដំណាក់កាលៈ

**១. ការពិនិត្យក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលមានស្រាប់ ស្តីពីការចូលរួមរបស់សាធារណជន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជា និងការអនុវត្តល្អៗរបស់ប្រទេសឥណ្ឌូនេស៊ីនិងប្រទេស ហ្វីលីពីន**

ជំហានដំបូងគឺការពិនិត្យច្បាប់ទាក់ទងនឹងថវិកាជាតិ រាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ សេចក្តីសម្រេច និងគោលនយោបាយផ្សេងៗទៀតរបស់ប្រទេសកម្ពុជា ជាពិសេសច្បាប់និងគោលនយោបាយពាក់ព័ន្ធនឹងការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជំហានទីពីរគឺការពិនិត្យការអនុវត្តនៃការចូលរួមជាក់ស្តែងនៅថ្នាក់ក្រោមជាតិ។ ការអនុវត្តទាំងនេះអាចផ្តល់ជាមេរៀនសម្រាប់ការអនុវត្តការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ។ ជំហានទីបីគឺជាការពិនិត្យការអនុវត្តល្អៗនៅប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូណេស៊ីដែលជាប្រទេសទទួលបានពិន្ទុខ្ពស់ជាងគេក្នុងចំណោមបណ្តាប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)។ ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូណេស៊ីត្រូវបានជ្រើសរើសយកមកសិក្សាលម្អិតដោយសារតែពួកគេមានការចូលរួមជាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈល្អជាងប្រទេសកម្ពុជា បានពិន្ទុសរុបលើតម្លាភាពថវិកាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងការស្ទង់មតិ OBS ខ្ពស់ជាងប្រទេសកម្ពុជា និងជាពិសេសប្រទេសទាំងពីរនេះមានការអនុវត្តល្អៗមួយចំនួន ដែលអាចជាមេរៀនសម្រាប់ការអនុវត្តនៅប្រទេសកម្ពុជា។ ប្រទេសហ្វីលីពីនគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដំបូងគេដែលបានចូលរួមធ្វើការស្ទង់មតិថវិកា បើកចំហនៅឆ្នាំ២០០៦ និងជាប្រទេសមួយដែលរដ្ឋាភិបាលរបស់ខ្លួនជាអ្នកជំរុញដ៏សំខាន់ក្នុងការចាប់ផ្តើមធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងជំរុញការចូលរួមជាសាធារណៈ។

ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ប្រទេសហ្វីលីពីនបានរក្សាដំណែងជាប្រទេសដែលបានពិន្ទុ ការចូលរួមជាសាធារណៈខ្ពស់ជាងគេនៅក្នុងចំណោមបណ្តាប្រទេសអាស៊ាន ហើយសកម្មភាពលើកកម្ពស់ការចូលរួមនេះកាន់តែមានភាពប្រសើរឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ យោងតាមគំនិតផ្តួចផ្តើមសកលសម្រាប់តម្លាភាពសារពើពន្ធ (GIFT) ការចូលរួមជាសាធារណៈនៅក្នុងដំណើរការថវិកានៅប្រទេសហ្វីលីពីនជាករណីមួយក្នុងចំណោមករណីល្អបំផុតនៅទូទាំងពិភពលោក (Petrie, 2018)។ ចំណែកប្រទេសឥណ្ឌូណេស៊ីវិញបានចាត់វិធានការមួយចំនួនដើម្បីពង្រឹងការចូលរួមជាសាធារណៈក្នុងកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីខ្លួនបានចូលរួមការស្ទង់មតិពីឆ្នាំ២០០៦មក។ ប្រទេសនេះជាទូទៅបានរក្សាដំណែងជាអ្នកបានពិន្ទុខ្ពស់ទីពីរ (ឬទីបី) ក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ ជារួមទាំងប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូណេស៊ីសុទ្ធតែទទួលបានពិន្ទុល្អជាងប្រទេសកម្ពុជា។ នៅក្នុងបរិបទនេះវាជាការចាំបាច់ដែលត្រូវស្វែងយល់ពីអ្វីដែលប្រទេសទាំងពីរនេះ (ជាពិសេសស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល របស់គេ) បានធ្វើដើម្បីលើកកម្ពស់ការចូលរួមជាសាធារណៈ។

**២. កិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នសាធារណៈ ដែលមានប្រតិបត្តការណ៍ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ក្នុងដំណាក់កាលទីពីរគឺមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័ននិងគណៈកម្មាធិការពាក់ព័ន្ធចំនួន៣ ដែលរួមមាន ១) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២) អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលមានទីតាំងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) និង៣) អាជ្ញាធរសវនកម្មជាតិ (NAA)។ ក្រុមអ្នកស្រាវជ្រាវបានខិតខំប្រឹងប្រែងទាក់ទងស្ថាប័នរដ្ឋបីផ្សេងទៀតតាមរយៈការសម្របសម្រួលរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះមិនបានជោគជ័យនោះទេ។ ស្ថាប័នទាំងនោះរួមមាន ១) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ២) គណៈកម្មការទី២ ស្តីពីសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា និង៣) គណៈកម្មការទី២ នៃព្រឹទ្ធសភា។ គោលបំណងនៃកិច្ចប្រជុំទាំងនេះរួមមានៈ (១) បង្ហាញពីលទ្ធផលបឋមពីការស្រាវជ្រាវ ការអនុវត្តល្អៗរបស់ប្រទេសផ្សេងៗ និងអនុសាសន៍មួយចំនួន (២) ស្វែងរកមតិរិះគន់ស្ថាបនាសម្រាប់ការរកឃើញ អនុសាសន៍និងវិធីសាស្ត្រផ្សេងៗដើម្បីធ្វើឱ្យមានការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់ប្រសើរឡើង និង(៣) បង្កើនការយល់ដឹងអំពីការអនុវត្តល្អៗ និងទាក់ទាញចំណាប់អារម្មណ៍ពីភាគីពាក់ព័ន្ធដើម្បីបង្កើនឱកាសចូលរួមឱ្យបានទូលំទូលាយ។

**៣. សម្ភាសន៍ជាមួយអ្នកជំនាញមួយចំនួនដែលដឹងពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្នែករដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) និងអាជ្ញាធរមូលដ្ឋាននិងប្រជាពលរដ្ឋនៅឃុំមួយ**

ដំណាក់កាលទីបីគឺ ១)សម្ភាសន៍ជាមួយអ្នកជំនាញបច្ចេកទេស និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៤រូប ដែលបានចូលរួមក្នុងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារថវិកា ការងារអប់រំ ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍជនបទ និងកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ២) សម្ភាសន៍ជាមួយប្រជាពលរដ្ឋនិងមន្ត្រីមូលដ្ឋានក្នុងឃុំមួយ។ សម្ភាសន៍នេះត្រូវបានធ្វើឡើងដើម្បីជួយបញ្ជាក់ឬបដិសេធការរកឃើញបឋមក្នុងការស្រាវជ្រាវនេះ។

## ១.៤ ទស្សនទាន "ការចូលរួម"

ការចូលរួមជាសាធារណៈក្នុងកិច្ចការរបស់រដ្ឋ និងជាពិសេសក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់គណនេយ្យភាពសាធារណៈ តម្លាភាព ភាពទុកចិត្តលើស្ថាប័នសាធារណៈ ការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ និងការផ្តល់ភាពស្របច្បាប់ដល់រដ្ឋាភិបាល (Baimyrzaeva & Kose, 2014; de Renzio & Kroth, 2011 GIFT 2018 Capristano, 2017 Sopanah, 2012) ។ ការចូលរួមជាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅទៅលើ "វិធីផ្សេងៗដែលប្រជាពលរដ្ឋនិងតួអង្គមិនមែនរដ្ឋទាក់ទងដោយផ្ទាល់ក្នុងការពិភាក្សាជាសាធារណៈជាមួយស្ថាប័នរដ្ឋនានា (ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិ

ប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល) ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយសារពើពន្ធ" និងការត្រួតពិនិត្យនិងវាយតម្លៃ (M & E) ) ការអនុវត្តទាំងនេះ (GIFT, 2018, ទំព័រ 81) [1]។

ការចូលរួមនេះមិនមែនសំដៅតែទៅលើការចូលរួមរបស់សាធារណជនក្នុងវដ្តថវិកាប្រចាំឆ្នាំប៉ុណ្ណោះទេ ប៉ុន្តែវាក៏រួមបញ្ចូលទាំងការចូលរួមក្នុងការងារសារពើពន្ធដទៃទៀតដូចជា (១) ការពិនិត្យគោលនយោបាយជុំវិញចំណូលនិងចំណាយនិង (២) ការចូលរួមក្នុងដំណើរការរៀបចំនិងផ្តល់សេវាសាធារណៈ និងគម្រោងវិនិយោគសាធារណៈ។ ដើម្បីធានាបាននូវតម្លាភាពនិងការចូលរួមប្រកបដោយអត្ថន័យ ការចូលរួមក៏ពាក់ព័ន្ធផងដែរទៅនឹងការផ្តល់មតិយោបល់របស់រដ្ឋាភិបាលត្រលប់ទៅសាធារណជន និងអង្គការសង្គមស៊ីវិលវិញអំពីការប្រើប្រាស់ធាតុចូលរបស់ពួកគេ ពីសំណាក់រដ្ឋាភិបាលដើម្បីកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការចូលរួមមានពីរទម្រង់: "ការចូលរួមដោយការអញ្ជើញ" "invited participation" និង "ការចូលរួមដោយការបង្កើត" "invented participation" (ibid) ។

"ការចូលរួមដោយការអញ្ជើញ" មានន័យថាការចូលរួមដែលផ្តួចផ្តើមឡើងដោយអង្គភាពរដ្ឋដូចជាក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាមីដទៃទៀត ឬរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីស្វែងរកធាតុចូលពីសាធារណជនក្នុងពេលរៀបចំថវិកា។ ស្ថាប័ននីតិបញ្ញត្តិអាចអញ្ជើញប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ឱ្យជួយពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ថវិកាជាតិ ឬ ស្ថាប័នសវនកម្មកំពូលអាចអញ្ជើញ ប្រជាពលរដ្ឋ និងអង្គការ សង្គមស៊ីវិលឱ្យចូលរួមកម្មវិធីសវនកម្មឬការងារនានារបស់ខ្លួន (ibid)។ ទាំងនេះគឺជាឧទាហរណ៍មួយចំនួនទាក់ទងនឹង "ការចូលរួមដោយការអញ្ជើញ" ។

"ការចូលរួមដោយការបង្កើត" មានន័យថាការចូលរួមរវាងស្ថាប័នរដ្ឋនិងតួអង្គមិនមែនរដ្ឋប៉ុន្តែការចូលរួមនេះត្រូវបានផ្តួចផ្តើមដោយតួអង្គមិនមែនរដ្ឋ។ ក្នុងករណីនេះតួអង្គមិនមែនរដ្ឋជាអ្នកដឹកនាំដំណើរការនៃការចូលរួមហើយស្ថាប័នរដ្ឋអាចនឹងចូលរួមយ៉ាងទំលំទូលាយ ចូលរួមតិចតួច រឺមិនចូលរួមទាល់តែសោះក្នុងដំណើរការនេះ។ ឧទាហរណ៍ល្អមួយគឺការស្ទង់មតិ OBS ដែលរៀបចំឡើងដោយសង្គមស៊ីវិលរៀងរាល់២ឆ្នាំម្តងចាប់ពីឆ្នាំ២០០៦មក (ibid)។

ការចូលរួមទាំងពីរប្រភេទនេះប្រើប្រាស់យុទ្ធវិធីផ្សេងៗគ្នា ប៉ុន្តែពួកវាជួយបំពេញគ្នាទៅវិញទៅមក។ យុទ្ធវិធីសម្រាប់ទំនាក់ទំនងគ្នាអាចជាការប្រាស្រ័យទាក់ទងគ្នាឬពិភាក្សាដោយផ្ទាល់ ឬតាមរយៈអ៊ីនធឺណែត ឬតាមរូបភាពទាំងពីររួមគ្នា។ លើសពីនេះទៅទៀត ទំនាក់ទំនងអាចមានរូបភាពជាការពិគ្រោះយោបល់ជា សាធារណៈ ដែលប្រព្រឹត្តទៅតែមួយលើក ឬជាប់រហូតនិងមានលក្ខណៈជាស្ថាប័ន។ លើសពីនេះទៀតការចូលរួមអាច

---

[1] សម្រាប់និយមន័យផ្សេងទៀត សូមមើលអត្ថបទផ្សេងៗ ដូចជា Sopanah, A. (2012). Ceremonial Budgeting: Public Participation in Development Planning at an Indonesian Local Government Authority. *Journal of Applied Management Accounting Research*, *10*(2), 73.

មានរូបភាពជា "ការចូលរួមក្នុងការងារថវិកា" ដែលក្នុងនោះប្រជាពលរដ្ឋអាចមានអំណាចសម្រេចនិងបោះឆ្នោតគាំទ្រឬមិនគាំទ្រលើខ្ទង់ចំណាយថវិកាជាក់លាក់ណាមួយ (ibid de Renzio & Kroth, 2011) ។

របាយការណ៍នេះផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើ "ការចូលរួមដោយការអញ្ជើញ" ដោយពិនិត្យមើលនូវក្របខ័ណ្ឌច្បាប់និងគោលនយោបាយពាក់ព័ន្ធ ក៏ដូចជាយន្តការដែលបានប្រើប្រាស់ដែលមានចែងទាំង ស្រុងឬដោយផ្នែក ឬនៅមិនទាន់បានចែងក្នុងច្បាប់ពេញលក្ខណៈ ហើយដែលច្បាប់និងយន្តការទាំងអស់នេះ អាចឱ្យសាធារណជននិងអង្គការសង្គមស៊ីវិលចូលរួមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានផ្ដល់សិទ្ធិដល់ស្ថាប័នរដ្ឋដូចជា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និង ស្ថាប័នសវនកម្មកំពូលក្នុងការបង្កើនការចូល រួមពីប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ។ ការចូលរួមជា សាធារណៈអាចមានរូបភាពជាការរៀបចំការអនុម័ត និងការតាមដានការអនុវត្តថវិកា និងការផ្ដល់មតិយោបល់ត្រលប់របស់ស្ថាប័នរដ្ឋចំពោះធាតុចូលដែលផ្ដល់ដោយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល និងការត្រួតពិនិត្យការអនុវត្តថវិកា (Baimyrzaeva & Kose, 2014 OBI 2017, Marchessault, nd.)។ ក្របខ័ណ្ឌ "ការចូលរួមដោយការអញ្ជើញ" នេះក៏ត្រូវបានប្រើដើម្បីវិភាគនិងទាញយកមេរៀនពីករណីប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ីផងដែរ។

## ១.៥ គម្លាតខាតនៃការសិក្សា

ថ្វីបើមានកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យរបាយការណ៍នេះមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងលម្អិតតាមដែលអាចធ្វើទៅបានក៏ដោយ ក៏ការសិក្សានេះនៅតែមានកង្វះខាតមួយចំនួន។ ទីមួយ ក្រុមអ្នកស្រាវជ្រាវមិនបានជួបជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ដូចដែលបានគ្រោងទុកដើម្បីស្វែងរកការបញ្ជាក់ និងធាតុចូលពីពួកគាត់សម្រាប់ការសិក្សានេះ។ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការសម្របសម្រួលកិច្ចប្រជុំទាំងនេះពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជាក៏ដោយ មានស្ថាប័នចំនួនបីដែលក្រុមអ្នកស្រាវជ្រាវមិនបានជួបតាមការគ្រោងទុក។ ដូច្នេះការសន្និដ្ឋាននៅក្នុងការសិក្សានេះត្រូវបានដកចេញពីទិន្នន័យនិងព័ត៌មានដែលក្រុមការងារប្រមូលបានតាមលទ្ធភាព និងតាមរយៈការសិក្សាពីប្រទេសហ្វីលីពីននិងប្រទេសឥណ្ឌូនេស៊ី។

ទីពីរ ដោយសារធនធាននិងពេលវេលាមានកំណត់ របាយការណ៍នេះយកតែប្រទេសអាស៊ានពីរប៉ុណ្ណោះមកធ្វើជាករណីប្រៀបធៀប។ បើការសិក្សានេះអាចទាញយកប្រទេសក្នុងនិងក្រៅតំបន់ផ្សេងទៀតមកប្រៀបធៀបនោះ ការវិភាគនឹងបានទូលំទូលាយជាងនេះ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងពីរដែលត្រូវបានជ្រើសរើសមកប្រៀបធៀបនេះជាប្រទេសដែលបានពិន្ទុល្អបំផុតនៅក្នុងតំបន់អាស៊ាន។

ទីបី ការស្រាវជ្រាវនេះត្រូវបានគ្រោងសិក្សាពីដំបូងជា "ការសិក្សាត្រួតពិនិត្យផ្នែកច្បាប់និងគោលនយោបាយ" ហេតុដូច្នេះវាមានចំណុចខ្លាំង និងកង្វះខាតដូចការសិក្សាដែលមានលក្ខណៈជាការសិក្សាពិនិត្យឡើងវិញនូវ ឯកសារដែលមានស្រាប់។ ប៉ុន្តែក្រុមអ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយអ្នកជំនាញគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ក៏ដូចជាទៅស្រាវជ្រាវនៅឃុំមួយដើម្បីស្វែងរកទិន្នន័យបន្ថែម និងផ្ទៀងផ្ទាត់លទ្ធផលនៃការរកឃើញបឋម។ ការធ្វើបែបនេះបានជួយបំពេញបន្ថែមនូវកង្វះខាតរបស់ការសិក្សាដែលពឹងផ្អែកលើតែការពិនិត្យឯកសារសុទ្ធសាធ។ ការស្រាវជ្រាវក៏ទទួលបានអត្ថប្រយោជន៍ពីឯកសារ ដែលមិនទាន់បានបោះពុម្ពផ្សាយមួយចំនួនដែលផ្តល់ដោយស្ថាប័នរដ្ឋ និងបុគ្គលដែលក្រុមអ្នកស្រាវជ្រាវបានជួបសម្ភាស។

ទីបួនការសិក្សានេះផ្តោតលើ "ការចូលរួមដោយការអញ្ជើញ" ប៉ុន្តែមិនបានពិនិត្យមើល "ការចូលរួមដោយការបង្កើត" នោះទេ ដែលនេះជាការរៀបចំតាំងពីដំបូងមក។ តាមជាក់ស្តែងគុណភាពនៃ "ការចូលរួមដោយការអញ្ជើញ" អាស្រ័យទៅនឹងគុណភាពនៃ "ការចូលរួមដោយការបង្កើត" ដែរ ហើយវាក៏អាស្រ័យផងដែរទៅនឹងសមត្ថភាពនិងលទ្ធភាពរបស់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការធ្វើការរួមគ្នា។ ចំណុចទាំងនេះមិនត្រូវបានគ្របដណ្តប់នៅក្នុងរបាយការណ៍នេះទេ ប៉ុន្តែមានលើកឡើងខ្លះៗក្នុងការសិក្សាស្រាវជ្រាវពីមុនមួយដែល គាំទ្រដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលអំពីកម្ពុជានៅឆ្នាំ២០១៧ (សូមមើល ចាន់ ឆ្នាំ ២០១៧) ។ ការស្រាវជ្រាវដោយ លោកស្រី ចាន់ សុខយេង និងសហការី នៅឆ្នាំ២០១៧នេះ បានវាយតម្លៃសមត្ថភាព សក្តានុពល និងកង្វះខាតរបស់សមាជិកក្រុមការងារថវិការបស់ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល (BGW) និងអង្គការសង្គមស៊ីវិលដទៃទៀត នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត ក្នុងការចូលរួមធ្វើថវិកាជាមួយស្ថាប័នរដ្ឋដើម្បីបង្កើនគណនេយ្យភាព និងតម្លាភាពថវិកា។

ចុងបញ្ចប់ គោលគំនិតនៃការចូលរួមដែលបានប្រើប្រាស់នៅក្នុងការស្ទង់មតិ OBS និងគំនិតផ្តួចផ្តើមសកលដើម្បីតម្លាភាពសារពើពន្ធនិងត្រូវបានប្រើក្នុងការសិក្សានេះ អាចមានវិសាលភាពទូលំទូលាយ និងមហិច្ឆតាខ្ពស់ពេកសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា។ លើសពីនេះទៀត ការសិក្សានេះក៏មិនបានពិនិត្យលើការរិះគន់លើក្របខ័ណ្ឌនៃការចូលរួមជាសាធារណៈដែលការស្ទង់មតិ OBS និងគំនិតផ្តួចផ្តើមសកលដើម្បី តម្លាភាពសារពើពន្ធបានប្រើប្រាស់នោះទេ។ ហើយការដែលការសិក្សានេះប្រើប្រាស់ក្របខ័ណ្ឌនៃការចូលរួមរបស់ការស្ទង់មតិ OBS និងគំនិតផ្តួចផ្តើមសកលដើម្បីតម្លាភាពសារពើពន្ធនេក៏មិនមែនមានន័យថាក្របខ័ណ្ឌការស្ទង់មតិ OBS គឺជាឧបករណ៍សមស្របតែមួយគត់ដែលអាចយកមកប្រើប្រាស់ ឬវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះទេ។

## ១.៦ និន្នាការទូទៅនៃសមិទ្ធផលកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង "ការចូលរួមដោយការអញ្ជើញ" នៅប្រទេសកម្ពុជា

ចាប់តាំងពីប្រទេសកម្ពុជាបានចូលរួមក្នុងការស្ទង់មតិ OBS ក្នុងឆ្នាំ២០០៨មក កម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់មួយចំនួន ដែលក្នុងនោះរួមមានការបញ្ចេញឯកសារថវិកាបានកាន់តែច្រើនពីសំណាក់រាជរដ្ឋាភិបាលដល់សាធារណជនដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម។ សំខាន់ជាងនេះទៅទៀតគឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរៀបចំផែនការវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលដំណើរការនេះអាចផ្តល់ឱកាសឱ្យមានការដាក់បញ្ចូលនូវបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈទៅក្នុងច្បាប់ថ្មីនោះ[2]។ ក្រៅពីនេះសមិទ្ធផលកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្សេងទៀតមានដូចជា ប្រព័ន្ធរដ្ឋបាលប្រមូលពន្ធមានភាពរឹងមាំជាងមុន ថវិកាគួរឱ្យទុកចិត្តនិងមានគណនេយ្យភាពជាងមុន ការដាក់ឯកសារហិរញ្ញវត្ថុឱ្យអាចប្រើបានតាមរយៈកម្មវិធីបច្ចេកវិទ្យាចល័ត ការអនុវត្តថវិកាកម្មវិធីនៅទូទាំងប្រទេស ការកើនចំណូលសាធាណៈ ការបង្កើនថវិកាដល់វិស័យអាទិភាព ការបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងការចេញផ្សាយរបាយការណ៍សវនកម្មទាន់ពេលវេលា (សូមមើល GSPFMRPSC, 2018) ។ យោងតាមផែនការការងាររយៈពេលមធ្យមនិងដែលទើបតែចេញផ្សាយចុងក្រោយរបស់ខ្លួន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្តេជ្ញាចិត្តធ្វើការកែលម្អការអនុវត្តការងាររបស់ខ្លួនដើម្បីបង្កើនពិន្ទុរបស់ប្រទេសកម្ពុជានៅក្នុងការស្ទង់មតិ OBS ហើយចំនុចនេះត្រូវបានដាក់បញ្ចូលនៅក្នុងផែនការការងារបច្ចុប្បន្នរបស់ក្រសួងនេះផងដែរ។ ដូចដែលមាននៅក្នុងការពិភាក្សាខាងក្រោម កំណែទម្រង់ច្បាប់ និងគោលនយោបាយឆ្ពោះទៅរកការចូលរួមឱ្យកាន់តែច្រើនពីសំណាក់សាធារណជននៅក្នុងកិច្ចការទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងខ្លះៗដើម្បីឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល ជាឧទាហរណ៍គឺការអញ្ជើញអង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងក្រុមការងារបច្ចេកទេស (TWG) គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយមួយទៀតគឺការអញ្ជើញអង្គការសង្គមស៊ីវិលឱ្យចូលរួមនៅក្នុងកិច្ចប្រជុំស្តីពីសំណើថវិកាមុនពេលត្រូវបញ្ជូនសំណើនេះទៅគណៈរដ្ឋមន្ត្រី។ ក៏ប៉ុន្តែនៅតាមក្រសួងសាម៉ីនីមួយៗស្ទើរតែគ្មានយន្តការសម្រាប់ឱ្យពួកគេចូលរួមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ បើទោះបីជាមានយន្តការខ្លះៗសម្រាប់ការចូលរួមរបស់ពួកគេក្នុង "ក្រុមការងារបច្ចេកទេស" នៅតាមក្រសួងមួយចំនួនក៏ដោយ។ យោងតាមរបាយការណ៍របស់ការស្ទង់មតិ OBS
បានឱ្យដឹងថា អាជ្ញាធរសវនកម្មជាតិមានសមត្ថភាពត្រួតពិនិត្យខ្ពស់ ប៉ុន្តែមិនទាន់មានការចូលរួមជាសាធារណៈនៅក្នុងការងាររបស់ខ្លួននៅ

---

[2] បទសម្ភាសន៍ទី១២, ជាមួយដៃគូរអភិវឌ្ឍន៍, ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៩។

ឡើយ។ ប៉ុន្តែការសន្ទនាជាមួយអាជ្ញាធរសវនកម្មជាតិបង្ហាញថា ថ្មីៗនេះមានយន្តការមិនអចិន្ត្រៃយ៍មួយចំនួនត្រូវបានបង្កើតឡើងសម្រាប់ការចូលរួមរបស់សាធារណជន។ អាជ្ញាធរសវនកម្មជាតិបានពន្យល់ថាអ្នកដែលមានបំណងចង់ប្តឹង អាចដាក់ពាក្យបណ្តឹងទៅការិយាល័យរដ្ឋបាលរបស់អាជ្ញាធរនេះ តាមរយៈអ៊ីម៉ែល ឬតាមទំព័រហ្វេសប៊ុក (ទំព័ររបស់អាជ្ញាធរសវនកម្មជាតិ ឬទំព័ររបស់សម្តេចនាយករដ្ឋមន្ត្រី)[3]។ អាជ្ញាធរសវនកម្មជាតិក៏មានក្រុមការងារដែលមានសមាជិក៦រូប សម្រាប់តាមមើលទំព័រហ្វេសប៊ុករបស់សម្តេចនាយករដ្ឋមន្ត្រីដើម្បីមើលគ្រប់ផូសពីអ្នកប្រើប្រាស់ហ្វេសប៊ុកដែលសរសេរទាក់ទងនឹងអាជ្ញាធរសវនកម្មជាតិ។ អាជ្ញាធរនេះក៏កំពុងធ្វើបច្ចុប្បន្នភាពវេបសាយរបស់ខ្លួននិងពិចារណាបង្កើតផ្នែកមួយនៅលើវេបសាយនេះសម្រាប់ទទួលពាក្យ បណ្តឹង។ ចាប់ពីឆ្នាំ២០១៨មកអាជ្ញាធរសវនកម្មជាតិ បានចាប់ផ្តើមធ្វើសវនកម្មលើការអនុវត្តការងារលើគម្រោងសាធារណៈចំនួនប្រាំ ហើយការធ្វើសវនកម្មបែបនេះមានការប្រមូលព័ត៌មានពីអ្នកប្រើសេវាសាធារណៈអំពីមតិយោបល់របស់ពួកគេលើគម្រោងសាធារណៈទាំងប្រាំនោះ។ ទោះយ៉ាងណាក៏ដោយរបាយការណ៍សវនកម្មនៃការអនុវត្តការងារមិនត្រូវបានផ្សព្វផ្សាយដល់សាធារណជនតាមរយៈវេបសាយរបស់ខ្លួននៅឡើយទេ (គិតត្រឹមពេលសរសេររបាយការណ៍នេះ)។ ការចូលរួមពីសាធារណជនក្នុងការងារសវនកម្មពីរប្រភេទទៀត គឺសវនកម្មហិរញ្ញវត្ថុនិង សវនកម្មអនុលោមភាពមិនទាន់មានការចូលរួមជាសាធារណៈនោះទេ។ ទាក់ទងនឹងការចូលរួមជាមួយរដ្ឋសភាវិញ មានរបាយការណ៍ថាអង្គការសង្គមស៊ីវិលត្រូវបាន អញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំមួយចំនួនដែលធ្វើឡើងដោយគណៈកម្មការទី២ លើសេចក្តីព្រាងច្បាប់ថវិកានៅពេលដែលរដ្ឋសភាកោះហៅតំណាងរាជរដ្ឋាភិបាលឱ្យមកបញ្ជាក់វែកញែកពីសេចក្តីព្រាងច្បាប់នេះ។

**តារាង ០១: លទ្ធភាពទទួលបានជាសាធារណៈនូវឯកសារថវិកាពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧**

| ឯកសារ | ២០០៨ | ២០១០ | ២០១២ | ២០១៥ | ២០១៧ |
|---|---|---|---|---|---|
| របាយការណ៍បុរេថវិកា | 🟡 | 🟢 | 🟢 | 🟢 | 🟢 |
| សំណើថវិការបស់ស្ថាប័ននីតិប្រតិបត្តិ | 🟡 | 🟡 | 🟡 | 🟡 | 🟡 |
| ច្បាប់ថវិកាដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| ច្បាប់ថវិកាសម្រាប់ប្រជាពលរដ្ឋ | 🔴 | 🔴 | 🔴 | 🟡 | 🟢 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🟡 | 🟢 |

[3] អាជ្ញាធរសវនកម្មជាតិមិនទទួលបានពាក្យបណ្តឹងពីសាធារណជននិងអង្គការសង្គមស៊ីវិលទេនៅឆ្នាំ២០១៨។ ប្រភព: កិច្ចប្រជុំពិគ្រោះយោបល់ទីមួយជាមួយតំណាងអាជ្ញាធរសវនកម្មជាតិ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩។

| | | | | | |
|---|---|---|---|---|---|
| ការពិនិត្យពាក់កណ្តាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 | 🟢 |
| របាយការណ៍ចុងឆ្នាំ | 🟢 | 🟢 | 🟢 | 🔴 | 🟡 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🔴 | 🟢 |

🟢 អាចរកបានជាសាធារណៈ 🔴 មិនបានផលិត

🟡 បានចេញផ្សាយយឺត ឬមិនត្រូវផ្សព្វផ្សាយតាមអ៊ីនធឺណិត ឬផលិតសម្រាប់តែប្រើប្រាស់ផ្ទៃក្នុង

IBP. (2017a). *សន្ទស្សន៍ថវិកាបើកចំហ* (*Open Budget Index)*

បើទោះបីជាមានវឌ្ឍនភាពជាទូទៅក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទោះជារាជរដ្ឋាភិបាលបានផ្តល់ឱកាសខ្លះៗសម្រាប់សាធារណជន និងអង្គការសង្គមស៊ីវិលចូលរួមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ដោយ ក៏ការចូលរួមរបស់សាធារណជននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមានកម្រិតទាបនៅប្រទេសកម្ពុជា[4]។ ជាក់ស្តែងប្រទេសកម្ពុជាទទួលបានពិន្ទុ៨ លើ១០០ សម្រាប់ការចូលរួមជាសាធារណៈ នៅឆ្នាំ២០១៥ និង៤ នៅឆ្នាំ២០១៧ (IBP, 2015a, IBP, 2017a)។ មិនត្រឹមតែប៉ុណ្ណោះ ទោះបីជាពិន្ទុជាលេខសម្រាប់ការចូលរួមជាសាធារណៈ មិនមាននៅក្នុងការស្ទង់មតិពីមុនៗក៏ដោយ ក៏របាយការណ៍សង្ខេបរបស់ OBS ចាប់តាំងពីឆ្នាំ២០០៨មក បង្ហាញថាឱកាសសម្រាប់ការចូលរួមគឺមានតិចតួច។ ចំណែកការពិនិត្យលើកម្រងសំនួរស្ទង់មតិក៏បង្ហាញដូចគ្នាដែរថាឱកាសសម្រាប់ការចូលរួមមានតិចតួច។ មិនតែប៉ុណ្ណោះ សម្រាប់ប្រទេសកម្ពុជាទិដ្ឋភាពទូទៅនៃកម្រងសំណួរបានបញ្ជាក់ថាការចូលរួមគឺនៅមានកម្រិត ហើយប្រទេសនេះទទួលបានពិន្ទុសូន្យលើស្ទើរគ្រប់សំនួរទាំងអស់ដែលទាក់ទងនឹងការចូលរួមជាសាធារណៈ (IBP, 2008a IBP, 2010a; IBP, 2012a, IBP, 2008d, IBP, 2010d, IBP, 2012d; IBP, 2015d, IBP, 2017d)។ ខណៈដែលលទ្ធផលបានបង្ហាញថាកម្រិតនៃការចូលរួមបានធ្លាក់ចុះពី៨ នៅក្នុងឆ្នាំ២០១៥ មកត្រឹម៤ នៅឆ្នាំ២០១៧ របាយការណ៍ស្រាវជ្រាវនេះចាត់ទុកថាកម្រិតនៃការចូលរួមគ្រាន់តែមានកម្រិតទាប ប៉ុន្តែមិនមែនជាការធ្លាក់ចុះពិន្ទុនោះទេ។ នេះគឺដោយសារថាវិធីសាស្ត្រស្រាវជ្រាវដែលប្រើនៅក្នុងការស្ទង់មតិ OBS ឆ្នាំ២០១៧ ខុសគ្នាឆ្ងាយពីវិធីសាស្ត្រស្រាវជ្រាវដែលប្រើនៅក្នុងឆ្នាំ២០១៥ ដែលក្នុងនោះគោលការណ៍នៃការចូលរួមដែលប្រើនៅក្នុងការស្ទង់មតិ OBS ឆ្នាំ២០១៧ មានលក្ខណៈទូលំទូលាយ និងគ្រប់ជ្រុងជ្រោយជាងការស្ទង់មតិ OBS ឆ្នាំ២០១៥ ឆ្ងាយណាស់ (GIFT, 2018)។ មួយផ្នែកដោយសារហេតុផលវិធីសាស្ត្រថ្មីនេះ ពិន្ទុមធ្យមនៃការចូលរួមនៅកម្រិតសកលបាន

---

[4] ក្នុងន័យនេះមានការកត់សម្គាល់ថា ការចូលរួមគឺជា "បាតុភូត ឬការងារថ្មី" នៅទូទាំងពិភពលោក (Marchessault, nd. , p.2)។

ថយចុះពី២៥ នៅឆ្នាំ២០១៥ មកត្រឹមតែ១២ នៅឆ្នាំ២០១៧។ នេះមានន័យថាពិន្ទុជាមធ្យមសម្រាប់ប្រទេសនីមួយៗរួមទាំងប្រទេសកម្ពុជាផងនោះក៏ធ្លាក់ចុះដែរ។

## ១.៧ គម្រោងនៃរបាយការណ៍ស្រាវជ្រាវ

របាយការណ៍នេះត្រូវបានរៀបចំដូចខាងក្រោម។ ជំពូកទីមួយគឺសេចក្តីផ្តើម។ ជំពូកទីពីរគឺការវិភាគក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការចូលរួមជាទូទៅរបស់សាធារណជន និងការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងក្នុងដំណើរការធ្វើថវិកា។ បន្ទាប់មក ជំពូកនេះបង្ហាញខ្លះៗផងដែរពីការស្រាវជ្រាវដែលមានស្រាប់ស្តីពីការការចូលរួមរបស់សាធារណជនជាក់ស្តែង។ ជំពូកទីបីគឺការពិភាក្សាពីការអនុវត្តល្អៗនិងបញ្ហាប្រឈមធំៗនៅប្រទេសហ្វីលីពីននិងប្រទេសឥណ្ឌូនេស៊ី។ ជំពូកចុងក្រោយនៃរបាយការណ៍នេះផ្តល់នូវអនុសាសន៍មួយចំនួនសម្រាប់ប្រទេសកម្ពុជាក្នុងការពង្រឹងការចូលរួមជាសាធារណៈ ក្នុងកាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី ២: ក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណជននៅប្រទេសកម្ពុជា

ផ្នែកនេះពិនិត្យមើលការចូលរួមរបស់សាធារណជនក្នុងច្បាប់និងគោលនយោបាយស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយអភិវឌ្ឍន៍ធំៗ ដូចជាយុទ្ធសាស្រ្តចតុកោណ ដែលអាណត្តិគោលនយោបាយទាំងនេះអាចគ្របដណ្តប់ការចូលរួមជាសាធារណៈក្នុងការធ្វើថវិកានៅកម្រិតផ្សេងៗគ្នា។ លទ្ធផលនៃការស្រាវជ្រាវគឺមានដូចតទៅនេះ។

**តារាងទី០២: ការចូលរួមរបស់សាធារណជនដូចដែលមានរម្លេចក្នុងច្បាប់ គោលនយោបាយ និងឯកសារពាក់ព័ន្ធផ្សេងៗ**

នៅក្នុងតារាងនេះសញ្ញា √ មានន័យថាច្បាប់ / គោលនយោបាយ / ឯកសារមានលើកឡើងពីការចូលរួមរបស់សាធារណជននៅក្នុងដំណាក់កាលជាក់លាក់ណាមួយនៃដំណើរការថវិកា។ សញ្ញា × បង្ហាញថាមិនមានការចូលរួមរបស់សាធារណជននៅក្នុងដំណាក់កាលជាក់លាក់ណាមួយនៃដំណើរការថវិកានោះទេ។ NA សម្គាល់ថាច្បាប់ / គោលនយោបាយ / ឯកសារមានចែងទាក់ទងនឹងហិរញ្ញវត្ថុសាធារណៈក្នុងរូបភាពទូទៅ ឬទាក់ទងនឹងគោលបំណងរួមនៃការសិក្សានេះ ប៉ុន្តែមិនទាក់ទងដោយផ្ទាល់ទៅនឹងដំណាក់កាលណាមួយនៃការចូលរួមរបស់សាធារណជនដែលការសិក្សានេះផ្តោតការយកចិត្តទុកដាក់នោះទេ។

| ចំណងជើង | ការរៀបចំថវិកា | ការអនុម័តថវិកា | ការតាមដានការអនុវត្ត | ការផ្តល់យោបល់ត្រលប់ទៅធាតុចូលរបស់ប្រជាពលរដ្ឋ | ការត្រួតពិនិត្យ | យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|
| **ថ្នាក់ជាតិ** | | | | | | |
| រដ្ឋធម្មនុញ្ញ (១៩៩៣ និងធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩) | × | × | × | × | × | មានលើកឡើងពីការចូលរួមតែក្នុងរូបភាពទូទៅ។ |
| បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងព្រឹទ្ធសភា (២០១៤) | NA | × | × | × | × | មានបង្កើតវេទិកាមួយចំនួនសម្រាប់ការចូលរួមរបស់សាធារណជន ប៉ុន្តែមិនមាននីតិវិធីលម្អិតទេ។ |
| ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ (២០០៨) | × | × | × | × | × | មិនមានបញ្ញត្តិស្តីពីការចូលរួមរបស់សាធារណជន នៅក្នុងដំណាក់កាលណាមួយនៃដំណាក់កាលទាំងអស់នៃវដ្ត ថវិកា។ |

| | | | | | | |
|---|---|---|---|---|---|---|
| ច្បាប់សវនកម្ម (២០០០) | NA | NA | x | × | × | មិនមានលើកឡើងពីការចូលរួមទេ។ |
| ស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា (២០១១) | NA | NA | √ | × | √ | មានលើកឡើងពីការចូលរួម។ អាជ្ញាធរសវនកម្មជាតិមើលឃើញប្រយោជន៍ដែលបានមកពីការសហការជាមួយវិទ្យាស្ថានស្រាវជ្រាវជាន់ខ្ពស់ និងទំនាក់ទំនងផ្លូវការជាមួយអង្គភាពវិជ្ជាជីវៈដែលជាផ្នែកមួយនៃអង្គការសង្គមស៊ីវិលក្នុងដំណើរការសវនកម្ម។ |
| ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ២០១២) | NA | NA | × | NA | NA | ប្រជាពលរដ្ឋអាចចូលរួមក្នុងអំឡុងពេលបើកការដេញថ្លៃ (មាត្រា ៤៤)។ |
| ច្បាប់ប្រឆាំងនឹងអំពើពុករលួយ (២០១០) | NA | NA | NA | NA | × | ច្បាប់នេះមិនគ្របដណ្តប់លើហិរញ្ញវត្ថុសាធារណៈនោះទេប៉ុន្តែមានបញ្ញត្តិដែលជួយធានាឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រព្រឹត្តិទៅដោយមានដំណើរការល្អ (មាត្រា ២)។ |
| ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន (សេចក្តីព្រាង) | NA | NA | NA | NA | NA | សេចក្តីព្រាងច្បាប់នេះប្រកាន់យកការចូលរួមជាសាធារណៈជាឧបករណ៍មួយដើម្បីលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពសាធារណៈ (មាត្រា ១, ២, ៦)។ |
| យុទ្ធសាស្រ្តចតុកោណ (ដំណាក់កាលទី ១: ឆ្នាំ ២០០៤ ដំណាក់កាលទី ២ ឆ្នាំ ២០០៨ ដំណាក់កាលទី ៣ ឆ្នាំ ២០១៣ ដំណាក់កាលទី ៤ ឆ្នាំ ២០១៨) | NA | NA | NA | NA | NA | ការចូលរួមជាសាធារណៈត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនិងសម្រេចបាននូវការអភិវឌ្ឍប្រកបដោយ សមធម៌។ |
| កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) (២០០៤ & ២០០៨) | NA | NA | NA | NA | NA | ឯកសារ PFMRP (2004): ការចូលរួមត្រូវបានលើកឡើងតែម្តងប៉ុណ្ណោះ។<br>ឯកសារ PFMRP (2008): មិនមានលើកឡើងពីការចូលរួមជាសាធារណៈទេ។ |
| ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP និងការធ្វើបច្ចុប្បន្នភាព: ២០១៤-២០១៨) | NA | NA | NA | NA | NA | ការចូលរួមជាសាធារណៈមិនត្រូវបានលើកឡើងក្នុងផ្នែកស្តីពីហិរញ្ញវត្ថុសាធារណៈទេ។ |
| សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២០០៧) | NA | NA | NA | NA | NA | មិនមានបញ្ជាក់ច្បាស់ទេថាតើតំណាងអង្គការសង្គមស៊ីវិលនិងវិស័យឯកជនអាចគ្រាន់តែធ្វើជាអ្នកសង្កេតការឬអាចលើកពីតម្រូវការឬកង្វល់នានាបាន។ |

| | | | | | |
|---|---|---|---|---|---|
| យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា (២០១៧) (២០១៧-២០២៥) (សេចក្តីព្រាង)[5] | NA | NA | NA | NA | NA | មិនមានលើកឡើងពីការចូលរួមទេ។ |
| **ថ្នាក់ក្រោមជាតិ** | | | | | | |
| ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ (២០០៨) | × | × | × | × | NA | ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងដំណើរការបង្កើតនិងអនុវត្តផែនការអភិវឌ្ឍន៍ (មាត្រា ៣៨)។ ប៉ុន្តែ មិនមានចែងអំពីការចូលរួមជាសាធារណៈក្នុងដំណើរការថវិកាទេ (មាត្រា ២៤៥)។ |
| ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ (២០១១) | × | × | × | × | NA | មានចែងពីការប្រមូលមតិយោបល់ពីសាធារណជនសម្រាប់ដាក់បញ្ចូលក្នុងដំណើរការស្នើររៀបចំកញ្ចប់ថវិកា (មាត្រា ៣៥)។ ក្នុងផ្នែកទី៤ នៃការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានមាត្រាចំនួន ៩ (៣៧-៤៦) ប៉ុន្តែមិនមានការលើកឡើងពីការចូលរួមជាសាធារណៈទេ។ |
| កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) (២០១០) | NA | NA | NA | NA | NA | ការចូលរួមជាសាធារណៈគឺជាចំណុចសំខាន់នៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គោលបំណងនៃកម្មវិធីនិងឧបសម្ព័ន្ធទី៣) |
| ផែនការអនុវត្តបីឆ្នាំរំកិល (IP3) (ដំណាក់កាលទី I, II, និង III នៃ NP-SNDD)<br><br>ឯកសារចុងក្រោយបង្អស់: IP3 III: ២០១៨- ២០២០ | NA | NA | NA | NA | NA | ការចូលរួមរបស់ប្រជាពលរដ្ឋនិង សង្គមស៊ីវិលគឺជាចំណុចស្នូលរបស់ផែនការអនុវត្តបីឆ្នាំរំកិល ក្នុងដំណាក់កាលទី១ ទី២ និងទី៣។ |
| ក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ (២០០៥) | NA | NA | NA | NA | NA | ការចូលរួមជាសាធារណៈគឺជាចំណុចស្នូលនៅក្នុងក្របខ័ណ្ឌនេះ។ |
| ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌ (២០១២) | NA | NA | NA | NA | NA | ការចូលរួមជាសាធារណៈត្រូវបានយកមកពិចារណានៅក្នុងសកម្មភាពទូទៅរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ |
| អនុក្រឹត្យស្តីពីតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាល (២០០៩) | NA | NA | NA | NA | NA | ការចូលរួមជាសាធារណៈត្រូវបានយកមកពិចារណា (មាត្រា ៩, ៦៥, ១២១, ៥០, ១០៧ និង ១៦៨)។ |

[5] ក្របខ័ណ្ឌលទ្ធផល (Results Framework) របស់សហគមន៍អឺរ៉ុប (២០១៩) ដែលជាកិច្ចព្រមព្រៀងរវាងក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយសហភាពអឺរ៉ុបស្តីពីគម្រោងគាំទ្រដោយសហភាពអឺរ៉ុបមិនមានលើកឡើងពីការចូលរួមជា សាធារណៈនោះទេ។ វាផ្តោតសំខាន់លើការបញ្ចេញឯកសារ គណនេយ្យភាព និងតម្លាភាព។

| | | | | | | |
|---|---|---|---|---|---|---|
| អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុងនិងស្រុក (២០១២) | √ | √ | √ | × | NA | ការចូលរួមជាសាធារណៈត្រូវបានលើកឡើងនៅក្នុងដំណាក់កាលរៀបចំថវិកា (មាត្រា ១៥,១៦) និងដំណើរការអនុវត្ត (មាត្រា ៥៩)។ |
| សេចក្តីណែនាំស្តីពីការរៀបចំការអនុម័តនិងការអនុវត្តមូលនិធិស្រុក / ក្រុង (២០១៣) | √ | √ | × | × | NA | ការចូលរួមជាសាធារណៈកើតឡើងក្នុងអំឡុងការរៀបចំថវិកានិងការអនុម័តថវិកា (ផ្នែក ខ.៥, ខ.៧) ប៉ុន្តែគ្មានការចូលរួមជាសាធារណៈក្នុងពេលអនុវត្តថវិកាទេ។ |
| ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ (២០០១) | × | × | × | × | NA | ច្បាប់នេះតម្រូវឱ្យមានការចូលរួមជាសាធារណៈក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ប៉ុន្តែមិនមានលើកឡើងពីការចូលរួមក្នុងពេលរៀបចំថវិកា ការអនុម័ត និងការអនុវត្តទេ។ |
| អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ / សង្កាត់ (២០០២) | √ | √ | √ | × | NA | ការចូលរួមជាសាធារណៈត្រូវបានលើកឡើងក្នុងការរៀបចំថវិកា (មាត្រា ១១, ១២, ១៣) និងការអនុវត្តថវិកា (មាត្រា ២៩, ៥៩)។ |
| អនុក្រឹត្យស្តីពីមូលនិធិឃុំ / សង្កាត់ (២០០២) | √ | √ | √ | × | NA | ការចូលរួមត្រូវបានត្រូវបានលើកឡើងក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា(មាត្រា ១៧) ។ |
| សេចក្តីប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងការអនុវត្តថវិកាឃុំសង្កាត់ (២០០២) | √ | √ | × | × | NA | ការចូលរួមជាសាធារណៈត្រូវបានបញ្ជាបដំណើរការធ្វើថវិកានិងអនុម័តថវិកា (ផ្នែកទី២, ទី៣, ទី៤) ប៉ុន្តែមិនមានក្នុងអំឡុងពេលអនុវត្តទេ។ |
| ប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធី<br>វិនិយោគ៣ឆ្នាំរំកិលថ្នាក់ឃុំ (២០១៦) | NA | NA | NA | NA | NA | ការចូលរួមត្រូវបានត្រូវបានលើកឡើងក្នុងដំណាក់កាលការរៀបចំថវិកានៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ឃុំ |
| ប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធី<br>វិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ស្រុក (២០១៦) | NA | NA | NA | NA | NA | ការចូលរួមត្រូវបានលើកឡើងក្នុងដំណាក់កាលនៃការរៀបចំ ថវិកានៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ស្រុក។ |
| ប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធី<br>វិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ខេត្ត (២០១៦) | NA | NA | NA | NA | NA | ការចូលរួមត្រូវបានលើកឡើងក្នុងដំណាក់កាលនៃការរៀបចំ ថវិកានៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ខេត្ត។ |
| អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគទុនថ្នាក់ក្រោមជាតិ (២០១៦) | × | × | √ | × | NA | ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារៀងៗខ្លួនមានសិទ្ធិពេញលេញក្នុងការឃ្លាំមើលការអនុវត្តគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មាត្រា ៣៥)។ |

| | | | | | | |
|---|---|---|---|---|---|---|
| សេចក្តីសម្រេចស្តីពីការអនុវត្ត គោលការណ៍ណែនាំស្តីពីការវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំរបស់រដ្ឋបាលស្រុក (២០១៧) | √ | √ | × | × | NA | ការចូលរួមរបស់សាធារណជនក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ និងកម្មវិធីវិនិយោគស្រុកគឺជាលក្ខណវិនិច្ឆ័យមួយសម្រាប់ការវាយតម្លៃការអនុវត្តរបស់ រដ្ឋបាលស្រុក។ |

## ២.១ ថ្នាក់ជាតិ

<u>ក្របខ័ណ្ឌច្បាប់និងគោលនយោបាយទូទៅ</u>: ដូចដែលបានបង្ហាញនៅក្នុងតារាងទី០២ខាងលើ ច្បាប់និងគោលនយោបាយស្នូលរបស់ប្រទេសកម្ពុជាមានដាក់បញ្ចូលការចូលរួមរបស់សាធារណជន ក្នុងការគ្រប់គ្រងកិច្ចការរដ្ឋខ្លះៗតែមិនគ្រប់ជ្រុងជ្រោយទេ។ មាត្រាទី៣៥ និងទី៥១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ប្រជាពលរដ្ឋខ្មែរគឺជាម្ចាស់ប្រទេស ហើយអាចអនុវត្តសិទ្ធិពេញលេញក្នុងការចូលរួមការងារនយោបាយ សេដ្ឋកិច្ច និងសង្គម។ ដូច្នេះស្ថាប័នរដ្ឋត្រូវយកចិត្តទុកដាក់ ពិចារណា និងដោះស្រាយរាល់ការព្រួយបារម្ភនិងសំណូមពររបស់ប្រជាពលរដ្ឋខ្មែរយ៉ាងយកចិត្តជាទីបំផុត។ ទោះជាយ៉ាងណាក៏ដោយរដ្ឋធម្មនុញ្ញមានចែងច្បាស់លាស់តែអំពីការចូលរួមរបស់សាធារណជនជាទូទៅ តែមិនមានចែងអំពីការចូលរួមទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងការងារថវិកានោះទេ។

សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបាន ព័ត៌មានមានចែងច្បាស់លាស់អំពីការចូលរួមរបស់សាធារណជននិងការទទួលបានព័ត៌មានអំពីរដ្ឋាភិបាល ប៉ុន្តែសេចក្តីព្រាងច្បាប់នេះនៅមិនទាន់ត្រូវបានអនុម័តនៅឡើយទេ។ ដោយមានការគាំទ្រពីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត (Sida) តាមរយៈអង្គការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកវិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (ហៅកាត់ថា យូណេស្កូ) ក្រុមការងារបច្ចេកទេស (TWG) មួយដែលមានអង្គការយូណេស្កូនិងក្រសួងព័ត៌មានជាសហប្រធាន បានទទួលភារកិច្ចរៀបចំសេចក្តីព្រាងច្បាប់នេះ។ នៅឆ្នាំ២០១៨ សេចក្តីព្រាងច្បាប់នេះបានបញ្ចប់រួចរាល់ហើយនៅត្រឹមកម្រិតក្រុមការងារបច្ចេកទេស ហើយវាត្រូវបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីឆ្លងនីតិវិធីច្បាប់បន្ត។ សេចក្តីព្រាងច្បាប់នេះមានមាត្រាចំនួនបីដែលទាក់ទងច្រើនទៅនឹងការចូលរួមរបស់សាធារណជន។ មាត្រាទី១ ចែងថា "គោលបំណងនៃច្បាប់នេះគឺដើម្បីធានាសិទ្ធិសេរីភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន"។ គោលបំណងរបស់សេចក្តីព្រាងច្បាប់នេះមានចែងក្នុងមាត្រាទី២គឺ "ដើម្បីធានាឱ្យមានការចូលរួមរបស់សាធារណជនក្នុងកិច្ចការនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសដូចមានចែងក្នុងមាត្រាទី ៣៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងលើកទឹកចិត្តដល់ស្ថាប័នសាធារណៈឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយ គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។" ស្របតាមគោលការណ៍សកលផងដែរ មាត្រាទី៦ក្នុងសេចក្តីព្រាងច្បាប់នេះលើកទឹកចិត្ត "ស្ថាប័នសាធារណៈទាំងអស់ ឱ្យគោរពតាមគោលការណ៍នៃការបញ្ចេញព័ត៌មានជាអតិបរិមា។"

យុទ្ធសាស្ត្រចតុកោណ (RS) គឺជាឯកសារគោលនយោបាយនាំមុខគេ ពីព្រោះឯកសារនេះផ្តល់ទិសដៅសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២៣។ យុទ្ធសាស្ត្រចតុកោណ បង្ហាញថាការចូលរួមយ៉ាងទូលំទូលាយគឺជាឧបករណ៍ដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជំរុញអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ប្រកបដោយសមធម៌។ ជាឧទាហរណ៍ ក្នុងក្របខ័ណ្ឌនេះ យុទ្ធសាស្ត្រដ៏ចម្បងមួយក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈគឺការលើកទឹកចិត្តឱ្យមាន "ការចូលរួមរបស់ប្រជាជនក្នុងដំណើរការអភិវឌ្ឍក៏ដូចជាក្នុងការរៀបចំ និងអនុវត្តគោលនយោបាយនានា"។ យុទ្ធសាស្ត្រនេះក៏ប្តេជ្ញាផងដែរក្នុងការពង្រឹងនិងពង្រីកការបញ្ចេញជាសាធារណៈនូវព័ត៌មានថ្មីៗស្តីពីសេវាសាធារណៈ ឯកសារច្បាប់ និងឯកសារគោលនយោបាយជាតិ ដោយលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការរៀបចំនិងអនុវត្តគោលនយោបាយផ្សេងៗ ជំរុញឱ្យមានយន្តការសម្រាប់ទទួលយកមតិយោបល់និងដោះស្រាយពាក្យបណ្តឹង ដែលក្នុងនោះអាចមាន លទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍តាមបែបព័ត៌មានវិទ្យា (ICT) ដើម្បីគាំទ្រការអនុវត្តបែបនេះ និងពង្រឹងប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យនិងសវនកម្ម (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨, ទំព័រទី១៣) ។ យ៉ាងណាក៏ដោយយុទ្ធសាស្ត្រចតុកោណ (RS) មិនមានលើកឡើងពីការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះទេ។

ចំណែកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ NSDP 2014-2018 បានបង្ហាញពីការចូលរួមជាសាធារណៈយ៉ាងទូលំទូលាយនៅគ្រប់ផ្នែក រាប់បញ្ចូលទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនិងការជំរុញការអភិវឌ្ឍជនបទ ប៉ុន្តែផែនការយុទ្ធសាស្ត្រនេះ មិនមានលើកពីការចូលរួមជាសាធារណៈនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈទេ។ ជាទូទៅនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការចូលរួមត្រូវបានលើកទឹកចិត្តក្នុង "ទិដ្ឋភាពបច្ចេកទេស" ប៉ុន្តែមិនទាក់ទងទៅនឹងការធ្វើថវិកានៃកម្មវិធីវិនិយោគទេ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2019-2023 មិនទាន់ត្រូវបានអនុម័តនៅឡើយនៅអំឡុងពេលសរសេររបាយការណ៍នេះ។

<u>ក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងការធ្វើថវិកា</u>: ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (១៩៩៨ និងធ្វើវិសោធនកម្មនៅឆ្នាំ២០០៨) និងច្បាប់ស្តីពីសវនកម្ម (២០០០) ដែលជាច្បាប់ធំៗពីរសម្រាប់គ្រប់គ្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនមានចែងច្បាស់លាស់អំពីការចូលរួមជា សាធារណៈពីសំណាក់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងដំណើរការហិរញ្ញវត្ថុនិងថវិកាទេ។ ជាក់ស្តែងច្បាប់ទាំងនេះមិនបានបញ្ចូលការចូលរួមរបស់សាធារណជនក្នុងដំណាក់កាលណាមួយទាំងអស់នៃវដ្តថវិកា (ការរៀបចំ ការអនុម័ត ការអនុវត្ត និងការត្រួតពិនិត្យ)។ ស្តង់ដារសវនកម្មសាធារណៈ (ឆ្នាំ២០១១) ដែលចែងពីការអនុវត្តសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិអនុញ្ញាតឱ្យអាជ្ញាធរនេះសហការជាមួយវិទ្យាស្ថានស្រាវជ្រាវជាន់ខ្ពស់ និងទាក់ទងជាផ្លូវការជាមួយអង្គភាពវិជ្ជាជីវៈដែលជាផ្នែកមួយនៃអង្គការសង្គមស៊ីវិលក្នុងដំណើរការ សវនកម្ម។ ក្រៅពីនេះស្ទើរតែគ្មានយន្តការ ឬឧបករណ៍គោលនយោបាយអចិន្ត្រៃយ៍ណាមួយដែលបង្កើតឡើងសម្រាប់ ឬ

ដោយអាជ្ញាធរសវនកម្មជាតិដើម្បីឱ្យប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលអាចដាក់ពាក្យបណ្ដឹង ផ្ដល់ធាតុចូលសម្រាប់កម្មវិធីសវនកម្ម និងការស៊ើបអង្កេតរបស់ខ្លួន និងផ្ដល់មតិយោបល់ត្រលប់សម្រាប់ធាតុចូលរបស់ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលនោះទេ។ ចំណែកច្បាប់ស្ដីពីលទ្ធកម្មសាធារណៈវិញមានតែមួយមាត្រាប៉ុណ្ណោះ (មាត្រា ៨៤) ដែលទាក់ទងនឹងការចូលរួមរបស់ភាគីពាក់ព័ន្ធៈ "ការដេញថ្លៃដែលបានដាក់ស្នើទាំងអស់នឹងត្រូវបើកជាសាធារណៈនិងភ្លាមៗបន្ទាប់ពីផុតថ្ងៃកំណត់។" ចំណែក"កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) (ឆ្នាំ២០០៤) បានលើកឡើងបន្តិចបន្តួច (ម្ដងគត់) ពីការចូលរួមរបស់អង្គការសង្គមស៊ីវិល ដោយលើកឡើងថាការចូលរួមរបស់ពួកគេគឺជាការចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងរួមរបស់កម្មវិធីនេះ។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ មិនមានចែងអំពីការចូលរួមជាសាធារណៈឡើយ។ លើសពីនេះទៀតសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឆ្នាំ២០០៧) ផ្ដល់ឱកាសឱ្យអង្គការសង្គមស៊ីវិលចូលរួមជាសមាជិក ឬអ្នកសង្កេតការណ៍។ សេចក្ដីព្រាងយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាចុងក្រោយបំផុត (២០១៧-២០២៥) ដែលនឹងផ្ដល់ទិសដៅសម្រាប់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលចុងក្រោយ មិនមានបញ្ញត្តិស្ដីពីការចូលរួមជាសាធារណៈឡើយ។ នេះគឺដោយសារដំណាក់កាលបន្ទាប់នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ នឹងផ្ដោតជាចំបងលើការទទួលខុសត្រូវសង្គមនិងថវិកាផ្អែកលើសមិទ្ធិកម្មការងារ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភាដែលចេញនៅឆ្នាំ២០១៤ មានរៀបរាប់លម្អិតអំពីនីតិវិធី និងប្រតិបត្តិការរបស់ស្ថាប័ននេះ។ ក្នុងចំណោមចំណុចផ្សេងៗទៀត បទបញ្ជានេះចែងអំពីការពិភាក្សាលើសេចក្ដីព្រាងច្បាប់និងសំណើច្បាប់ របៀបវារៈការប្រជុំ បទបញ្ជាពិសេសស្ដីពីថវិកាជាតិ និងថវិកាសម្រាប់រដ្ឋសភា ការស៊ើបអង្កេត និងការឆ្លើយតបពីរាជរដ្ឋាភិបាល ការបញ្ចេញមតិយោបល់ និងវិធានស្ដីពីការជជែកវែកញែក។ បទបញ្ជាផ្ទៃក្នុងនេះមិនមានបទបញ្ញត្តិស្ដីពីនីតិវិធីលម្អិតសម្រាប់ការចូលរួមជាទូទៅរបស់សាធារណជន និងទាក់ទងទៅនឹងសវនាការស្ដីពីសំណើថវិកាជាតិ ការអនុវត្តនិងការត្រួតពិនិត្យ សវនាការទាន់ទងនឹងសវនកម្ម និងយន្តការស្ដីពីការផ្ដល់យោបល់ត្រលប់ទៅមតិយោបល់របស់សាធារណជនទេ (រដ្ឋសភា, ២០១៤a)។ មានបញ្ញត្តិទូទៅមួយចំនួនស្ដីពីការចូលរួមរបស់សាធារណជន។ ជាឧទាហរណ៍ ប្រការទី៧ ផ្ដល់ភារកិច្ចដល់គណៈកម្មការអចិន្ត្រៃយ៍ "ដើម្បីពិនិត្យឡើងវិញនិងដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋដោយយកចិត្តទុកដាក់និងច្បាស់លាស់" ។ ប្រការទី១២ អនុញ្ញាតិឱ្យគណៈកម្មាធិការនីមួយៗ ស្នើរសុំប្រធានរដ្ឋសភាតែងតាំងអ្នកជំនាញដែលមិនមែនជាសមាជិករដ្ឋសភាមកធ្វើការក្នុងគណៈកម្មការរបស់ខ្លួន។ អ្នកជំនាញមិនមានសិទ្ធិសម្រេចចិត្តក្នុងកិច្ចការរបស់ គណៈកម្មការនោះទេ។" លេខាធិការដ្ឋាននៃរដ្ឋសភាមានភារកិច្ចថែរក្សា "កំណត់ហេតុប្រជុំនិងឯកសារដទៃទៀត" ហើយពេលមានការស្នើសុំ លេខាធិការដ្ឋានអាចផ្ដល់ជូនដល់ "សាធារណជននិងតំណាងរាស្ត្រនូវកំណត់ហេតុប្រជុំនិងឯកសារទាំងនេះ តែត្រូវមានការយល់ព្រមពីប្រធានសភាជាមុន។" ប្រការទី៤៧ ចែងថា "កិច្ចប្រជុំរដ្ឋសភាត្រូវធ្វើឡើងជាសាធារណៈ។" ប្រការទី៦៤ចែងថា "ជាគោលការណ៍ប្រធានរដ្ឋសភាអាចអនុញ្ញាតឱ្យសាធារណជនចូលរួមកិច្ចប្រជុំនៅក្នុងសាលប្រជុំឱ្យតែមានកៅអីទំនេរ"។ ជាទូទៅមានបញ្ញត្តិតែមួយចំនួនប៉ុណ្ណោះ និងមិនមាននីតិវិធីលម្អិត

ទាក់ទងនឹងលទ្ធភាពទទួលបានព័ត៌មាន ការចូលរួមក្នុងកិច្ចការរបស់រដ្ឋសភា និងការចូលរួមរបស់សាធារណជនក្នុងសវនាការជាសាធារណៈ។

សេចក្តីសម្រេចស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការទី២ស្តីពីសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម របស់រដ្ឋសភា (រដ្ឋសភា ឆ្នាំ២០១៤) ក៏មានចែងអំពីការចូលរួមរបស់សាធារណជនផងដែរ។ សេចក្តីសម្រេចនេះបង្ហាញថាគណៈកម្មការនេះ "អាចចូលរួមនិងរៀបចំសិក្ខាសាលាសាធារណៈ ឬកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គការជាតិនិងអន្តរជាតិ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត"។ គណៈកម្មការនេះក៏អាចសហការជាមួយអង្គការនិងក្រុមដែលពាក់ព័ន្ធដូចជាដៃគូជាតិនិងអន្តរជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន។ គណៈកម្មការនេះអាចជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីសាធារណជននៅក្នុងវេទិកាផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ គណៈកម្មការនេះទទួលភារកិច្ចពិនិត្យសំណូមពរនិងយោបល់ផ្សេងៗពីសាធារណជនដើម្បីបញ្ជូនទៅក្រសួងពាក់ព័ន្ធឱ្យពិចារណានិងដោះស្រាយតាមរយៈសំណើរបស់ប្រធានរដ្ឋសភា។ សេចក្តីសម្រេចនេះ ដូចគ្នានឹងបទបញ្ជាផ្ទៃក្នុងរដ្ឋសភាដែរ ខ្វះនីតិវិធីលម្អិតទាក់ទងនឹងការចូលរួមរបស់សាធារណជន និងមិនមានលើកពីការផ្តល់យោបល់ត្រលប់ទៅមតិយោបល់របស់សាធារណជននោះទេ។

ព្រឹទ្ធសភា (២០១៤) ក៏មានបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដែរ ហើយបទបញ្ជានេះមានចែងពីបញ្ហាសំខាន់ៗ ដូចបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាដែរ។ បទបញ្ជានេះមិនមាននីតិវិធីលម្អិតសម្រាប់ការចូលរួមរបស់សាធារណជនក្នុងសវនាការរបស់ព្រឹទ្ធសភាទេ និងមានចែងតិចតួចពីការចូលរួមរបស់សាធារណជន ប៉ុន្តែមិនមានចែងពីការផ្តល់ព័ត៌មានជូនសាធារណជននិងពីការផ្តល់យោបល់ត្រលប់ទៅមតិយោបល់របស់សាធារណជនទេ។ មានប្រការចំនួន៣ ស្តីពីការចូលរួមដូចខាងក្រោម។ ប្រការទី១៨ អនុញ្ញាតឱ្យគណៈកម្មការនីមួយៗ "អញ្ជើញអ្នកតំណាង រដ្ឋាភិបាល ឥស្សរជន អ្នកជំនាញ ឬអ្នកតំណាងសង្គមស៊ីវិលដើម្បីផ្តល់យោបល់លើបញ្ហាផ្សេងៗ។" ដូចគ្នានឹងគណៈកម្មការរដ្ឋសភាដែរ គណៈកម្មការរបស់ព្រឹទ្ធសភាអាចស្នើសុំតែងតាំងអ្នកជំនាញដើម្បីជួយការងាររបស់ខ្លួន។ ប្រការទី៤២ ចែងថា "កិច្ចប្រជុំរបស់ព្រឹទ្ធសភា [លើកលែងតែការប្រជុំជាសម្ងាត់] ត្រូវធ្វើឡើងជាសាធារណៈនិងផ្សាយតាមវិទ្យុនិងទូរទស្សន៍ជាតិ"។ ការដែលមានឱកាសតិចតួចសម្រាប់ការចូលរួមរបស់សាធារណជននៅក្នុងកិច្ចការនិងកិច្ចប្រជុំរបស់រដ្ឋសភានិងព្រឹទ្ធសភាត្រូវបានបញ្ជាក់តាមរយៈកម្រងសំនួរនៃការស្ទង់មតិ OBI ដែលបង្ហាញថាមិនមានយន្តការសម្រាប់ការចូលរួមក្នុងការពិគ្រោះយោបល់លើសំណើថវិកាប្រចាំឆ្នាំនិងបញ្ហាទាក់ទងនឹងហិរញ្ញវត្ថុផ្សេងទៀតដែលធ្វើឡើងដោយរដ្ឋសភានិងព្រឹទ្ធសភានោះទេ។

ជាទូទៅនៅថ្នាក់ជាតិការចូលរួមរបស់សាធារណជន ដូចដែលមានចែងក្នុងច្បាប់នានា បទបញ្ញានិងគោលនយោបាយអភិវឌ្ឍន៍ធំៗ ត្រូវបានចាត់ទុកថាជាឧបករណ៍មួយដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនិងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងនយោបាយប្រកបដោយសមធម៌។ ប៉ុន្តែសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

និងការធ្វើថវិកា ច្បាប់និងក្របខ័ណ្ឌគោលនយោបាយដែលពាក់ព័ន្ធបានផ្តល់ឱកាសតិចតួចនិងមានចែងមិនច្បាស់ លាស់ អំពីការចូលរួមរបស់សាធារណជន។ នេះបង្ហាញថាឱកាសសម្រាប់ការចូលរួមរបស់សាធារណជនដែលផ្តល់ដោយអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និង អាជ្ញាធរសវនកម្មជាតិគឺមានលក្ខណៈស្តួចស្តើងណាស់។

## ២.១ ថ្នាក់ក្រោមជាតិ

នៅថ្នាក់ក្រោមជាតិ ការចូលរួមរបស់សាធារណជនមានលក្ខណៈលេចធ្លោជាងនៅថ្នាក់ជាតិ ទាំងក្នុងសកម្មភាពទូទៅ និងការធ្វើថវិកា បើទោះបីជានៅមានកង្វះខាតក៏ដោយ។ មន្ត្រីរាជរដ្ឋាភិបាល អ្នកជំនាញនិង អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅឬជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិយល់ស្របគ្នាថាច្បាប់និងគោលនយោបាយថ្នាក់ក្រោមជាតិត្រូវបាន "បង្កើតឡើងដើម្បីឱ្យមានការចូលរួម"[6]។

<u>ក្របខ័ណ្ឌច្បាប់និងគោលនយោបាយទូទៅ</u>: ច្បាប់និងគោលនយោបាយនៅថ្នាក់ក្រោមជាតិមានបទបញ្ញត្តិលេចធ្លោ និងមានយន្តការផ្សេងៗក្នុងការសម្រួលដល់ការចូលរួមរបស់សាធារណជនដូចខាងក្រោម។ ទី១ ច្បាប់និងក្របខ័ណ្ឌគោលនយោបាយទាំងនោះតម្រូវឱ្យមានចូលរួមរបស់សាធារណជនក្នុងដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍និងវិនិយោគ។ នេះមានន័យថាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ និយាយម្យ៉ាងទៀតគឺថាប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ដើម្បីចូលរួមការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍន៍ ហើយសំខាន់ជាងនេះទៅទៀតក្នុងការត្រួតពិនិត្យការអនុវត្តការងាររបស់ក្រុមប្រឹក្សា។ គោលនយោបាយដែលមានបញ្ចូលការចូលរួមរបស់សាធារណជន ច្រើនគួរឱ្យកត់សម្គាល់មានដូចជាកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ផែនការអនុវត្តបីឆ្នាំរំកិល (IP3) ដែលជាឧបករណ៍សម្រាប់អនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលការណ៍ណែនាំស្តីពីការរៀបចំនិងការបង្កើតកម្មវិធី វិនិយោគថ្នាក់ឃុំ (CIP) , កម្មវិធីវិនិយោគស្រុក (DIP) និងកម្មវិធីវិនិយោគខេត្ត (PIP) (សូមមើលព័ត៌មានលម្អិតនៅក្នុងតារាងទី០២)។

ទីពីរ វិធានការជាក់លាក់ជាច្រើនត្រូវបានបង្កើតឡើងដើម្បីឱ្យមានការចូលរួមរបស់សាធារណជន ជាឧទាហរណ៍ នៅក្នុងឧបសម្ព័ន្ធទី៣នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NP-SNDD) មានបង្ហាញពីយន្តការមួយចំនួនដើម្បីឱ្យមានការចូលរួមពីប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលនៅក្នុងការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ វិធានការលម្អិតផ្សេងទៀតសម្រាប់ការចូលរួមរបស់សាធារណ

[6] បទសម្ភាសន៍ទី ០៨, ជាមួយអង្គការមិនមែនរដ្ឋាភិបាល, ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩; បទសម្ភាសន៍ទី១១, ជាមួយដៃគូរអភិវឌ្ឍន៍, ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១៩។

ជនមានដូចជាការចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដែលក្នុងនោះប្រជាពលរដ្ឋ ក្រុមជនងាយរងគ្រោះ និង សមាជិក
គណបក្សនយោបាយនានាអាចសួរសំណួរ ផ្តល់យោបល់ទៅកាន់ការងាររបស់ក្រុមប្រឹក្សា លើកឡើងនូវកង្វល់និង បញ្ហានានា និងធ្វើការទាមទារផ្សេងៗទៅកាន់ក្រុមប្រឹក្សាទាំងនោះ ហើយថែមទាំងអាចទាក់ទង និងធ្វើការដោយ ផ្ទាល់ជាមួយក្រុមប្រឹក្សានិងគណៈអភិបាលថ្នាក់ក្រោមជាតិទាំងនោះផងដែរ។

<u>ក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការធ្វើថវិកា</u>: ទោះបីជាច្បាប់និងគោលនយោបាយថ្នាក់ក្រោមជាតិទាំងអស់មិនស៊ីសង្វាក់គ្នាពេញលេញ នឹងបទប្បញ្ញត្តិរបស់ខ្លួនទាក់ទងនឹងការចូលរួមរបស់សាធារណជនក្នុងដំណើរការថវិកាក៏ដោយ ក៏ច្បាប់និងគោលនយោបាយទាំងនោះមួយចំនួនបានបញ្ជ្រាបការចូលរួមរបស់សាធារណជនយ៉ាងច្បាស់លាស់ក្នុងការរៀបចំ អនុម័ត និងអនុវត្តថវិកា។ ជាឧទាហរណ៍អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ / សង្កាត់ អនុក្រឹត្យស្តីពីមូលនិធិឃុំសង្កាត់ និងអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង និងស្រុកមានបញ្ញត្តិដូចរៀបរាប់ខាងលើ (សូមមើលតារាងទី២ សម្រាប់ព័ត៌មានលម្អិត)។ បញ្ហានៅមានត្រង់ថា ក្របខ័ណ្ឌច្បាប់ទាំងនោះគ្មានបទប្បញ្ញត្តិទាក់ទងនឹងការផ្តល់យោបល់ត្រលប់ពីក្រុមប្រឹក្សាថ្នាក់ក្រោមជាតិទៅលើ ធាតុចូលពីប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល។ និយាយម្យ៉ាងទៀតគឺពុំទាន់មានយន្តការណាមួយដែលអាចឱ្យ សាធារណជនបានដឹងថាតើធាតុចូលរបស់ពួកគេត្រូវរាជរដ្ឋាភិបាលប្រើប្រាស់សម្រាប់ការរៀបចំថវិកា តាមដាន និងសវនកម្មដោយរបៀបណានោះទេ។

<u>ការអនុវត្តការចូលរួមរបស់សាធារណជននៅថ្នាក់ក្រោមជាតិជាក់ស្តែង:</u> ខណៈដែលច្បាប់ និងគោល នយោបាយមានបំណងធ្វើឱ្យការអនុវត្តការចូលរួមរបស់សាធារណជនមានលក្ខណៈស្របច្បាប់ និងជាប្រព័ន្ធនៅ ក្នុងការអភិវឌ្ឍមូលដ្ឋាន និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ ក្រោមជាតិនោះ ការអនុវត្តជាក់ស្តែង នៅមានការខ្វះខាតនិងខុសគ្នាយ៉ាងខ្លាំងពីតំបន់មួយទៅតំបន់មួយ និងពី
បរិបទមួយទៅបរិបទមួយ។

**ការចូលរួមទូទៅ:** ការចូលរួមទូទៅរបស់សាធារណជននៅក្នុងសកម្មភាពស៊ីវិល ការអភិវឌ្ឍ និង នយោបាយនៅថ្នាក់ក្រោមជាតិគឺនៅមិនទាន់ធ្វើឡើងដោយស្មើគ្នានោះទេ។ បើទោះបីជានៅមិនទាន់មានការឯក ភាពគ្នានៅឡើយក្នុងចំណោមការសិក្សាពាក់ព័ន្ធអំពីបរិមាណនៃការចូលរួមរបស់សាធារណជន ក៏ការសិក្សាខ្លះ បានបង្ហាញថាមានប្រជាពលរដ្ឋនៅមូលដ្ឋានមួយចំនួនបានចូលរួមក្នុងកិច្ចប្រជុំភូមិ និងឃុំ / សង្កាត់។ ជា ឧទាហរណ៍ ក្នុងការស្ទង់មតិមួយជាមួយប្រជាជនចំនួន ២.១២១នាក់នៅខេត្តចំនួនបី គឺខេត្តបាត់ដំបង កំពង់ឆ្នាំង និងពោធិ៍សាត់បានបង្ហាញថាប្រជាពលរដ្ឋចំនួន ៧៤% បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់មូលដ្ឋាននៅឆ្នាំ២០១០ (Kang and Liv 2011)។ លើសពីនេះទៀតមានភស្តុតាងដែលបង្ហាញពីកិច្ចប្រជុំជាទៀងទាត់រវាងក្រុមការងារ

បច្ចេកទេសថ្នាក់ខេត្តលើវិស័យអប់រំ (PTWGE) និងអង្គការមិនមែនរដ្ឋាភិបាលខេត្តនៅខេត្តបាត់ដំបងនិងខេត្តកំពង់ចាមផងដែរ។

ចំពោះគុណភាពនៃការចូលរួមរបស់សាធារណជនវិញ អត្ថបទស្រាវជ្រាវយ៉ាងច្រើនបង្ហាញថាការចូលរួមនៅមានគុណភាពទាបណាស់។ ការសិក្សាទាំងនោះបានរកឃើញថាប្រជាពលរដ្ឋជាច្រើនចូលរួមប្រជុំនៅមូលដ្ឋានតែមិននិយាយ ឬចូលរួមប្រជុំដើម្បីទទួលទានអាហារសម្រន់ និងទទួលអំណោយ ឬក៏ថាមេភូមិនិងមេឃុំប្រើអំណាចគ្របដណ្តប់ការពិភាក្សា ហើយបើកឱកាសតិចតួចឱ្យប្រជាពលរដ្ឋរួមចំណែកផ្តល់យោបល់និងធាតុចូល (Heng, Kim, & So, 2011; Kang & Liv, 2011; Plummer & Tritt, 2012; Thon, Ou, Eng, & Ly, 2009)។ ការសិក្សាដទៃទៀតបង្ហាញថាការចូលរួមទូទៅរបស់ប្រជាពលរដ្ឋមានកម្រិតខ្ពស់នៅពេលចាប់ផ្តើមនៃ កំណែទម្រង់វិមជ្ឈការ (ពីឆ្នាំ២០០២) ប៉ុន្តែសន្ទុះនៃការចូលរួមបានធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ។ មូលហេតុមួយគឺដោយសារតែអាជ្ញាធរមូលដ្ឋានមិនមានធនធានគ្រប់គ្រាន់ដើម្បីរក្សាកិច្ចសន្យារបស់ខ្លួន (ដូចជាការសន្យាសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន) និងមានអំណាចតិចតួចក្នុងការដោះស្រាយជម្លោះ (ដូចជាបញ្ហាដីធ្លីនិងធនធានធម្មជាតិ) (Kim & Öjendal, 2007)។ ការចុះសម្ភាសន៍របស់ក្រុមអ្នកស្រាវជ្រាវនៅក្នុងឃុំមួយក្នុងខេត្តកណ្តាលបានបញ្ជាក់ថាគុណភាពនៃការចូលរួមពិតជានៅទាបដូចការសិក្សាខាងលើបានរកឃើញមែន។ គួរកត់សម្គាល់ថាគុណភាពទាបនៃការចូលរួមរបស់សាធារណជនគឺមួយផ្នែកធំបណ្តាលមកពីកំណែទម្រង់លទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ ប៉ុន្តែក៏អាចមានកត្តារួមចំណែកដទៃទៀតផងដែរ ដែលធ្វើឱ្យការចូលរួមរបស់សាធារណជននៅទន់ខ្សោយ។ កត្តាទាំងនោះមានដូចជាជីវភាពក្រីក្រនៃប្រជាជននៅតាមជនបទ ការជាប់ជំពាក់បំណុលច្រើនរបស់ប្រជាជននៅមូលដ្ឋាន ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដែលជាមធ្យោបាយថ្មីសម្រាប់ការចូលរួមជាសាធារណៈ ការធ្វើចំណាកស្រុក និងការផ្លាស់ប្តូរបរិយាកាសនយោបាយនាពេលថ្មីៗនេះ។

**ដំណើរការថវិកា**: ទោះបីជាក្របខ័ណ្ឌច្បាប់និងគោលនយោបាយថ្នាក់ក្រោមជាតិបានផ្តល់ឱកាសឱ្យមានការ ចូលរួមពីសាធារណជននៅក្នុងដំណើរការថវិកា (ការរៀបចំ ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកា) ការស្រាវជ្រាវនិងការវាយតម្លៃផ្សេងៗ ក៏ដូចជាមតិយោបល់របស់អ្នកជំនាញ និងអ្នកអនុវត្តបានបំភ្លឺថាការអនុវត្តនៃការចូលរួមរបស់សាធារណជនក្នុងការងារថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតទាបនិងមានស្ថានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយ។ ប្រការនេះមានន័យថាវាអាស្រ័យលើវត្តមាននៃការគាំទ្រពីខាងក្រៅ។ ប្រសិនបើមានការគាំទ្រពីខាងក្រៅ ការចូលរួមរបស់សាធារណជនជាទូទៅមានភាពប្រសើរ បើមិនដូច្នេះទេការចូលរួមជាសាធារណៈមិនមានការរីកចម្រើនទេ។ ចំណែកការផ្តល់យោបល់ត្រលប់ទៅមតិយោបល់របស់សាធារណជនពីសំណាក់រដ្ឋបាលថ្នាក់ក្រោមជាតិវិញគឺមិនទាន់មានកើតឡើងនៅឡើយទេ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលមួយ[7] និងអង្គការរបស់អង្គការសហប្រជាជាតិមួយ[8]ដែលធ្វើការលើកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញ នូវភ័ស្តុតាងថាការចូលរួមរបស់សាធារណជននៅក្នុង កម្មវិធីវិនិយោគឃុំ (CIP) មានភាពប្រសើរឡើងនៅតាមតំបន់មួយចំនួន។ ក្រៅពីការរីកចម្រើនក្នុងការចូលរួមរបស់សាធារណជននៅថ្នាក់ឃុំ/សង្កាត់ក្នុងការរៀបចំនិងអនុម័តកម្មវិធីវិនិយោគឃុំ (CIP) ក៏មានការរីកចម្រើនក្នុងការចូលរួមរបស់សាធារណជនក្នុងការរៀបចំថវិកាឃុំ/សង្កាត់ប្រចាំឆ្នាំផងដែរ ដែលក្នុងនោះប្រជាពលរដ្ឋបានចូលរួមក្នុងដំណើរការរៀបចំនិងអនុម័តថវិការឃុំ/សង្កាត់។ ប៉ុន្តែភាពប្រសើរឡើងនៅថ្នាក់ឃុំ/សង្កាត់នេះមិនបានកើតឡើងនៅថ្នាក់មូលដ្ឋានខាងលើៗ ជាអាទ៍ នៅថ្នាក់ក្រុង ស្រុក និងខេត្ត / រាជធានី។

**តារាងទី០៣: ប្រតិទិនថវិកាឃុំសង្កាត់ (សម្រាប់ឆ្នាំសារពើពន្ធ "n"):**

| | ភារកិច្ច | មន្ត្រីទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| 1 | ការធ្វើសេចក្តីព្រាងថវិកា | មេឃុំ/ចៅសង្កាត់ | ខែកក្កដា – ថ្ងៃទី១៥ ខែតុលា (ឆ្នាំចាស់ n-1) |
| 2 | សេចក្តីព្រាងថវិកាត្រូវបានផ្សព្វផ្សាយជាសាធារណៈ | មេឃុំ/ចៅសង្កាត់ | មិនត្រូវយឺតជាងថ្ងៃទី១៥ ខែតុលា (ឆ្នាំចាស់ n-1) |
| 3 | ការអនុម័តសេចក្តីព្រាងថវិកា | ក្រុមប្រឹក្សាឃុំសង្កាត់ | មិនត្រូវយឺតជាងថ្ងៃទី៣១ ខែតុលា (ឆ្នាំចាស់ n-1) |
| 4 | ការបញ្ជូនសេចក្តីព្រាងថវិកាទៅ អភិបាលខេត្ត និងរាជធានី | មេឃុំ/ចៅសង្កាត់ | ថ្ងៃទី៥ ខែវិច្ឆិកា (ឆ្នាំចាស់ n-1) |
| 5 | ការអនុម័តសេចក្តីព្រាងថវិកា | អភិបាលខេត្ត / រាជធានី | មិនត្រូវយឺតជាងថ្ងៃទី៣០ ខែវិច្ឆិកា (ឆ្នាំចាស់ n-1) |
| 6 | ការអនុវត្តថវិកា | មេឃុំ/ចៅសង្កាត់ | ខែមករា - ធ្នូ (ឆ្នាំនេះ- n) |
| 7 | ការធ្វើវិសោធនកម្មថវិកា (ប្រសិនបើមាន) | មេឃុំ/ចៅសង្កាត់ និង ក្រុមប្រឹក្សាឃុំសង្កាត់ដោយមានការយល់ព្រមពីអភិបាលខេត្ត / រាជធានី | ខែមិថុនា - កក្កដា (ឆ្នាំនេះ- n) |
| 8 | ការបិទថវិកា | មេឃុំ/ចៅសង្កាត់ និង ក្រុមប្រឹក្សាឃុំសង្កាត់ដោយមានការយល់ព្រមពីអភិបាលខេត្ត / រាជធានី | ខែមករា - ខែមីនា (ឆ្នាំបន្ទាប់- n+1) |

[7] បទសម្ភាសន៍ទី៨, ជាមួយអង្គការមិនមែនរដ្ឋាភិបាល, ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩។
[8] បទសម្ភាសន៍ទី១១, ជាមួយដៃគូអភិវឌ្ឍន៍, ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១៩។

ប្រភព: (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០០២)

វឌ្ឍនភាពក្នុងការចូលរួមរបស់សាធារណជនក្នុងកម្មវិធីវិនិយោគឃុំ (CIP) និងការរៀបចំថវិការឃុំ / សង្កាត់នៅតែត្រូវការកែលម្អជាលំដាប់។ បញ្ហាគឺនៅត្រង់ថាជាទ្រឹស្តី ឃុំ/សង្កាត់ត្រូវរៀបចំនិងអនុម័តកម្មវិធីវិនិយោគឃុំ (CIP) មុនពេលរៀបចំនិងអនុម័តថវិកាប្រចាំឆ្នាំរបស់ឃុំសង្កាត់។ ក៏ប៉ុន្តែជាការអនុវត្តជាក់ស្តែងគឺវាមិនបានកើតឡើងដូច្នេះទេ គឺថាឃុំ / សង្កាត់ខ្លះបានរៀបចំកម្មវិធីវិនិយោគឃុំ (CIP) មុនពេលរៀបចំនិងអនុម័តថវិកាប្រចាំឆ្នាំ ដែលនេះគឺជារឿងល្អ ប៉ុន្តែក្នុងករណីផ្សេងទៀត ការរៀបចំកម្មវិធីវិនិយោគឃុំ (CIP) បានត្រូវធ្វើដំណាលគ្នាជាមួយនឹងការរៀបចំនិងអនុម័តថវិកាប្រចាំឆ្នាំ ហើយក្នុងករណីផ្សេងទៀតការរៀបចំនិងអនុម័តថវិកាប្រចាំឆ្នាំត្រូវបានធ្វើមុនពេលរៀបចំកម្មវិធីវិនិយោគឃុំ (CIP) ទៅទៀតក៏មាន។ តាមជាក់ស្តែងថវិកាឃុំ / សង្កាត់ត្រូវបានរៀបចំ អនុម័ត និងអនុវត្តតាមប្រតិទិនដែលណែនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (សូមមើលតារាងទី០៣) ។ ប៉ុន្តែប្រតិទិនស្រដៀងគ្នានេះនៅមិនទាន់មានទេសម្រាប់ការរៀបចំកម្មវិធីវិនិយោគឃុំ (CIP)[9]។ ក្រៅពីនេះបើយោងតាមការឱ្យដឹងពីក្រុមការងារថវិកាដែល សម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ភាពមិនទាន់ស៊ីសង្វាក់គ្នានេះគឺដោយសារតែ សេចក្តីប្រកាសរួមរបស់ ក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធីវិនិយោគឃុំ ៣ឆ្នាំរំកិលទើបតែត្រូវបានចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៨មក ហេតុដូច្នេះការតម្រូវឱ្យមានការណែនាំ និងការគាំទ្របន្ថែមដើម្បីឱ្យការអនុវត្តបានរលូនជាការចាំបាច់។

ដូចគ្នានេះដែរគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (PROCEED) ដែលបានអនុវត្តពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ដោយអង្គការផេកខេមបូឌា (Pact Cambodia) បាននាំមកនូវលទ្ធផលវិជ្ជមានមួយចំនួននៅឃុំ / សង្កាត់គោលដៅរបស់ខ្លួន។ ការរីកចំរើនមានដូចជាការយល់ដឹងកាន់តែប្រសើរឡើងអំពីតួនាទី សិទ្ធិ និងការទទួលខុសត្រូវ ទាំងខាងអ្នកទាមទាអភិបាលកិច្ច (ប្រជាពលរដ្ឋ)និង អ្នកផ្គត់ផ្គង់អភិបាលកិច្ច (ឃុំ / សង្កាត់ និងស្រុក / ក្រុង) ហើយក៏មានភាពប្រសើរឡើង[10]នូវទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងអាជ្ញាធរនៅថ្នាក់ទាំងពីរនេះផងដែរ[11]។ ការរីកចម្រើនបែបនេះមិនត្រូវបានឃើញនៅ

---

[9] នៅមិនមានប្រតិទិនស្តង់ដាររួមនៅគ្រប់ឃុំ / សង្កាត់ទាំងអស់សម្រាប់ការរៀបចំកម្មវិធីវិនិយោគឃុំ (CIP) ទេ។ ប្រតិទិនសម្រាប់ផែនការអភិវឌ្ឍឃុំ / សង្កាត់ត្រូវបានកំណត់ដោយខេត្តនីមួយៗ មានន័យថារដ្ឋបាលខេត្តនីមួយៗ (ផ្នែកផែនការនិងវិនិយោគ) កំណត់ប្រតិទិនសម្រាប់ឃុំនៅក្នុងខេត្តរបស់ខ្លួន។

[10] បទសម្ភាសន៍ទី៨, ជាមួយអង្គការមិនមែនរដ្ឋាភិបាល, ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៩ ។

[11] នៅក្នុងក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD 2010-2019) នេះ គេបានបង្កើតក្របខ័ណ្ឌគណនេយ្យភាពសង្គម (Social Accountability Framework - SAF)។ គោលបំណងមួយរបស់ក្របខ័ណ្ឌគណនេយ្យភាពសង្គម គឺការសម្របសម្រួលការចូលរួមរបស់ស្ថាប័នរដ្ឋនិងតួអង្គមិនមែនរដ្ឋក្នុងដំណើរការ

តាមតំបន់ដទៃទៀតដែលមិនមានការអនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ ឬគម្រោងស្រដៀងគ្នានោះទេ[12]។ ផ្នែកបន្ទាប់នៃរបាយការណ៍នេះនឹងពិនិត្យមើលករណីនៃការចូលរួមរបស់សាធារណជននៅប្រទេសឥណ្ឌូនេស៊ីនិងប្រទេសហ្វីលីពីន។

---

គណនេយ្យភាពសង្គម។ ផែនការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (I-SAF) ដែលបានអនុវត្តនៅចន្លោះឆ្នាំ ២០១៥ និងឆ្នាំ ២០១៧ ត្រូវបានវាយតម្លៃដោយធនាគារពិភពលោក (ឆ្នាំ ២០១៨)។ បើយោងតាមការវាយតម្លៃនេះ ជាទូទៅកម្រិតនិងគុណភាពនៃការចូលរួមរបស់សាធារណជនមិនមានការរីកចម្រើនទេបន្ទាប់ពីមានការអនុវត្ត I-SAF ហេតុដូច្នេះ របាយការណ៍ស្រាវជ្រាវនេះមិនបានរៀបរាប់លម្អិតពីមេរៀនដែលអាចដកស្រង់ចេញពីការអនុវត្តផែនការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមដែលបានអនុវត្តកន្លងមកនោះទេ។

[12] បទសម្ភាសន៍ទី៨, ជាមួយអង្គការមិនមែនរដ្ឋាភិបាល, ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩។

# ជំពូកទី៣: បទពិសោធន៍ល្អៗអំពីការចូលរួមជាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងដំណើរការថវិកាជាតិនៅប្រទេស ឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន

## ៣.១. កំណត់ចំណាំអំពីការប្រៀបធៀបរវាងប្រទេសទាំងពីរនិងប្រទេសកម្ពុជា

គោលបំណងចំបងមួយនៃស្រាវជ្រាវបែបប្រៀបធៀបរវាងប្រទេសទាំងពីរនេះនិងប្រទេសកម្ពុជា គឺដើម្បីស្វែង យល់ពីបទពិសោធន៍នៃ"ការអនុវត្តល្អៗ" ក៏ដូចជាបញ្ហាគន្លឹះៗនៃការចូលរួមជាសាធារណៈក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈដែលប្រទេសឥណ្ឌូនេស៊ីនិងប្រទេសហ្វីលីពីនប្រឈម និងដកស្រង់យកមេរៀនល្អៗមក ពង្រឹងការអនុវត្តការចូលរួមរបស់សាធារណជន និងអង្គការសង្គមស៊ីវិលនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជា។ ជាការកត់ចំណាំមួយគឺថា ប្រទេសទាំងពីរនេះ ជាទូទៅអាចមានប្រព័ន្ធនយោបាយ និងរចនាសម្ព័ន្ធនយោបាយ សេដ្ឋកិច្ច និងសង្គមខុសៗគ្នា និងអាចខុសពីប្រព័ន្ធនិងរចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជាដែលអាចធ្វើឱ្យការអនុវត្តមួយចំនួនរបស់ពួកគេមិនស៊ីគ្នានឹងបរិបទរបស់ប្រទេសកម្ពុជា។ ជាឧទាហរណ៍នៅប្រទេសឥណ្ឌូនេស៊ី គ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ និងការយកចិត្តរបស់ឥស្សរជនសំខាន់ៗក្នុងតំបន់នានាដើម្បីបញ្ចប់ជម្លោះស៊ីវិលក្នុងបុព្វហេតុផលប្រយោជន៍រួម បានជួយសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនៅក្នុងកិច្ចការរបស់រដ្ឋាភិបាលឥណ្ឌូនេស៊ី បើទោះបីជាការចូលរួមជា សាធារណៈនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសនេះនៅតែត្រូវការការកែលម្អមួយ កម្រិតធំទៀត និងជាបន្តបន្ទាប់ទៀតក៏ដោយ (Ahmed និង Weiser, 2006; Kristiansen, et al., 2008; Sopanah, 2012)។ នៅប្រទេសហ្វីលីពីន យ៉ាងហោចណាស់ កត្តាសំខាន់ៗចំនួន ៤ បានសម្រួលដល់កិច្ចការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីដើមទស្សវត្ស៍ ឆ្នាំ២០០០មក។ កត្តាទាំងនេះរួមមាន: (១)វេទិកានយោបាយសម្រាប់ការបោះឆ្នោតរបស់លោក ប្រធានាធិបតី អាគីណូ ដែលផ្តោតជាចំបងលើការប្រឆាំងអំពើពុករលួយ និងតម្លាភាព (២) ការតែងតាំងមនុស្សជំនិតរបស់គាត់ ដែលជាមនុស្សកំណែទម្រង់និយម និងជាមនុស្សធ្លាប់មានបទពិសោធន៍ក្នុងវិស័យសង្គមស៊ីវិល ឲ្យធ្វើជារដ្ឋមន្ត្រីក្រសួងថវិកានិងការគ្រប់គ្រង (DBM) ដែលការជួយសម្រួលដល់ការចូលរួមជាសាធារណៈ ក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៣) ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៃរដ្ឋបាលលោកប្រធានាធិបតី អាគីណូ ក្នុងការធ្វើឱ្យប្រសើរឡើងនៅក្នុងការស្ទង់មតិ OBS និង (៤) ការដែលថាប្រទេសហ្វីលីពីន ជាប្រទេសសមាជិកស្ថាបនិកនៃគំនិតផ្តួចផ្តើមភាពជាដៃគូបើកទូលាយថវិកា (Capistrano, 2017; Magno, 2015; Marchessault, មិនមានកាល បរិច្ឆេទ)។ យ៉ាងណាក៏ដោយ ការនេះមិនមែនមានន័យថាប្រទេសកម្ពុជាមិនអាចរៀនសូត្រពីបទពិសោធន៍ល្អៗរបស់ប្រទេសទាំងពីរនេះដើម្បីបង្កើននិងពង្រឹងការចូលរួមរបស់សាធារណជន និងអង្គការសង្គមស៊ីវិលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងធ្វើឱ្យមានភាព

ប្រសើរឡើងក្នុងការស្ទង់មតិOBSនោះទេ។ ផ្ទុយទៅវិញ ប្រទេសកម្ពុជាអាចដកស្រង់នូវបទពិសោធន៍ល្អៗ និងដែលសមស្របនឹងបរិបទរបស់ប្រទេសនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបស់ខ្លួន។

## ៣.២. លទ្ធផលនៃការស្ទង់មតិ OBS អំពីការចូលរួមជាសាធារណៈ នៅប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន

មុននឹងស្វែងយល់ពីការអនុវត្តនានានៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន យើងគួរតែស្វែងយល់ អំពីរូបភាពរួមនៃការចូលរួមជាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសទាំងពីរនេះ ក៏ដូចជាការអនុវត្តនៅប្រទេសកម្ពុជា តាមរយៈការវិភាគពីការអនុវត្តនិងពិន្ទុរបស់ប្រទេសទាំងនេះ នៅក្នុងការស្ទង់មតិOBS។ ប្រទេសហ្វីលីពីន និងឥណ្ឌូណេស៊ី (ដូចមានក្នុងតារាង០៤) បានផ្តល់ឱកាសដល់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលរបស់ពួកគេចូលរួម ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈច្រើនជាងប្រទេសកម្ពុជានៅក្នុងវដ្តថវិកាជាតិ និងក្នុងផ្នែកផ្សេងៗទៀតនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

តារាង០៤ បានបង្ហាញថា លទ្ធផលជារួមលើការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជា គឺទាបបំផុតក្នុងចំណោមប្រទេសទាំងបី ខណៈដែលប្រទេសពីរទៀតបានពន្ទុល្អប្រសើរជាងប្រទេសនេះ។ ទោះជាការស្ទង់មតិ OBSពីមុនបួនដង មិនមានពិន្ទុជារួម លើការចូលរួមជាសាធារណៈក៏ដោយ ក៏លទ្ធផលក្នុងការស្ទង់មតិពីរចុងក្រោយ គឺនៅឆ្នាំ២០១៥ និង២០១៧ បានបង្ហាញថា ប្រទេសពីរទៀត មានការអនុវត្តល្អប្រសើរជាងប្រទេសកម្ពុជាជាមួយកម្រិតធំ។ ជាពិសេស ប្រទេសហ្វីលីពីនបានពន្ទុល្អ ប្រសើរខ្លាំងនៅក្នុងការស្ទង់មតិបីលើកចុងក្រោយ។ នៅឆ្នាំ២០១២ តាមការស្ទង់មតិបានបង្ហាញថា ប្រទេសនេះបានផ្តល់ឱកាស "មធ្យម" និងនៅឆ្នាំ២០១៥ វាបានផ្តល់ឱកាស "គ្រប់គ្រាន់" សម្រាប់ការចូលរួមជាសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ នៅឆ្នាំ២០១៧វាបានផ្តល់ឱកាស"នៅមានកម្រិត"(គ្រប់គ្រាន់សម្រាប់ស្ថាប័នសវនកម្មកំពូល)។[13]

**តារាងទី ០៤: ពិន្ទុលើការអនុវត្តជារួម និងការចូលរួមជាសាធារណៈ នៅប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន**

| | កម្ពុជា | | | ឥណ្ឌូនេស៊ី | | | ហ្វីលីពីន | | |
|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ពិន្ទុរួម | ពិន្ទុការចូលរួម | កំណត់ចំណាំ | ពិន្ទុរួម | ពិន្ទុការចូលរួម | កំណត់ចំណាំ | ពិន្ទុរួម | ពិន្ទុការចូលរួម | កំណត់ចំណាំ |

[13] ប្រសិនបើគេប្រើវិធីសាស្ត្រវាយតម្លៃឆ្នាំ២០១៥ មកវាយតម្លៃការស្ទង់មតិ OBS នៅឆ្នាំ២០១៧ វិញនោះ ប្រទេសនេះ អាចត្រូវវាយតម្លៃថា បានផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការចូលរួមជាសាធារណៈ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ជាសាធារណៈ | | | ជាសាធារណៈ | | | ជាសាធារណៈ | |
| ២០០៦ | - | - | | ៤១ | (ម/ទ) | | ៥១ | (ម/ទ) | |
| ២០០៨ | ១១ | (ម/ទ) | | ៥៤ | (ម/ទ) | | ៤៨ | (ម/ទ) | |
| ២០១០ | ១៥ | (ម/ទ) | | ៥១ | (ម/ទ) | | ៥៥ | (ម/ទ) | |
| ២០១២ | ១៥ | (ខ្សោយ) | | ៦២ | (ខ្សោយ) | **(ពិន្ទុការចូលរួមជាសាធារ**ណៈ តិចជាង ៣៤) | ៤៨ | (មធ្យម)* | **(ពិន្ទុការចូលរួមជា សាធារ**ណៈ ពីចន្លោះ ៣៤ ទៅ ៦៦) |
| ២០១៥ | ៨ | ៨ | សរុប = ខ្សោយ; ប្រ=ខ្សោយ; ប= គ្មាន; ស=ខ្សោយ | ៥៩ | ៣៥ | សរុប = ខ្សោយ; ប្រ = ខ្សោយ; ប = មានកំណត់; ស = មានកំណត់ | ៦៤ | ៦៧ | សរុប = គ្រប់គ្រាន់; ប្រ = គ្រប់គ្រាន់, ប = មានកំណត់, ស = មានកំណត់ |
| ២០១៧ | ២០ | ៤ | សរុប = ខ្សោយ; ប្រ = ខ្លះ (៦); ប = ស្ទើរគ្មាន (0); ស = ស្ទើរគ្មាន (0) | ៦៤ | ២២ | សរុប = ខ្លះៗ; ប្រ = ខ្លះ (៨); ប = ខ្លះ (១៨); ស = មានកំណត់ (៥៦) | ៦៧ | ៤១ | សរុប = មានកំណត់; ប្រ = មានកំណត់ (៤២), ប = ខ្លះ (៨), ស = គ្រប់គ្រាន់ (៧៨) |

ប្រភព: ចងក្រងដោយក្រុមអ្នកស្រាវជ្រាវ ពីសន្ទស្សន៍បើកទូលាយថវិកា (Open Budget Indexes) និងការស្ទង់មតិ បើកចំហថវិកា (Open Budget Surveys) សម្រាប់ប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន (ឆ្នាំ ២០០៦-២០១៧)។

កំណត់ចំណាំ: ម/ទ = មិនទាក់ទង ចំនួនតិច = 0-៤0 មានកំណត់ = ៤១-៦0 គ្រប់គ្រាន់ = ៦១-១០០ ខ្សោយ = 0-៣៣ មធ្យម = ៣៤-៦៦ ខ្ពស់ = ៦៧-១០០ ប = នីតិបញ្ញត្តិ ប្រ = នីតិប្រតិបត្តិ ស = អាជ្ញាធរសវនកម្ម

សរុបមក ការរកឃើញពីការវិភាគលើការស្ទង់មតិទាំងអស់បានបង្ហាញថា ប្រទេសទាំងបីនេះនៅតែត្រូវផ្តល់ ឱកាសបន្ថែមទៀតដល់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលរបស់ខ្លួនក្នុងការចូលរួមការរៀបចំ និងការ ត្រួតពិនិត្យការអនុវត្តថវិកា ក្នុងវដ្តថវិកាទាំងមូល។ ប៉ុន្តែក្នុងចំណោមប្រទេសទាំងបី ប្រទេសកម្ពុជាបានផ្តល់ ឱកាសតិចតួចបំផុតដល់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលរបស់ខ្លួនក្នុងការចូលរួមសកម្មភាពគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈរបស់អង្គសំខាន់ទាំងបីនៃរដ្ឋ គឺអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល ហើយទទួលបានពិន្ទុសូន្យ លើសំណួរភាគច្រើននៅក្នុងការស្ទង់មតិ OBS។ ទោះបីប្រទេសឥណ្ឌូណេស៊ី ទទួលបានពិន្ទុសូន្យសម្រាប់សំណួរមួយចំនួនក៏ដោយ ក៏ប្រទេសនេះទទួលបានពិន្ទុល្អជាងប្រទេសកម្ពុជា នៅ ក្នុងសំណួរមួយចំនួនធំ (ដែលភាគ ច្រើនវាបានពិន្ទុមធ្យម ឬទាបជាងមធ្យម)។ កាលពីដំបូង ប្រទេសហ្វីលីពីន បានទទួលពិន្ទុមធ្យម ឬក្រោមមធ្យម លើសំនួរជាច្រើនក្នុងការស្ទង់មតិពីរលើកដំបូង។ ប៉ុន្តែមិនដូចប្រទេស កម្ពុជា និងប្រទេសឥណ្ឌូនេស៊ីទេ ប្រទេសនេះបានធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបស់ខ្លួនជាប្រចាំ និងជា ពិសេសចាប់តាំងពីមានរដ្ឋបាលរបស់

លោក អាគីល្លា មកដោយវាទទួលបានពិន្ទុពេញ ឬលើមធ្យមលើសំណួរ ភាគច្រើននៅក្នុងការស្ទង់មតិក្រោយៗមក។ ពិន្ទុសម្រាប់អាជ្ញាធរជាតិសវនកម្មរបស់ប្រទេសនេះមានភាព ប្រសើរឡើងគួរឲ្យកត់សម្គាល់ជាងគេ។

## ៣.៣. ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូណេស៊ី: កំណែទម្រង់ឆ្ពោះទៅកាន់ការចូលរួមជាសាធារណៈដែល កាន់តែប្រសើរឡើង - វឌ្ឍនភាពនិងបញ្ហាប្រឈម

ផ្នែកនេះ ផ្តោតជាចំបងលើវិធានការកំណែទម្រង់គន្លឹះៗ ឆ្ពោះទៅរកការចូលរួមជាសាធារណៈ ដែលកាន់តែ ប្រសើរឡើង នៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន។ វាពិនិត្យទៅលើផ្នែកសំខាន់ៗ នៃការចូលរួម (ជាពិសេស លទ្ធផលនិងបញ្ហាប្រឈមនានាដែលនៅសេសសល់) ដែលគ្របដណ្តប់នៅក្នុងការស្ទង់មតិ OBS ទាក់ទងទៅនឹងអង្គនិតិប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និងអង្គសវនកម្មជាតិ ។

### ប្រទេសឥណ្ឌូនេស៊ី

<u>អង្គនីតិប្រតិបត្តិ</u>

ចំណុចចំនួន ៣ ដែលស្ថាប័ននីតិប្រតិបត្តិប្រទេសឥណ្ឌូណេស៊ី ធ្វើបានល្អគួរសម គឺការអនុម័តច្បាប់ស្តីពីសិទ្ធិ ទទួលបានព័ត៌មាន ការបង្កើតយន្តការជាក់ស្តែងនិងអាចរកបាន ដើម្បីកំណត់ទស្សនៈរបស់សាធារណជនលើ អាទិភាពថវិកា និងចំនួនប្រធានបទដែលបានលើកមកពិភាក្សាក្នុងពេលមានការចូលរួមរបស់សាធារណជនក្នុងការរៀបចំថវិកា។ ចំណុចផ្សេងទៀត ដែលមាននៅក្នុងការស្ទង់មតិត្រូវការធ្វើឱ្យមានភាពប្រសើរឡើងមួយកម្រិតធំ។

ទីមួយ ការអនុវត្តល្អមួយនៅប្រទេសឥណ្ឌូនេស៊ី គឺការតម្រូវពីផ្លូវច្បាប់ស្តីពីការទទួលបានព័ត៌មាន ការទទួលបានព័ត៌មានជាក់ស្តែង និងការចេញផ្សាយព័ត៌មានរបស់រដ្ឋាភិបាល។ វាបានពិន្ទុខ្សោយ លើចំនុចទាំងនេះនៅក្នុងការស្ទង់មតិពីរលើកដំបូង និងទទួលបានពិន្ទុមធ្យម លើតម្រូវការផ្លូវច្បាប់ និងការអនុវត្តជាក់ស្តែងក្នុងការទទួលបានព័ត៌មាន នៅឆ្នាំ២០១០ ជាឆ្នាំចុងក្រោយដែលចំណុចនេះ ត្រូវបានវាយតម្លៃក្នុងការស្ទង់មតិ OBS។ ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន តម្រូវឱ្យភ្នាក់ងារ រដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បញ្ចេញព័ត៌មានសាធារណៈដល់ប្រជាពលរដ្ឋ ដើម្បីឱ្យ ពួកគេអាចទទួលបានព័ត៌មានបែបនេះ។ ច្បាប់នេះត្រូវបានអនុម័តនៅឆ្នាំ២០០៨ ហើយត្រូវអនុវត្តយ៉ាងទូលំទូលាយ ដោយគ្របដណ្តប់លើគ្រប់កម្រិតនៃរដ្ឋាភិបាលចាប់ពីឆ្នាំ២០១០ តទៅ។ ជាការអនុវត្តជាក់ស្តែង លើកលែងតែក្នុងឆ្នាំ២០០៦ នៅក្នុងការស្ទង់មតិបន្តបន្ទាប់មក ប្រទេសនេះត្រូវបានគេវាយតម្លៃថា បានផ្តល់ដល់សាធារណជនដោយផ្អែកនូវព័ត៌មានហិរញ្ញវត្ថុ និង ព័ត៌មានមិនមែនហិរញ្ញវត្ថុនៃថវិកាជាតិ នៅក្នុងទម្រង់ព័ត៌មានសំរាយ (សម្រាប់កម្មវិធីថវិកាដែលគ្រប ដណ្តប់តិចជាង ២ភាគ៣ នៃការចំណាយថវិកា

ជាតិ) ។ សាធារណជន នៅតែមានឧបសគ្គខ្លះៗក្នុង ការទទួលបានព័ត៌មានសាធារណៈ ជាពិសេសព័ត៌មានហិរញ្ញវត្ថុ (IBP, 2010e Kristiansen, et al, 2008) ប៉ុន្តែលទ្ធភាពនៃការទទួលបាន "ព័ត៌មានបែបនេះ គឺមាន... និងការទទួលបាននូវព័ត៌មាន បែបនេះក៏មានភាពងាយស្រួលដែរ" (IBP, 2006e) ។

ទីពីរ ប្រទេសឥណ្ឌូនេស៊ីក៏បានពិន្ទុល្អដែរ សម្រាប់ការបង្កើតយន្តការជាក់ស្តែង និងអាចរកបាន ដើម្បីកំណត់ ទស្សនរបស់សាធារណជនលើអាទិភាពថវិកា និងទីបី ចំនួនប្រធានបទ ដែលបានលើកយកមកពិភាក្សាក្នុងពេលមានការចូលរួមរបស់សាធារណជនក្នុងការរៀបចំថវិកាជាតិ។ ប្រទេសនេះបានពិន្ទុខ្ពស់ជាងមធ្យម សម្រាប់ចំណុចទាំងពីរនេះ។ ការនេះកើតឡើងតាំងពីឆ្នាំ២០១៥មក ហើយមុនឆ្នាំនេះវាទទួលបានពិន្ទុខ្សោយ លើចំណុចទាំងពីរនេះ។ ទោះជាយ៉ាងណាក៏ដោយ ខណៈដែលវាបានបង្កើតយន្តការមួយចំនួនសម្រាប់ការ ចូលរួមជាសាធារណៈ យន្តការទាំងនេះមិនត្រូវបានត្រូវប្រើប្រាស់យ៉ាងទូលំទូលាយដោយសាធារណជន នោះទេ។ ម្យ៉ាងទៀត មានតែចំនួនពាក់កណ្តាលនៃប្រធានបទសំខាន់ៗសម្រាប់យកមកពិភាក្សាជាមួយ សាធារណជន ដែលត្រូវបានកំណត់នៅក្នុងការស្ទង់មតិ OBS ត្រូវបានគ្របដណ្តប់ក្នុងពេលពិភាក្សា។ មុនឆ្នាំ ២០១៥ សាធារណជនអាចចូលរួមរៀបចំផែនការអភិវឌ្ឍន៍ជាតិរយៈពេលមធ្យម (RPJMN) តែប៉ុណ្ណោះ ដែលការចូលរួមនេះអាច ធ្វើឡើងតាមរយៈវេទិកាពិភាក្សាសម្រាប់គម្រោងអភិវឌ្ឍន៍ (Musrenbang)។ ផែនការរយៈពេលមធ្យមនេះត្រូវបានគេប្រើដើម្បីផ្តល់ទិសដៅអាទិភាពចំណាយប្រចាំឆ្នាំ ដែលធ្វើឡើងតាមរយៈ ការរៀបចំផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ RKP (IBP, 2012e) ។ ក្នុងន័យនេះ សាធារណជន និងអង្គការ សង្គមស៊ីវិល មិនត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងដំណើរការទាំងមូល នៃការរៀបចំថវិកាប្រចាំឆ្នាំនោះទេ។

ទោះបីជាមិនមានការតម្រូវពីច្បាប់ស្តីពីការចូលរួមរបស់សាធារណជន និងសង្គមស៊ីវិលនៅក្នុងដំណើរការថវិកា ជាពិសេសនៅថ្នាក់ជាតិក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែង មានយន្តការមួយចំនួនសម្រាប់ឱ្យពួកគេចូលរួម ក្នុងកិច្ចការនេះ ជាពិសេសនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ រដ្ឋាភិបាលបានបង្កើតឱកាសឱ្យមានការចូល រួមជាបណ្តើរៗ និងពង្រីកបន្ថែមនូវយន្តការដែលមានស្រាប់ដើម្បីឱ្យមានការចូលរួមនេះ។ Musrenbang ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារផែនការអភិវឌ្ឍន៍ជាតិ (NDPA) ត្រូវបានរដ្ឋប្រគល់ភារកិច្ចឱ្យធ្វើ ផែនការរយៈពេលវែង ផែនការរយៈពេលមធ្យម និងផែនការប្រចាំឆ្នាំ។ ការរៀបចំផែនការថវិកាប្រចាំឆ្នាំ ត្រូវបានបែងចែកជាពីរដំណាក់កាល គឺទីមួយការអភិវឌ្ឍផែនការបច្ចេកទេស (ផែនការការងារប្រចាំឆ្នាំ) ក្រោម ការចាត់ចែងរបស់ Musrenbang ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលជាអ្នករៀបចំផែនការអភិវឌ្ឍន៍ពីថ្នាក់ ក្រោមជាតិដល់ថ្នាក់ជាតិ និងទីពីរគឺការគិតគូថវិកាសម្រាប់ផែនការនេះ ក្រោមកិច្ចសហការរវាងភ្នាក់ងារផែន ការអភិវឌ្ឍន៍ជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលដាក់ឯកសារផែនការនេះឱ្យនីតិបញ្ញត្តិអនុម័ត។ កាលពីដំបូង ការរៀបចំផែនការការងារប្រចាំឆ្នាំ គឺជាកិច្ចការផ្តាច់មុខរបស់រដ្ឋ ដោយគ្មានតម្រូវការផ្លូវច្បាប់ លើការចូលរួមជាសាធារណៈ ក៏ដូចជាការអនុវត្តជាក់ស្តែងនោះទេ (IBP, 2006e IBP, 2008e)។ ប៉ុន្តែចាប់ តាំងពីឆ្នាំ២០០៨មក រដ្ឋាភិបាលបានបើកវេទិកានេះជាបណ្តើរៗ ដើម្បីឱ្យមានការចូលរួមពីផ្នែកសាធារណៈ (រួមទាំងសាកលវិទ្យាល័យ) និងអង្គការសង្គមស៊ីវិល

ដែលភាគីរដ្ឋអញ្ជើញឱ្យចូលរួមនៅក្នុងដំណើរការការងារ របស់គ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលសាធារណៈ (ពីថ្នាក់ភូមិដល់ថ្នាក់ជាតិ) ។ មូលដ្ឋានច្បាប់សម្រាប់ការចូលរួម នេះត្រូវបានគេចែងនៅក្នុងច្បាប់២៥/២០០៤ (IBP, 2008e)។ ក្រោយៗមក ផ្នែកសាធារណៈ និងអង្គការ សង្គមស៊ីវិលជាច្រើនដទៃទៀត ក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការពិភាក្សាកំណត់អាទិភាពជាតិផងដែរ។

ក្តីបារម្ភមួយអំពីយន្តការនេះ គឺថាសាធារណជន និងអង្គការសង្គមស៊ីវិល មិនបានចូលរួមយ៉ាងសកម្មខ្លាំងក្លា នៅក្នុងយន្តការនេះទេ ហើយវេទិកានេះនៅតែត្រូវបានគ្របដណ្តប់ដោយភាគីរដ្ឋាភិបាល និងធ្វើឡើងដើម្បី បង្គ្រប់កិច្ចប៉ុណ្ណោះ (Ahmed and Weiser, 2006, IBP, 2015e; Kristiansen, et al, 2008; Sopanah, 2012)។ បញ្ហាមួយទៀតគឺថា ឱកាសនៃការចូលរួមមិនត្រូវបានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយ នោះទេ។ការរិះគន់ធំជាងនេះមួយទៀតគឺថា ទោះរដ្ឋាភិបាលបានបើកទូលាយឱ្យមានការចូលរួមជា សាធារណៈ ក្នុងទិដ្ឋភាពបច្ចេកទេសនៃការធ្វើផែនការក៏ដោយ ក៏ការរៀបចំថវិកាសម្រាប់ផែនការនេះ នៅតែត្រូវបានធ្វើ ឡើងដោយគ្មានការចូលរួមរបស់សាធារណជន និងអង្គការសង្គមស៊ីវិល ដែលការនេះបានបង្កើតឱ្យ មាន "ភាពដាច់នៃការចូលរួមជាសាធារណៈ" (IBP, 2015e)។ លើសពីនេះទៀតដោយសារការចូលរួមជា សាធារណៈមានលក្ខណៈជ្រើសរើស ប្រការនេះជាមូលដ្ឋានដែលធ្វើឱ្យប្រទេសឥណ្ឌូនេស៊ីទទួលបានពិន្ទុត្រឹម ខ្ពស់ជាងមធ្យម ឬទាបជាងមធ្យម សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងសកម្មភាពនៃការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈរបស់នីតិប្រតិបត្តិ។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមជាសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រទេសឥណ្ឌូនេស៊ី ត្រូវដោះស្រាយបញ្ហាមួយចំនួនទៀត ជាអាទ៍រួមមាន: (១) តម្រូវការច្បាប់ស្តីពីការចូលរួមជាសាធារណៈ ក្នុងការរៀបចំ និងការត្រួតពិនិត្យការអនុវត្តថវិកាជាតិ (២) ការបង្ហាញពីគោលបំណងសម្រាប់ការចូលរួម និងការផ្តល់ព័ត៌មានជាមុន សម្រាប់ការពិភាក្សាបញ្ហាថវិកា (៣) ការដាក់បញ្ចូលការចូលរួមជាសាធារណៈ នៅក្នុងប្រតិទិនការរៀបចំថវិកាជាតិ និង(៤) ការចូលរួមនៃក្រុមជនងាយរងគ្រោះ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។ ប្រទេសនេះជាទូទៅទទួលបានពិន្ទុខ្សោយសម្រាប់ចំណុចទាំងនេះ។ ការចូលរួមជាសាធារណៈ ក្នុងការអនុវត្តថវិកាជាតិ (ជាឧទាហរណ៍ ការស្វែងយល់អំពីទស្សនរបស់សាធារណជនលើថវិកាជាតិ) និងការ អនុវត្តថវិការបស់ក្រសួងពាក់ព័ន្ធ គឺជារឿងផ្សេងទៀតដែលត្រូវការកែលម្អផងដែរ។ ជាការអនុវត្តជាក់ស្តែង មានយន្តការចំពោះកិច្ចការមួយចំនួន សម្រាប់ការត្រួតពិនិត្យថវិកាជាតិពីសំណាក់សាធារណជន និងអង្គការ សង្គមស៊ីវិល ប៉ុន្តែយន្តការជាប្រព័ន្ធ និងតម្រូវកាផ្នែកច្បាប់សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តថវិកាជាតិ នៅមិនទាន់មាននៅឡើយទេ។ កម្មវិធី "LIPOR" ដែលរៀបចំដោយការិយាល័យ ប្រធានាធិបតីគឺជា ឧទាហរណ៍មួយ។ សាធារណជនអាចផ្ញើមតិនានា រួមទាំងមតិស្តីពីការអនុវត្តថវិកាផងដែរ តាមរយៈកម្មវិធី នេះ។ តែជាក់ស្តែង ការប្រើប្រាស់កម្មវិធីនេះនៅតែមានកម្រិតនៅឡើយ (IBP, 2017e) ។

ដើម្បីធានាបាននូវតម្លាភាព និងអត្ថប្រយោជន៍នៃការចូលរួមជាសាធារណៈ ចាប់តាំងពីឆ្នាំ២០១២មក ការស្ទង់មតិ OBS ក៏បានវាយតម្លៃថាតើនីតិប្រតិបត្តិបានផ្តល់មតិយោបល់ត្រលប់ អំពីការប្រើប្រាស់នូវធាតុ ចូលពីសាធារណជននិងអង្គការសង្គមស៊ីវិល សម្រាប់ការៀបចំ និងការអនុវត្តថវិកាជាតិ ដែរឬទេ ។ ប្រទេសនេះ ជារួមគឺទទួលបានពិន្ទុខ្សោយលើចំណុចនេះ។ គឺថា វាមិនដែលបានផ្តល់មតិយោបល់ត្រលប់បែបនេះដល់ សាធារណជន និងអង្គការសង្គមស៊ីវិលនោះទេ។ មានតែមួយឆ្នាំទេ គឺនៅឆ្នាំ២០១៤ ដែលវាបានចេញផ្សាយ របាយការណ៍សង្ខេបមួយ ដែលរៀបរាប់អំពីដំណើរការពិគ្រោះយោបល់ និងសេចក្តីសង្ខេបលទ្ធផលនៃការ ពិគ្រោះយោបល់ សម្រាប់ការរៀបចំថវិកា។

**<u>អង្គនីតិប្បញ្ញត្តិ</u>**

នៅក្នុងផ្នែកស្តីពីការចូលរួមជាសាធារណៈនៅក្នុងការសម្រេចចិត្តរបស់អង្គនីតិប្បញ្ញត្តិ (ដែលភាគច្រើនផ្តោតលើ គណៈកម្មាធិការនានារបស់អង្គនីតិប្បញ្ញត្តិ) ការស្ទង់មតិ OBS ពិនិត្យទៅលើ (១) ការចូលរួមរបស់ នីតិប្រតិបត្តិនិងផ្នែកសាធារណៈ នៅក្នុងសវនាការសាធារណៈ ដែលធ្វើឡើងដោយអង្គនីតិប្បញ្ញត្តិទៅលើ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ (២) ថវិកាជាតិសម្រាប់អង្គភាពថ្នាក់កណ្តាលនានានៃរដ្ឋាភិបាល (CGAUs) និង (៣) នៅក្នុងរបាយការណ៍ការស្ទង់មតិសវនកម្មចុងក្រោយ និង (៤) ថាតើវាបានចេញ ផ្សាយរបាយការណ៍ ឬផ្តល់មតិយោបល់ត្រលប់នៃសវនាការសាធារណៈនេះដែរឬទេ។ អង្គនីតិប្បញ្ញត្តិ ឥណ្ឌូណេស៊ី ជាទូទៅទទួលបានពិន្ទុទាបជាងមធ្យមនៅលើបួនចំណុចនេះ ទោះបីជាមានភាពលម្អិតគួរឱ្យកត់ សម្គាល់មួយចំនួនដូចខាងក្រោម។

ចាប់ពីឆ្នាំ២០១២មក អង្គនីតិប្បញ្ញត្តិបានចាប់ផ្តើមបើកទូលាយ ឱ្យមានការចូលរួមរបស់ សាធារណជន និង អង្គការសង្គមស៊ីវិល ក្នុងកិច្ចការសម្រេចចិត្តរបស់ខ្លួនជាបណ្តើរៗ និងបានទទួលពិន្ទុខ្លះៗ (ក្រោមមធ្យម) សម្រាប់ចំណុចនេះ។ គណៈកម្មាធិការនៃអង្គនីតិបញ្ញត្តិ បានរៀបចំសវនាការដាច់ដោយឡែកពីគ្នា គឺមួយធ្វើឡើងជាមួយអង្គនីតិប្រតិបត្តិ និងមួយទៀតធ្វើឡើងជាមួយសាធារណជន អំពីថវិកាជាតិសម្រាប់អង្គភាពមួយ ចំនួននៃរដ្ឋបាលថ្នាក់កណ្តាល។ នៅក្នុងសវនាការជាមួយអង្គនីតិប្រតិបត្តិ សាធារណជនមិនត្រូវបានផ្តល់ ឱកាសឱ្យផ្តល់សក្ខីកម្មនោះទេ ប៉ុន្តែក្នុងសវនាការជាមួយសាធារណជន តំណាងអង្គការសង្គមស៊ីវិល (និងអង្គភាពរដ្ឋបាលថ្នាក់កណ្តាលដែលពាក់ព័ន្ធ) ត្រូវបានអញ្ជើញឱ្យផ្តល់សក្ខីកម្មឬធាតុចូលដល់ការពិភាក្សា នេះ។ ការចូលរួមគឺមាន ប៉ុន្តែមិនមានលក្ខណៈបើកចំហទូលំទូលាយសម្រាប់មនុស្សគ្រប់គ្នានោះទេ ហើយ គណៈកម្មាធិការនីមួយៗមានសិទ្ធិសម្រេចថាតើកិច្ចប្រជុំទាំងនោះត្រូវធ្វើឡើងដោយបិទទ្វារឬបើកទ្វារ។ ការចូល រួមនេះក្រោយមកត្រូវបានចែងជាច្បាប់ ប៉ុន្តែក៏មានករណីលើកលែងដែរ។ ច្បាប់ស្តីពីស្ថាប័ននីតិប្បញ្ញត្តិបាន ណែនាំថាសាធារណជនអាចចូលរួមកិច្ចប្រជុំរបស់អង្គនីតិបញ្ញត្តិ ឬអាចចូលរួមតាមរយៈការផ្សាយបន្តផ្ទាល់ តាមប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែការផ្តល់សក្ខី

កម្មមិនត្រូវបានអនុញ្ញាតនោះទេ ហើយមានតែមនុស្សដែលបាន អញ្ជើញពីរឬបីនាក់ប៉ុណ្ណោះ ដែលអាចផ្តល់នូវធាតុចូលបាន (IBP, 2017e) ។[14]

ចាប់តាំងពីឆ្នាំ២០១២មក គណៈកម្មាធិការនីតិបញ្ញត្តិដែលបានរៀបចំសវនាការជាសាធារណៈ បានចេញ ផ្សាយរបាយការណ៍ស្តីពីសវនាការរបស់ខ្លួន។ ប៉ុន្តែក៏មានការខ្វះខាតផងដែរ ដែលរួមមាន: ការចេញសេចក្តីសង្ខេបនៃសវនាការជាជាងរបាយការណ៍លម្អិត ការចេញរបាយការណ៍សម្រាប់តែសវនាការបើកចំហរ និងភាពលំបាកក្នុងការស្វែងរករបាយការណ៍ដែលចេញផ្សាយនៅលើគេហទំព័ររបស់ខ្លួន (www.dpr.go.id.)។ ពួកគេ ក៏មិនដែលបានផ្តល់ការឆ្លើយតបត្រលប់វិញ ទៅដល់សាធារណជននិងអង្គការសង្គមស៊ីវិល ថាតើធាតុចូល ដែលទទួលបានពីពួកគេត្រូវបានប្រើដោយ របៀបណាដើម្បីកែលម្អផែនការថវិកានោះទេ។ ដូច្នេះហើយទើប អង្គនីតិប្បញ្ញត្តិ ជាទូទៅទទួលបាន ពិន្ទុខ្សោយលើការផ្តល់មតិយោបល់ នៅក្នុងការស្ទង់មតិ OBS។

<u>អាជ្ញាធរសវនកម្ម</u>

ផ្នែកនៃការស្ទង់មតិ OBS ដែលផ្តោតលើការចូលរួមជាមួយនិងរបស់អាជ្ញាធរសវនកម្មជាតិ មានការផ្លាស់ប្តូរ ច្រើនក្នុងប៉ុន្មានឆ្នាំនេះ។ ប៉ុន្តែ ជាទូទៅផ្នែកសំខាន់ទាំងបួនក្នុងការស្ទង់មតិនេះគឺ: (១) ថាតើក្រុមប្រឹក្សាសវនកម្មរដ្ឋ (SAB) មានយន្តការសម្រាប់ទទួលធាតុចូលសម្រាប់កម្មវិធី/ដំណើរការសវនកម្ម របស់ខ្លួនដែរឬទេ (២) ថាតើសាធារណជនអាចចូលរួមការស៊ើបអង្កេតសវនកម្មដែរឬទេ (៣) ថាតើក្រុមប្រឹក្សាសវនកម្មបានផ្តល់មតិយោបល់ត្រឡប់ទៅលើធាតុចូលដែលខ្លួនបានទទួលឬទេ និង (៤) ថាតើវាមានរក្សាយន្តការដើម្បី ផ្សព្វផ្សាយលទ្ធផលនៃសវនកម្មរបស់ខ្លួនដែរឬទេ។

នៅត្រង់ចំណុច ការចូលរួមរបស់សាធារណជននិងអង្គការសង្គមស៊ីវិល ក្នុងការស៊ើបអង្កេតសវនកម្មរបស់ខ្លួន ក្រុមប្រឹក្សាសវនកម្មទទួលបានពិន្ទុខ្សោយ ដោយសារតែខ្លួនមិនបានផ្តល់ឱកាសឱ្យពួកគេ ចូលរួមការស៊ើប អង្កេតនោះទេ។ មានបីចំណុចផ្សេងទៀតគឺមានភាពរីកចម្រើនច្រើន។ ដើម្បីទទួលធាតុចូលសម្រាប់កម្មវិធីឬដំណើរការសវនកម្មរបស់ខ្លួន ក្រុមប្រឹក្សាសវនកម្មមានវេបសាយផ្ទាល់ខ្លួនមួយដែលវេបសាយនេះមានមួយផ្នែក (http://www.bpk.go.id/formpage/complaints/) សម្រាប់ទទួលពាក្យបណ្តឹង និងមួយផ្នែកផ្សេង ទៀតសម្រាប់ការផ្តល់យោបល់អំពីបញ្ហានានា និងការស្នើប្រធានបទសម្រាប់កម្មវិធីសវនកម្មរបស់ខ្លួន។ វាក៏ មាន

[14] ប្រទេសឥណ្ឌូនេស៊ី ទទួលបានពិន្ទុខ្សោយលើការចូលរួមក្នុងសវនាការនីតិប្បញ្ញត្តិ នៅក្នុងការស្ទង់មតិពីរលើកដំបូង។ សាធារណជន មិនត្រូវបានអនុញ្ញាតឱ្យចូលរួម និងផ្តល់សក្ខីកម្មនោះទេ។ ពួកគេមិនដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុង សវនាការស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ហើយក៏មិនត្រូវបានផ្តល់ឱកាសផ្តល់ធាតុចូលក្នុងសវនការលើរបាយការណ៍ សវនកម្មផងដែរ។

មជ្ឈមណ្ឌលព័ត៌មាននិងទំនាក់ទំនងមួយនៅរដ្ឋធានី ហ្សាកាតា (ដូចដែលតម្រូវដោយច្បាប់ស្តីពីសិទ្ធិ ទទួលបានព័ត៌មាន) ដែលសាធារណជន អាចដាក់ពាក្យបណ្តឹងឬសំណូមពរដោយផ្ទាល់។ ចាប់ពីឆ្នាំ២០១៤ មក ក្រុមប្រឹក្សាសវនកម្មបានចេញរបាយការណ៍ព័ត៌មានស្តីពីមតិយោបល់ដែលខ្លួនបានទទួលទោះបីជា គុណភាពរបាយការណ៍ទាំងនេះ មិនសូវមានសង្គតិភាព និងមានការខ្វះខាតព័ត៌មានលម្អិតសំខាន់ៗមួយ ចំនួនក្តី (IBP, 2017e) ។ ហេតុដូច្នេះហើយទើបជាទូទៅ ប្រទេសឥណ្ឌូណេស៊ី បានទទួលពិន្ទុពេញ លើយន្តការដើម្បីផ្សព្វផ្សាយរបាយការណ៍សវនកម្មរបស់ខ្លួន ក្រៅពីការផ្សព្វផ្សាយវាជាសាធារណៈ។ ក្រុមប្រឹក្សា សវនកម្មក៏មានយន្តការមួយចំនួន និងសកម្មភាពផ្សព្វផ្សាយផ្សេងៗទៀត ដើម្បីផ្សព្វផ្សាយលទ្ធផលសវនកម្ម របស់ខ្លួនផងដែរ។ ក្រៅពីការចេញផ្សាយរបាយការណ៍សវនាកម្មលម្អិតជាទៀងទាត់ យន្តការសម្រាប់ការ ផ្សព្វផ្សាយផ្សេងៗទៀតរួមមាន វេបសាយ និងមជ្ឈមណ្ឌលព័ត៌មាននិងទំនាក់ទំនង (ដែលតាមរយៈនេះ សាធារណជនអាចសាកសួរអំពីការស៊ើបអង្កេតនិងរបាយការណ៍សវនកម្មបាន) និងការបោះពុម្ពផ្សាយសេចក្តី ជូនដំណឹង, ព្រឹត្តិប័ត្រ និងទស្សនាវដ្តី។

## ប្រទេសហ្វីលីពីន

<u>អង្គនីតិប្រតិបត្តិ</u>

ជាទូទៅ នីតិប្រតិបត្តិប្រទេសហ្វីលីពីន មានការអនុវត្តល្អៗច្រើន នៅក្នុងផ្នែកជាច្រើននៃការស្ទង់មតិ OBS ដែលជារួមមានៈ (១) តម្រូវការផ្លូវច្បាប់លើការចូលរួមជាសាធារណៈ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២) ការបង្ហាញជាមុននូវគោលបំណងនៃការចូលរួម និងការផ្តល់ព័ត៌មានជាមុន (៣) ការដាក់ការបញ្ចូល ការចូលរួមរបស់សាធារណជន និងអង្គការសង្គមស៊ីវិលក្នុងប្រតិទិនការរៀបចំថវិកា; (៤) ការបង្កើតយន្តការ ជាក់ស្តែង និងអាចរកបានដើម្បីកំណត់ទស្សនរបស់សាធារណជនអំពីអាទិភាពថវិកា ក្នុងអំឡុងពេលនៃ ការរៀបចំនិងការត្រួតពិនិត្យការអនុវត្តថវិកា (៥) ការចូលរួមជាសាធារណៈជាមួយក្រសួងពាក់ព័ន្ធនានាក្នុង ការរៀបចំនិងអនុវត្តថវិកា និង (៦) ការចូលរួមរបស់ក្រុមជនងាយរងគ្រោះក្នុងដំណើរការថវិកា (លើកលែងតែ ក្នុងការអនុវត្តថវិកា) ។

ប្រទេសហ្វីលីពីននៅមិនទាន់មានច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននោះទេ។ ប៉ុន្តែការទទួលបាននិងការ ចេញផ្សាយព័ត៌មានសាធារណៈ ត្រូវបានធានានៅក្នុងច្បាប់ដទៃទៀតរបស់ប្រទេសនេះ។ ជាអាទ៍ រដ្ឋ ធម្មនុញ្ញឆ្នាំ១៩៨៧ របស់ប្រទេសនេះបានផ្តល់សិទ្ធិឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានរបស់រដ្ឋាភិបាល និង សិទ្ធិក្នុងការត្រូវបានផ្តល់ព័ត៌មានអំពីផលប្រយោជន៍សាធារណៈ។ ក្រៅពីនេះ ច្បាប់ស្តីពីក្រមសីលធម៌ និង បទដ្ឋានក្រមសីលធម៌សម្រាប់មន្ត្រីនិងនិយោជិកសាធារណៈ តម្រូវឱ្យពួកគេបញ្ចេញឯកសារសាធារណៈ ក្នុង រយៈពេល១៥ថ្ងៃក្រោយការចូលជាធរមាននៃឯកសារទាំងនេះ។ ថ្វីបើមានអវត្តមាននៃច្បាប់ស្តីពីសិទ្ធិទទួល បានព័ត៌មានក្តី ក៏រដ្ឋាភិបាលហ្វីលីពីនបានផ្តល់ឱកាសឱ្យសាធារណជននិងអង្គការសង្គមស៊ីវិល បានចូលរួម ក្នុងការសម្រេចចិត្តរបស់ខ្លួនមួយកម្រិតធំ និងជាទូទៅវាបានទទួលពិន្ទុពេញលើចំណុចការទទួលបានព័ត៌មាន នៅក្នុងការស្ទង់មតិ OBS ។

ប្រជាពលរដ្ឋអាចទទួលបានព័ត៌មានហិរញ្ញវត្ថុនិងព័ត៌មានមិនមែនហិរញ្ញវត្ថុ ក្នុងទម្រង់សម្រាយទាក់ទង នឹងការចំណាយសម្រាប់កម្មវិធីនានាពីភ្នាក់ងាររដ្ឋាភិបាលជាច្រើន។

មិនដូចប្រទេសឥណ្ឌូនេស៊ីទេ ប្រទេសហ្វីលីពីន បានទទួលពិន្ទុល្អប្រសើរ (ពេញឬខ្ពស់ជាងមធ្យម) សម្រាប់ស្ទើរតែគ្រប់ការស្ទង់មតិ OBS ទៅលើការចូលរួមជាសាធារណៈ ជាមួយអង្គនីតិប្រតិបត្តិ ជាអាទ៍ទៅ លើចំណុចៈ (១) តម្រូវការផ្លូវច្បាប់សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ (២) ការបង្ហាញជាមុននូវគោលបំណងនៃការចូលរួមនិងការផ្តល់ព័ត៌មានជាមុន (៣) ការដាក់បញ្ចូលការចូលរួម របស់សាធារណជននិងអង្គការសង្គមស៊ីវិលក្នុងប្រតិទិនការរៀបចំថវិកា (៤) ការបង្កើតយន្តការជាក់ស្តែងនិង អាចរកបានដើម្បីកំណត់ទស្សនរបស់សាធារណជនអំពីអាទិភាពថវិកា និង(៥) ការចូលរួមរបស់ក្រុមជនងាយ រងគ្រោះក្នុងដំណើរការថវិកា (លើកលែងតែក្នុង ការអនុវត្តថវិកា) ។

មានការកត់សម្គាល់ល្អៗមួយចំនួនអំពីអង្គនីតិប្រតិបត្តិរបស់ប្រទេសហ្វីលីពីន។ ទីមួយ តម្រូវការផ្នែកច្បាប់នៃ ការចូលរួមជាសាធារណៈត្រូវបានចែងក្នុងច្បាប់មួយកម្រិតធំ។ គឺថាវាត្រូវបានធានាក្នុងលក្ខណៈទូលំទូលាយ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះ។ ក្រៅពីនេះ តាំងពីឆ្នាំ២០១២មក ក្រសួងថវិកានិងការគ្រប់គ្រង (DBM) ក៏បានលើកទឹកចិត្តដល់ភ្នាក់ងាររដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល នៅក្នុងការរៀបចំថវិការបស់ពួកគេ - តាមរយៈការចេញនូវអនុសារណៈថវិកាជាតិស្តីពីគោលការណ៍ណែនាំអំពីភាពជាដៃគូជាមួយ អង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងការរៀបចំសំណើថវិការបស់ភ្នាក់ងារនីមួយៗ[15] និងសារលិខិតអនុសារណៈរួមលើគោលការណ៍ណែនាំ និងនីតិវិធីគោលនយោបាយក្នុងការអនុវត្តដំណើរការរៀបចំថវិកានៅកម្រិតមូលដ្ឋានដែលមានលក្ខណៈចូលរួម (GPP) (IBP, 2012f)[16]។ កាលពីដំបូង គឺនៅឆ្នាំ២០១២ ការអនុវត្តនេះត្រូវបានសាកល្បងជាមួយក្រសួងចំនួន៦ និងសាជីវកម្មរដ្ឋាភិបាលចំនួន៣ប៉ុណ្ណោះ ខណៈដែលក្រសួងនិងសាជីវកម្មដទៃទៀត ត្រូវបានលើកទឹកចិត្ត ឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនៅលើមូលដ្ឋានស្ម័គ្រចិត្ត។ ការនេះត្រូវបានគេអនុវត្ត ជារៀងរាល់ឆ្នាំ តាមរយៈការចេញនូវអនុស្សរណៈយោគយល់និងសារលិខិតអនុស្សរណៈរួម និងត្រូវបានដាក់ ឱ្យដំណើរការទៅគ្រប់ភ្នាក់ងារនិងសាជីវកម្មរបស់រដ្ឋាភិបាល នាពេលក្រោយៗមក។ ការចូលរួមក្នុងការ អនុវត្តថវិកា ត្រូវ

[15] គំរូអនុសារណៈនេះ អាចរកបាននៅវេបសាយ https://www.dbm.gov.ph/wp-content/uploads/Issuances/2012/National%20Budget%20Circular/NBC536/NBC536.pdf និង https://www.dbm.gov.ph/wp-content/uploads/Issuances/2019/National-Budget-Memorandum/NBM-No-131-26Feb2019.pdf ទាញយកនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

[16] គំរូសារលិខិតអនុសារណៈរួម អាចរកបាននៅវេបសាយ https://www.dbm.gov.ph/index.php?pid=8&xid=28&id=38&page=#2012 ទាញយកនៅ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

បានចែងក្នុងសារាចរថវិកាជាតិស្តីពីគោលការណ៍ណែនាំស្តីពីភាពជាដៃគូជាមួយអង្គការសង្គម ស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការអនុវត្តថវិការបស់ទីភ្នាក់ងារនីមួយៗ និងអនុស្សារណៈថវិកាជាតិស្តីពី គោលការណ៍ណែនាំសម្រាប់ការអនុវត្តនិងតាមដានគម្រោងថវិកាដែលមានការចូលរួមរបស់ប្រជាជននៅមូលដ្ឋាន[17]។ គួរកត់សម្គាល់ផងដែរថា គោលការណ៍ណែនាំទាំងនេះគឺជាបទបញ្ញានីតិប្រតិបត្តិ ដែលចេញដោយ អង្គនីតិប្រតិបត្តិ ហើយមិនមែនជាច្បាប់នោះទេ[18]។

ទីពីរ ក្នុងកិច្ចពិភាក្សាជាមួយអង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត គោលបំណងនៃការចូលរួមគឺមាន ភាពច្បាស់លាស់ និងត្រូវបានជូនដំណឹងទៅពួកគេជាមុននិងដោយទាន់ពេលវេលា តែចំនួនប្រធានបទដែល បានគ្របដណ្តប់ក្នុងកិច្ចពិភាក្សា គឺមានកម្រិតនៅឡើយ។ លិខិតអញ្ជើញពីក្រសួង ថវិកានិងការគ្រប់គ្រងមិនគ្រាន់តែបង្ហាញពីគោលបំណងនៃកិច្ចប្រជុំប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានចែងនូវ ការណែនាំអំពីរបៀបចូលរួម ហើយលិខិតនេះក៏ត្រូវបានបង្ហោះនៅលើវេបសាយរបស់ក្រសួងមុនការប្រជុំផងដែរ។ ភ្នាក់ងាររដ្ឋាភិបាលមួយ ចំនួនបានចុះកិច្ចព្រមព្រៀងជាផ្លូវការជាមួយអង្គការសង្គម ស៊ីវិលដែលខ្លួនបានជ្រើសរើស ហើយកិច្ចព្រមព្រៀង ភាពជាដៃគូថវិកា (BPA)[19] នេះបានបង្ហាញពី គោលបំណង វិសាលភាព និងតួនាទីនិងការទទួល ខុសត្រូវរបស់ភ្នាក់ងារសាមុីនិងក្រុមអង្គការសង្គម ស៊ីវិល មុនពេលពិគ្រោះយោបល់កើតឡើង (IBP, 2012f) ។ នាពេលបច្ចុប្បន្ន ភាពខ្វះខាតមួយនៃយន្តការនេះ គឺថាការពិភាក្សាមិនបានគ្របដណ្តប់លើប្រធានបទ ទាក់ទងនឹងថវិកាសំខាន់ៗទាំង៦ ដែលមាននៅក្នុងការស្ទង់មតិOBSនោះទេ ពោលគឺវាគ្រប់ដណ្តប់តែលើ ប្រធានបទចំនួន២តែប៉ុណ្ណោះ - គឺការចំណាយសង្គម និងគម្រោងវិនិយោគសាធារណៈ - ទាំងនៅក្នុងកិច្ចព្រម ព្រៀងភាពជាដៃគូថវិកា និងកិច្ចប្រជុំពិនិត្យតាមដានការអនុវត្តថវិកាជាក់ស្តែង។ យន្តការចូលរួមជាសាធារណៈ ផ្សេងៗទៀត នៅក្នុងដំណើរការថវិកាដែលរៀបចំឡើងដោយក្រសួងថវិកានិងការគ្រប់គ្រង រួមមានវេទិកាថវិកា របស់ប្រជាពលរដ្ឋ វេទិកាជាមួយអង្គការសង្គមស៊ីវិល និងវេទិកាភាពជាដៃគូបើកចំហ របស់រដ្ឋាភិបាល។ ហើយមុនពេលមានកិច្ចប្រជុំពិគ្រោះយោបល់ទាំងនេះ គោលបំណង និងវិសាលភាពនៃកិច្ចប្រជុំត្រូវបានជូន ដំណឹងទៅដល់ភាគីពាក់ព័ន្ធជាមុន។ រដ្ឋាភិបាលក៏បាន

---

[17] គំរូអនុស្សារណៈ អាចរកបាននៅវេបសាយ http://omcrs.nia.gov.ph/?q=content/mc-2014-014 ទាញយកនៅ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៩។

[18] នៅពាក់កណ្តាលឆ្នាំ២០១៨ ព្រឹទ្ធសភាប្រទេសហ្វីលីភីន បានផ្តួចផ្តើមបង្កើតច្បាប់ស្តីពីការកំណត់ការចូលរួមរបស់ ប្រជាពលរដ្ឋ នៅក្នុងដំណើរការថវិកា ការកំណត់សមូហភាព និងសម្រាប់គោលបំណងផ្សេងទៀត។ ក្នុងពេលបច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់នេះកំពុងរង់ចាំការពិនិត្យឡើងវិញពីគណៈកម្មាធិការពាក់ព័ន្ធនៃព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់នេះ អាច ទាញយកបានពីវេបសាយ http://www.senate.gov.ph/lisdata/2778424053?pedf= ទាញយកនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៩។

[19] គំរូកិច្ចព្រមព្រាងរវាងភ្នាក់ងាររដ្ឋាភិបាលនីមួយៗជាមួយអង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត អាចរកបាននៅវេបសាយ http://www.nia.gov.ph/?q=budget-partnership-agreement ឬ http://philssa.org.ph/wp-content/uploads/2013/09/BPA_PHILSSA-2013-2015.pdf ទាញយកនៅ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

បង្កើតបរិយាកាស អនុគ្រោះដល់ប្រជាពលរដ្ឋនិង អង្គការសង្គមស៊ីវិល ដើម្បីចូលរួមតាមរយៈអនឡាញផងដែរ ជាឧទាហរណ៍ តាមរយៈការបង្កើតនិងការចូល រួមតាមវេបផតថល OpenBuB (www.openbub.gov.ph) សម្រាប់ការអនុវត្ត និងការត្រួតពិនិត្យថវិកា[20]។

មកទល់ឆ្នាំ២០១០ ប្រទេសហ្វីលីពីនបានទទួលពិន្ទុខ្សោយលើការចូលរួមរបស់សាធារណជន និងអង្គការ សង្គមស៊ីវិលនៅក្នុងការរៀបចំការអនុវត្ត និងការត្រួតពិនិត្យថវិកាជាតិរបស់ខ្លួន។ មុនឆ្នាំ២០១០ ការពិគ្រោះយោបល់ជាមួយសាធារណជននិងអង្គការសង្គមស៊ីវិលមួយចំនួន គ្របដណ្តប់តែលើបញ្ហាអភិវឌ្ឍន៍ទូទៅ តាមរយៈការចូលរួមរបស់ពួកគេជាមួយអាជ្ញាធរជាតិសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (NEDA) និងលើកម្មវិធីមួយចំនួន (លើកលែងតែការៀបចំថវិកា) នៃក្រសួងមួយចំនួន (OBI, 2010)។ ការចូលរួមនេះត្រូវបានធ្វើឱ្យកាន់តែស៊ី ជម្រៅនិងជាប្រព័ន្ធ តាមរយៈការចេញសេចក្តីណែនាំគោលនយោបាយមួយចំនួនខាងលើ។ ក្នុងចំណោម ការងារដទៃទៀត តាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូថវិកា អង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀតបាន ចូលរួមកំណត់អាទិភាពថវិកាប្រចាំឆ្នាំរបស់ភ្នាក់ងាររដ្ឋាភិបាលកណ្តាលនានា។ ភ្នាក់ងាររដ្ឋាភិបាលនីមួយៗក៏ មានបណ្តាញទូរស័ព្ទបន្ទាន់ ដែលប្រជាពលរដ្ឋអាចផ្ញើយោបល់ សំនួរ និងសំណូមពរ មកកាន់ពួកគេ និងមានវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបើកចំហឱ្យសាធារណជនចូលរួមផងដែរ។ តាមរយៈគោលការណ៍ ណែនាំ និងនីតិវិធីស្តីពីដំណើរការការរៀបចំថវិកានៅកម្រិតមូលដ្ឋានដែលមានលក្ខណៈចូលរួម (GPP) អង្គការសង្គម ស៊ីវិលក្នុងស្រុកនិងអ្នកពាក់ព័ន្ធដទៃទៀត រួមទាំងសមាគមធុរកិច្ចនៅមូលដ្ឋាន និងអ្នកតំណាង ក្រុមដែលមិន សូវបានគេយកចិត្តទុកដាក់ មិនត្រឹមតែត្រូវបានគេពិគ្រោះយោបល់ជាមួយលើអាទិភាពថវិកា ប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងអាចចូលរួមសម្រេចលើសំណើថវិកាថែមទៀតផង។ ការរៀបចំថវិកានៅកម្រិតមូលដ្ឋាន ដែលមានលក្ខណៈចូលរួម តម្រូវឱ្យមានការបង្កើតក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រក្នុងតំបន់ (LPRATs) នៅមូលដ្ឋាននីមួយៗ ដើម្បីកំណត់គម្រោងអាទិភាពនៅមូលដ្ឋានដែលនឹងត្រូវដាក់បញ្ចូលទៅ ក្នុងសំណើរ ថវិការរបស់ភ្នាក់ងាររដ្ឋាភិបាលកណ្តាល និងសាជីវកម្មរដ្ឋាភិបាលពាក់ព័ន្ធនានា។ ក្រុមសកម្មភាពកាត់បន្ថយ ភាពក្រីក្រក្នុងតំបន់ មានតំណាងស្មើៗគ្នាពីតំណាងរដ្ឋាភិបាល និងអ្នកតំណាងអង្គការសង្គមស៊ីវិល ដោយក្នុង នោះមានម្នាក់ក្នុងចំណោមពួកត្រូវធ្វើជាសហប្រធាននៃក្រុមនេះ។ តំណាងអង្គការសង្គមស៊ីវិលទាំងនេះអាច បោះឆ្នោតក្នុងការកំណត់គម្រោងអាទិភាពរបស់ក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រក្នុងតំបន់។ ដើម្បីឱ្យសំណើ ថវិការបស់ការិយាល័យអាចបញ្ជូនទៅថ្នាក់កណ្តាលបាន ភ្នាក់ងារថ្នាក់តំបន់និង សាជីវកម្មរដ្ឋាភិបាលត្រូវការ ការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់ (RDCs) រៀងៗខ្លួន។ តាមការកំណត់២៥% នៃសមាជិករបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់ ត្រូវមកពីវិស័យឯកជន[21]។ ក្នុងការដាក់

---

[20] សម្រាប់ព័ត៌មានផ្សេងៗទៀតនិងព័ត៌មានលម្អិតទាក់ទងនឹងគំនិតផ្តួចផ្តើមនានាដើម្បីកែលម្អតម្លាភាព និងការចូលរួមជាសាធារណៈ សូមមើល Magno, F. A. (2015). "*Public Participation and Fiscal Transparency in the Philippines.*" ចេញផ្សាយដោយ គំនិតផ្តួចផ្តើមសកលសម្រាប់តម្លាភាពសារពើព័ន្ធ (GIFT) ។

[21] សម្រាប់ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់ សូមមើលវេបសាយ http://caraga.neda.gov.ph/regional-development-council/composition-2/ ទាញយកនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨។

សំណើគម្រោងថវិកា ទៅក្រសួងថវិកានិង ការគ្រប់គ្រង ទីភ្នាក់ងារថ្នាក់កណ្តាល និងសាជីវកម្មនីមួយៗត្រូវបាន តម្រូវឱ្យបញ្ចូល និងដាក់ជូនក្រសួងនេះ នូវទម្រង់រៀបចំថវិកា ដែលមានរបាយការណ៍អំពីធាតុចូល អនុសាសន៍ និងការផ្តល់យោបល់ត្រលប់ ពីអង្គការ សង្គមស៊ីវិលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលខ្លួនបានពិគ្រោះយោបល់ ជាមួយ ។

ប្រទេសហ្វីលីពីន បានពិន្ទុលើមធ្យម សម្រាប់ការចូលរួមជាសាធារណៈ ក្នុងការអនុវត្ត និងការឃ្លាំមើលការ អនុវត្តថវិការបស់ខ្លួន ដែលរួមមាន (១) ការកំណត់ទស្សនៈរបស់សាធារណជនក្នុងការអនុវត្តថវិកា (២) ចំនួនប្រធានបទដែលបានពិភាក្សាជាមួយសាធារណជននិងអង្គការសង្គមស៊ីវិល និងការផ្តល់ព័ត៌មានមុនកិច្ចប្រជុំ និង (៣) ការត្រួតពិនិត្យការអនុវត្តថវិកា។ ជាទូទៅយន្តការសំខាន់ៗដែលប្រើប្រាស់សម្រាប់ការរៀបចំ ថវិកាជាតិ ក៏ត្រូវបានគេប្រើសម្រាប់ការអនុវត្ត និងតាមដានអនុវត្តថវិកាផងដែរ ដែលយន្តការទាំងនេះរួមមានកិច្ចព្រម ព្រៀងភាពជាដៃគូថវិកា ក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់ និងក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រក្នុងតំបន់។ ជា ឧទាហរណ៍ ភ្នាក់ងាររដ្ឋាភិបាលដែលបានចុះ កិច្ចព្រមព្រៀងភាពជាដៃគូថវិកាជាមួយអង្គការសង្គមស៊ីវិលត្រូវ បានគេតម្រូវឱ្យផ្តល់ព័ត៌មានដល់អ្នកទាំងនោះ ដើម្បីជួយឱ្យពួកគេបង្កើតការវាយតម្លៃគម្រោង និងកម្មវិធីរបស់ ក្រសួងសាមីដោយផ្អែកលើភស្តុតាង។ នៅក្រោមបទបញ្ជានីតិបញ្ញត្តិលេខ៣២៥ស្តីពីការរៀបចំឡើងវិញនៃក្រុម អភិវឌ្ឍន៍តំបន់ ក្រុមប្រឹក្សានេះត្រូវបានផ្តល់ភារកិច្ចជាអ្នកសម្របសម្រួល ការតាមដាននិងវាយតម្លៃគម្រោង អភិវឌ្ឍន៍ក្នុងតំបន់របស់ខ្លួន។ នៅក្រោមកិច្ចព្រមព្រៀងភាពជាដៃគូថវិកា អង្គការសង្គមស៊ីវិលអាចចូលរួមក្នុងការត្រួតពិនិត្យតាមដាន និងការពិនិត្យឡើងវិញ នូវការអនុវត្តថវិកាដែលបានអនុម័តក្រោមយន្តការក្រុម សកម្មភាពកាត់បន្ថយភាពក្រីក្រក្នុងតំបន់។ វេបសាយ បណ្តាញទូរស័ព្ទ និងបណ្តាញសង្គម ដែលបានរៀបរាប់ ខាងលើត្រូវបានគេប្រើប្រាស់ ដើម្បីបម្រើការតាមដានការអនុវត្ត និងត្រួតពិនិត្យការអនុវត្តថវិកាផងដែរ។ ក្រសួង ថវិកានិងការគ្រប់គ្រង ក៏មានគំនិតផ្តួចផ្តើមដទៃទៀតដើម្បីឱ្យ សាធារណជនអាចតាមដានពិនិត្យមើលការ អនុវត្តថវិកា និងការឃ្លាំមើលការអនុវត្តថវិកាផងដែរ។ ឧទាហរណ៍មួយគឺ ការតម្រូវឱ្យគ្រប់ក្រសួង និងភ្នាក់ងារ របស់រដ្ឋាភិបាលបិទប្រកាសនូវព័ត៌មានមូលដ្ឋានសំខាន់ៗមួយចំនួនអំពីគម្រោងនិងកម្មវិធីរបស់ពួកគេនៅលើ វេបសាយរបស់ខ្លួន ដូចដែលមានចែងក្នុងច្បាប់ស្តីពីមូលធនទូទៅឆ្នាំ២០១១ ហើយការមិនអនុលោមតាម ច្បាប់នេះអាចបណ្តាល ឱ្យមានការផ្អាកគម្រោង/កម្មវិធីរបស់ខ្លួន (IBP, 2012f) ។ វេបផតថល OpenBuB ក៏បានអនុញ្ញាត ឱ្យសាធារណជនតាមដាននិងផ្តល់យោបល់លើការអនុវត្តគម្រោងសកម្មផងដែរ។ ទោះបីជា មានវឌ្ឍនភាពជាច្រើនក្នុងប៉ុន្មានឆ្នាំកន្លងមកក្តី ប្រទេសហ្វីលីពីននៅជួបប្រទះនូវបញ្ហាមួយចំនួន ដែលរួម មាន កង្វះច្បាប់ដែលផ្តោតលើយន្តការជាប្រព័ន្ធសម្រាប់ការចូលរួមជាសាធារណៈ ការចូលរួមនៃក្រុមជនដែលងាយ រងគ្រោះក្នុងការអនុវត្តថវិកានិងការត្រួតពិនិត្យការអនុវត្តថវិកានៅមានកំរិត និងការប្រជុំមិនទៀងទាត់របស់ក្រុម សកម្មភាពកាត់បន្ថយភាពក្រីក្រក្នុងតំបន់(IBP, 2012f, IBP, 2017f, Capistrano, 2017, Magno, 2015)។

ក្រសួងជាច្រើនបានប្រើប្រាស់យន្តការចូលរួម ដើម្បីឱ្យសាធារណជនផ្តល់ធាតុចូលនៅក្នុងការរៀបចំ និងការ អនុវត្តថវិការបស់ពួកគេ។ ឧទាហរណ៍មួយគឺកម្មវិធី CheckMySchool ដែលជាកិច្ចសហការ រវាងក្រសួងអប់រំ និងបណ្តាញគណនេយ្យភាពសង្គមនៅអាស៊ីបូព៌ា (ANSA-EAP) និងមូលនិធិប៉ាស៊ីហ្វិក ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមក្នុងការអនុវត្តថវិកាសម្រាប់គម្រោងកែលម្អសាលារៀនរបស់ក្រសួងអប់រំ (IBP, 2017f) ។ ឧទាហរណ៍មួយទៀត គឺការសហការគ្នារវាងក្រសួងអប់រំនិងបណ្តាអង្គការសង្គមស៊ីវិលមួយចំនួន ដើម្បីត្រួត ពិនិត្យលទ្ធកម្មសៀវភៅពុម្ព ដែលធ្វើឱ្យ មានការចែកចាយសៀវភៅដោយប្រើរយៈពេលខ្លីជាងមុន ការបោះពុម្ពសៀវភៅដែលមានគុណភាពល្អជាងមុន និងការលុបបំបាត់ការចែកចាយសៀវភៅខ្មោច (Merchessault, មិនមានឆ្នាំ, ទំព័រទី ១៥) ។

ការផ្តល់មតិយោបល់លើធាតុចូល ដែលភ្នាក់ងាររដ្ឋាភិបាលទទួលបានពីសាធារណជន និងអង្គការសង្គម ស៊ីវិល គឺជារឿងមួយដែលត្រូវការការកែលម្អខ្លះៗ។ **ទោះបីជា**ប្រទេសហ្វីលីពីនទទួលបានពិន្ទុខ្ពស់លើការចូលរួមជាសាធារណៈក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកាក៏ដោយ ក៏ពិន្ទុលើការផ្តល់មតិយោបល់ត្រលប់លើការប្រើប្រាស់ធាតុចូលពីសាធារណៈ ដើម្បីរៀបចំនិងអនុវត្តថវិកា គឺបានទាបជាងមធ្យម នៅឆ្នាំ ២០១២ និងឆ្នាំ២០១៥ និងបានសូន្យនៅឆ្នាំ២០១៧។ ការស្ទង់មតិនៅឆ្នាំ២០១២ និងឆ្នាំ២០១៥ បានបង្ហាញថា ប្រទេសនេះបានចេញសេចក្តីសង្ខេបនៃលទ្ធផលពីការពិគ្រោះយោបល់ ដែលគ្មានព័ត៌មាន លម្អិតគ្រប់គ្រាន់ និងមិនបានចេញអ្វីទាល់តែសោះនៅក្នុងការស្ទង់មតិនៅឆ្នាំ២០១៧។ អនុស្សារណៈស្តីពី ថវិកាជាតិ តម្រូវឱ្យភ្នាក់ងាររដ្ឋាភិបាលនិងសាជីវកម្មរដ្ឋ ផ្តល់ជូនអង្គការ សង្គមស៊ីវិលជាដៃគូនូវលទ្ធផលនៃការ ពិគ្រោះយោបល់ភ្លាមៗបន្ទាប់ពីការដាក់សំណើគម្រោងថវិកា ទៅក្រសួងថវិកានិងការគ្រប់គ្រង និងបញ្ចេញ ឯកសារមួយដែលមានចំណងជើងថា "សេចក្តីសង្ខេបនៃ មតិយោបល់ត្រលប់ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិលលើកម្មវិធីនិងគម្រោងកំពុងដំណើរការ"។ ក្រៅពីនេះ ក្រសួងថវិកានិងការគ្រប់គ្រង ក៏អាច ធ្វើការពិភាក្សាជាក្រុមដាច់ដោយឡែក ឬ ការប្រជុំពិនិត្យឡើងវិញជាមួយភ្នាក់ងារសាមីនិងបណ្តាអង្គការសង្គម ស៊ីវិលដើម្បីពិភាក្សាពីលទ្ធផលនៃការពិគ្រោះយោបល់ និងប្រសិទ្ធភាពនៃយន្តការនានាផងដែរ (IBP, 2012f)។ បញ្ហាពាក់ព័ន្ធមួយ គឺថាអង្គការសង្គមស៊ីវិលដែលមិនមានបណ្តាញនៅថ្នាក់ជាតិ អាចមិនបានទទួល មតិយោបល់ត្រលប់ពីភ្នាក់ងារសាមី ហើយក្រុមសកម្មភាពកាត់បន្ថយភាពក្រីក្រក្នុងតំបន់ អាចមិនទទួលបាន របាយការណ៍អំពីការប្រើប្រាស់ធាតុចូលរបស់ពួកគេ (IBP, 2015f) ។

<u>អង្គនីតិប្បញ្ញត្តិ</u>

ឱកាសសម្រាប់សាធារណជន ក្នុងការចូលរួមសវនាការនីតិប្បញ្ញត្តិ ជាទូទៅគឺនៅមានកំណត់នៅឡើយ។ ចំណុចពីរដែលប្រទេសនេះ ធ្វើបានល្អគ្រាន់បើ គឺការបើកសវនាការជាសាធារណៈលើ ក្របខ័ណ្ឌ ម៉ាក្រូសេដ្ឋកិច្ច

និងសារពើពន្ធ ដែលក្នុងនោះសាធារណជនត្រូវបានផ្តល់ឱកាសខ្លះៗឱ្យចូលរួមសវនការ និង សវនាការស្តីពីថវិការបស់ភ្នាក់ងារថ្នាក់កណ្តាលនីមួយៗ ដែលក្នុងនោះអង្គនីតិ ប្រតិបត្តិផ្តល់សក្ខីកម្ម។ មានការរីកចម្រើនមួយកម្រិតធំផ្សេងទៀតដែលរួមមានការចូលរួមជាសាធារណៈ នៅក្នុងសវនាការស្តីពីថវិការបស់ ភ្នាក់ងារថ្នាក់កណ្តាលនីមួយៗ សវនាការស្តីពីរបាយការណ៍សវនកម្ម និងការផ្តល់មតិយោបល់ត្រលប់ដែលមានលក្ខណៈទូលំទូលាយទៅលើសវនាការ ។

អង្គនីតិប្បញ្ញត្តិរបស់ប្រទេសហ្វីលីពីន ជាទូទៅផ្តល់នូវឱកាសទូលំទូលាយសម្រាប់សាធារណជន និងអង្គការ សង្គមស៊ីវិលចូលរួមក្នុងសវនាការស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធរបស់ខ្លួន។ សម្រាប់សវនាការនីតិបញ្ញត្តិ ដែលក្នុងនោះមានការផ្តល់សក្ខីកម្មរបស់អង្គនីតិប្រតិបត្តិ និងសាធារណជនស្តីពីក្របខ័ណ្ឌ ម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ គឺវាបានពិន្ទុល្អ គឺពិន្ទុពេញ សម្រាប់ឆ្នាំ២០០៦ និងលើមធ្យម សម្រាប់ឆ្នាំ២០១០ ឆ្នាំ២០១២ និងឆ្នាំ២០១៥ លើកលែងតែក្នុងឆ្នាំ២០០៨ប៉ុណ្ណោះដែលវាបានពិន្ទុទាប ជាងមធ្យម។ ការទទួល បានពិន្ទុមិនពេញ គឺដោយសារតែសាធារណជនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការ ប៉ុន្តែមិនត្រូវបាន ផ្តល់ឱកាសឱ្យចូលរួមការពិភាក្សាឬផ្តល់សក្ខីកម្មនោះទេ។ ចាប់ពីឆ្នាំ២០១០មក ពិន្ទុលើចំនុចនេះបានកើន ឡើង មួយផ្នែកដោយសារតែការបង្កើតគំនិតផ្តួចផ្តើមថវិកាជំនួស (ABI) ដែលជាសម្ព័ន្ធអង្គការសង្គមស៊ីវិល ធ្វើការលើបញ្ហាថវិកា។ ចាប់តាំងពីពេលបង្កើតមក វាបានគាំទ្រការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការចំណាយខ្ពស់លើវិស័យសង្គម និងការដោះស្រាយបញ្ហាហិរញ្ញវត្ថុដែល ទាក់ទងទៅនឹងគោលដៅអភិវឌ្ឍន៍សហសវត្ស (MDGs)។ រហូតមកដល់ពេលនេះ វាបានធ្វើឱ្យមានការចូលរួម របស់អង្គការសង្គមស៊ីវិលមួយចំនួននៅក្នុងកិច្ចការថវិកានៅសភា (IBP, 2008f) ។ ជាឧទាហរណ៍ នៅឆ្នាំ ២០១២ និងឆ្នាំ២០១៣ សវនការដោយឡែកមួយត្រូវបានរៀបចំដោយគណៈកម្មាធិការមូលធន (the House Committee on Appropriations) ដែលក្នុងនោះ អង្គការសង្គមស៊ីវិល រួមទាំងABIផងត្រូវបានអនុញ្ញាត ឱ្យបង្ហាញគម្រោងថវិកាជំនួស និងផ្តល់នូវទស្សនរបស់ពួកគេលើការសន្មត់ម៉ាក្រូសេដ្ឋកិច្ច ដែលបានប្រើនៅ ក្នុងសំណើថវិកាជាតិ (IBP, 2012f, IBP, 2015f) ។

អង្គនីតិបញ្ញត្តិ បានធ្វើសវនការជាសាធារណៈយ៉ាងទូលំទូលាយ លើថវិការបស់ភ្នាក់ងារថ្នាក់កណ្តាលនីមួយៗ ដែលក្នុងនោះអង្គនីតិប្រតិបត្តិត្រូវផ្តល់សក្ខីកម្ម។ នៅលើចំនុចនេះ វាបានទទួលពិន្ទុពេញនៅគ្រប់ការស្ទង់មតិ OBS ទាំងអស់។ សវនការទាំងនេះ ក៏ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកផងដែរ។នៅក្នុងសវនការមួយចំនួនអង្គការសង្គមស៊ីវិលត្រូវបានអនុញ្ញាតឱ្យចូលរួមជាអ្នកសង្កេតការណ៍។

បញ្ហាចម្រូងចម្រាសមួយ គឺការចូលរួមរបស់សាធារណជននិងអង្គការសង្គមស៊ីវិលនៅក្នុងសវនការនេះ។ ជាទូទៅ ប្រទេសនេះទទួលបានពិន្ទុទាបលើចំនុចនេះ ដោយសារតែសក្ខីកម្មពីសាធារណជន និងអង្គការសង្គម ស៊ីវិលនៅមានកម្រិតទាប។ វាទទួលបានពិន្ទុសូន្យនៅក្នុងការស្ទង់មតិពីរលើកដំបូង។ ពិន្ទុលើចំនុចនេះ

ទើប មានភាពប្រសើរខ្លះ ចាប់ពីឆ្នាំ២០១០មក មួយផ្នែកដោយសារតែការតស៊ូមតិពីABI ដូចដែលបានពិភាក្សាខាងលើ។ ឆ្នាំ២០១០ គឺជាឆ្នាំតែមួយគត់ដែលវាបានពិន្ទុខ្ពស់ជាងមធ្យម ដោយសារតែការផ្តល់ឱកាសសម្រាប់អង្គការសង្គមស៊ីវិលបង្ហាញសំណើថវិកាជំនួស។ នៅក្នុងការស្ទង់មតិជាបន្តបន្ទាប់ ពិន្ទុរបស់វាលើសំណួរនេះ ត្រូវបានធ្លាក់ចុះ (ក្រោមមធ្យម) ដោយសារតែការផ្តល់ឱកាសតិចតួច សម្រាប់អង្គការសង្គមស៊ីវិលផ្តល់ សក្ខីកម្មនិងសួរសំណួរ។

នៅឆ្នាំ ២០១៧ ការស្ទង់មតិ OBS បានសួរអំពីសវនាការនីតិប្បញ្ញត្តិ និង/ឬ ប្រើប្រាស់យន្តការចូលរួមផ្សេងៗទៀតលើរបាយការណ៍សវនកម្ម ដែលសាធារណជនត្រូវបានអនុញ្ញាតឱ្យផ្តល់ធាតុចូលក្នុងកំឡុងពេលពិគ្រោះយោបល់។ ប្រទេសនេះទទួលបានពិន្ទុខ្សោយលើចំនុចនេះ ដោយសារតែគណៈកម្មាធិការសភាមិនបានរៀបចំសវនាការអំពីរបាយការណ៍សវនកម្ម ដែលសាធារណជនឬ អង្គការសង្គមស៊ីវិលត្រូវបានអញ្ជើញឱ្យផ្តល់សក្ខីកម្មនោះទេ។

អង្គនីតិប្បញ្ញត្តិ ជាទូទៅទទួលបានពិន្ទុខ្សោយសម្រាប់ការផ្តល់មតិយោបល់ត្រលប់ដល់សាធារណជនទៅលើ សវនាការរបស់ខ្លួន តាមរយៈការចេញរបាយការណ៍ទូលំទូលាយស្តីពីសវនការនោះ ដោយសារតែខ្លួនមិនដែល បានចេញរបាយការណ៍បែបនេះទេ។ នៅឆ្នាំ២០១៥ គណៈកម្មាធិការមូលធន (the House Committee on Appropriations) និងគណៈកម្មាធិការហិរញ្ញវត្ថុព្រឹទ្ធសភា បានចេញសេចក្តីសង្ខេបលទ្ធផល នៃការពិភាក្សាជាមួយសាធារណជននិងអង្គការសង្គមស៊ីវិល ហើយព្រឹទ្ធសភាក៏បានចេញរបាយការណ៍ស្តីពីលទ្ធផល សវនាការថវិកាផងដែរ (IBP, 2015f)។ ជាការអនុវត្តទូទៅ ប្រធានគណៈកម្មាធិការនីមួយៗ តែងតែធ្វើសន្និសិទ ព័ត៌មានឬការសម្ភាសតាមប្រព័ន្ធផ្សព្វផ្សាយ អំពីដំណើរការសវនាការរបស់ខ្លួន។ ប៉ុន្តែយន្តការទាំងនេះមិនបាន ផ្តល់ព័ត៌មានទូលំទូលាយអំពីសវនាការនោះទេ។ ព័ត៌មានបន្ថែម ដូចជារបាយការណ៍ របស់គណៈកម្មាធិការ និងកំណត់ហេតុផ្លូវការ គឺអាចស្នើសុំពីអង្គនីតិបញ្ញត្តិបាន តែការឆ្លើយតបមកវិញអាចត្រូវការពេលច្រើន (IBP, ២០១៥f) ។

<u>អាជ្ញាធរសវនកម្មជាតិ</u>

គណៈកម្មាធិការសវនកម្ម (COA) របស់ប្រទេសហ្វីលីពីន ធ្វើបានល្អលើពីរចំនុច គឺការរក្សាយន្តការទំនាក់ ទំនងផ្លូវការជាមួយសាធារណជនក្នុងការទទួលធាតុចូលពីពួកគេ សម្រាប់កម្មវិធី/ដំណើរការសវនកម្មរបស់ខ្លួន និងការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការស៊ើបអង្កេតសវនកម្មសមិទ្ធកម្មការងារ។ រឿងពីរទៀតដែលត្រូវ ធ្វើឱ្យប្រសើរឡើងជាងពេលបច្ចុប្បន្នគឺ: យន្តការដើម្បីធ្វើឱ្យរបាយការណ៍សវនកម្ម ត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយក្រៅពីការធ្វើឱ្យសាធារណជនទទួលបានរបាយណ៍នេះ និងការផ្តល់មតិយោបល់ត្រលប់លើធាតុចូលពីសាធារណជនចំពោះពាក្យបណ្តឹង របស់ពួកគេ។

គណៈកម្មាធិការសវនកម្ម បានរក្សាយន្តការទំនាក់ទំនងជាផ្លូវការដើម្បីទទួលបាននូវធាតុចូលសម្រាប់ កម្មវិធី ឬដំណើរការសវនកម្មរបស់ខ្លួន។ ដូច្នេះហើយបានជាវាបានទទួលពិន្ទុពេញ ឬលើមធ្យមនៅលើ ចំណុចនេះ (ពិន្ទុមិនពេញដោយសារតែយន្តការមួយចំនួន មិនត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយពី សំណាក់សាធារណជន)។ នៅលើវេបសាយរបស់គណៈកម្មាធិការសវនកម្ម មានផ្នែកមួយដែលហៅថា "រាយការ ការបន្លំ" (Fraud Alert) អាសយដ្ឋានអ៊ីម៉ែល និងខ្សែទូរស័ព្ទ សម្រាប់សាធារណជន ទាក់ទងគណៈកម្មការនេះ រួមទាំងការដាក់ពាក្យបណ្តឹងឬការផ្តល់យោបល់ផងដែរ។ វាក៏មាន ការិយាល័យប្រជាពលរដ្ឋ (Citizens' Desk) (https://pis.coa.gov.ph) ដែលមុខងាររបស់វារួមមានការទទួលពាក្យបណ្តឹងដែរ។ ធាតុចូលដែល ទទួល បាន ត្រូវបានប្រើប្រាស់ដើម្បីពង្រឹងកម្មវិធីសវនកម្ម របស់ខ្លួន។

មិនដូចប្រទេសឥណ្ឌូនេស៊ីទេ ប្រទេសហ្វីលីពីន បានផ្តល់ឱកាសដល់សាធារណជនចូលរួមក្នុងការស៊ើប អង្កេតសវនកម្មរបស់ខ្លួន។ វាបានទទួលពិន្ទុពេញនៅលើចំណុចនេះ។ មានយន្តការសម្រាប់សាធារណជន និង អង្គការសង្គមស៊ីវិល ចូលរួមការស៊ើបអង្កេតសវនកម្មសមិទ្ធិកម្មការងាររបស់ខ្លួន ហើយយន្តការនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយអង្គការសង្គមស៊ីវិលនៅក្នុងគម្រោង ធ្វើការរួមគ្នាសាកល្បងមួយ ដែលបានចាប់ផ្តើមកាលពីឆ្នាំ២០១២។ ការជូនដំណឹងអំពីការបន្លំនិង សំណើសវនកម្មអាចធ្វើឡើងតាមរយៈ ការិយាល័យសវនកម្មការបន្លំ (the Fraud Audit Office) ឬការិយាល័យប្រជាពលរដ្ឋ ដោយផ្ទាល់ ឬនៅលើវេបសាយរបស់គណៈកម្មាធិការនេះ។ ច្បាប់ស្តីពីសវនកម្មរដ្ឋរបស់ប្រទេស ហ្វីលីពីន មិនបាននិយាយ ពីការចូលរួមរបស់សាធារណជននៅក្នុងការស៊ើបអង្កេតសវនកម្មទេ។ ប៉ុន្តែតាមរយៈគោលការណ៍ណែនាំស្តីពី ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសវនកម្ម ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល អាចចូលរួមក្នុងដំណើរ ការសវនកម្ម រួមទាំងការស៊ើបអង្កេតសវនកម្មសមិទ្ធិកម្មការងារផងដែរ។ តាមរយៈកម្មវិធីនេះ ពួកគេអាចចាប់ដៃ គូជាមួយគណៈកម្មាធិការសវនកម្ម ដើម្បីបង្កើតក្រុមសវនករពិសេសសម្រាប់ត្រួតពិនិត្យគម្រោងរដ្ឋាភិបាល ដែលខ្លួនជ្រើសរើស[22]។ ការរាយការណ៍ពីករណីបន្លំនិងការស្ម័គ្រចិត្តធ្វើជាសវនករពលរដ្ឋ អាចធ្វើបានតាមរយៈ វេបសាយ i-Kwenta.com ។ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ សវនកម្មដែលមានការចូលរួមបែបនេះចំនួន ៣ ត្រូវបានធ្វើឡើង (IBP, 2015f, Magno, 2015) ។

ពិន្ទុលើយន្តការដើម្បីផ្សព្វផ្សាយរបាយការណ៍សវនកម្មលើសពីការធ្វើឱ្យរបាយណ៍ការនេះអាចរកបានជាសាធារណៈមានការប្រែប្រួលពីការស្ទង់មតិមួយទៅមួយ។ នៅក្នុងការស្ទង់មតិបីលើកដំបូង ដែលគ្រាន់តែ វាស់

[22] របាយណ៍ការសវនកម្មរបស់គម្រោងនានា អាចរកបាននៅវេបសាយ https://www.coa.gov.ph/index.php/reports/citizen-participatory-audit-reports ទាញយកនៅថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩។

វែងថាតើរបាយការណ៍នេះត្រូវបានចេញផ្សាយដែរឬទេ គេរាយការណ៍ថារបាយការណ៍នេះត្រូវបានបោះ ពុម្ពផ្សាយ ប៉ុន្តែវាខ្វះនូវព័ត៌មានលម្អិត។ ហេតុដូច្នេះ វាបានទទួលពិន្ទុទាបជាងមធ្យមលើចំនុចនេះ។ ចាប់តាំង ពីឆ្នាំ២០១២មក សំណួរនេះមានការផ្លាស់ប្តូរបន្តិចបន្តួច ទៅជាថាតើមានយន្តការផ្សេងៗទៀតដើម្បី ផ្សព្វផ្សាយ លទ្ធផលសវនកម្មឱ្យបានទូលំទូលាយដែរឬទេ ដែលជាហេតុធ្វើឱ្យប្រទេសហ្វីលីពីនបានពិន្ទុទាបលើចំនុចនេះ នៅឆ្នាំ២០១២។ ប៉ុន្តែប្រទេសនេះទទួលបានពិន្ទុពេញនៅឆ្នាំ២០១៥ ដែលជាឆ្នាំចុងក្រោយ សំណួរនេះត្រូវ បានបញ្ចូលក្នុងការស្ទង់មតិ OBS។ ការបានពិន្ទុពេញនេះ គឺដោយសារតែមានសន្និសីទព័ត៌មាន ដ៏កម្រមួយ ដើម្បីពិភាក្សារបាយការណ៍សវនកម្មពិសេស ស្តីពីការឃុបឃិតក្លែងបន្លំក្នុងការប្រើប្រាស់ថវិកាជាតិមួយក្នុងឆ្នាំ ២០១៣ (IBP, 2015f)។ មានការិយាល័យព័ត៌មានសាធារណៈមួយរបស់គណៈកម្មាធិការ សវនកម្មជាតិ ប៉ុន្តែមិនមានយន្តការផ្លូវការណាមួយ ដើម្បីធានាថាសាធារណជនអាចដឹងពីលទ្ធផលនៃការធ្វើសវនកម្មនោះ ទេ។ អ្វីដែលគណៈកម្មាធិការសវនកម្មបានធ្វើ គឺច្រើនតែការបង្ហាញការរកឃើញនៅក្នុងសវនកម្មរបស់ខ្លួននៅ ក្នុងព្រឹត្តិការណ៍សាធារណៈនានា ឬនៅសន្និសីទព័ត៌មានរបស់ខ្លួន (IBP, 2012f) ។

ចំណុចដែលគណៈកម្មាធិការសវនកម្មធ្វើមិនបានល្អ គឺការផ្តល់មតិត្រលប់ជាផ្លូវការនិងលម្អិតដល់សាធារណជន អំពីការប្រើប្រាស់ធាតុចូលរបស់ពួកគេក្នុងកម្មវិធីសវនកម្មរបស់ខ្លួន។ វាទទួលបានពិន្ទុក្រោមមធ្យមនៅឆ្នាំ២០១២និងឆ្នាំ២០១៧ និងបានសូន្យនៅឆ្នាំ២០១៥។ មតិយោបល់ត្រលប់ពីគណៈកម្មាធិការ សវនកម្ម ដែលខ្វះព័ត៌មានលម្អិតមានការផ្លាស់ប្តូរខ្លះៗក្នុងពេលកន្លងមក។ នៅឆ្នាំ២០១២ វាគ្រាន់តែបានចេញ សេចក្តីសង្ខេបនៃបណ្តឹងក្លែងបន្លំលើនៅ "ការជូនដំណឹងពីការបន្លំ" (Fraud Alert) នៅលើវេបសាយ របស់ខ្លួន។ នៅឆ្នាំ២០១៥ ផ្នែកនេះត្រូវបានប្តូរទៅជាប្រព័ន្ធព័ត៌មាន សាធារណៈ ឬ Public Information System (http://pis.coa.gov.ph/pis/view.php) ហើយប្រជាពលរដ្ឋដែលចង់ទទួលបានព័ត៌មានទាក់ទង នឹងការធ្វើសវនកម្ម ឬព័ត៌មានមិនទាក់ទងនឹងសវនកម្ម អាចបង្កើតសំបុត្រមួយដើម្បីទទួលព័ត៌មាន និងមើលស្ថានភាព នៃកង្វល់ឬពាក្យបណ្តឹងរបស់ពួកគេ។ នៅឆ្នាំ២០១៧ វាមិនទាន់បានបង្កើតបញ្ជីនៃធាតុ ចូលដែល ទទួលបាន ពីសាធារណជននោះទេ ប៉ុន្តែសម្រាប់សវនកម្មធ្វើឡើងក្រោមយន្តការសវនកម្ម ដែល មានការចូលរួមពីប្រជាពលរដ្ឋ វាបានផ្តល់របាយការណ៍ស្តីពីសវនកម្មដែលមានការចូលរួមពីប្រជាពលរដ្ឋនោះ ដែលក្នុងរបាយណ៍នោះ បានបញ្ចូលនូវធាតុចូលដែលទទួលបានពីប្រជាពលរដ្ឋ និងរៀបរាប់លម្អិតអំពីរបៀប ដែលពួកគេ ត្រូវ បានប្រើដើម្បីកំណត់កម្មវិធីសវនកម្មរបស់ខ្លួន។

# ជំពូកទី៤: សេចក្តីសន្និដ្ឋាននិងអនុសាសន៍គន្លឹះៗ

ការចូលរួមជាសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (រាប់បញ្ចូលទាំងការរៀបចំថវិកាជាតិ) ត្រូវបាន គេជឿថាជាសិទ្ធិមួយ ប៉ុន្តែការចូលរួមជាសាធារណៈក្នុងកិច្ចការនេះនៅប្រទេសកម្ពុជានៅមានលក្ខណៈ ចង្អៀត នៅឡើយ។ ប៉ុន្តែយើងក៏គួរកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នរដ្ឋ ពាក់ព័ន្ធនានាក្នុងការ បង្កើន លទ្ធភាពឱ្យពលរដ្ឋក្នុងការទទួលបានព័ត៌មាន តម្លាភាព និងការចូលរួមជាសាធារណៈនៅក្នុងសកម្មភាព ទូទៅរបស់ខ្លួន ក៏ដូចជាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។ គោលបំណងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលចង់ធ្វើឱ្យប្រសើរឡើងនូវពិន្ទុរបស់ប្រទេសកម្ពុជាក្នុងការវាយតម្លៃរបស់ OBS ក៏គួរត្រូវកោត សរសើរផងដែរ។ ការសិក្សានេះមានគោលបំណងពីរជាចម្បង។ ទីមួយ វាមានបំណងពិនិត្យឡើងវិញ នូវច្បាប់ និងក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនានានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីកំនត់វិសាលភាព និងរបៀប ដែលច្បាប់និងគោល នយោបាយពាក់ព័ន្ធ ផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ក្នុងការចូលរួម ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងការរៀបចំថវិកាជាតិផងដែរ។ ទីពីរ ការសិក្សានេះក៏មាន បំណងស្វែង រកវិធីសាស្ត្រប្រាកដនិយម ដើម្បីផ្តល់ជាអនុសាសន៍សម្រាប់ការអនុវត្តទៅដល់ស្ថាប័នរដ្ឋពាក់ព័ន្ធ ដោយផ្អែកលើ របកគំហើញដែលដកស្រង់ចេញពីការសិក្សានេះ។

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនានារបស់ប្រទេសកម្ពុជា មិនសូវមានការ បរិយាយលម្អិតស្តីពីការចូលរួមជាសាធារណៈ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិនោះទេ។ ប៉ុន្តែក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ ផ្តល់នូវឱកាសនិងយន្តការ មួយ ចំនួនធំ សម្រាប់ឱ្យប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលចូលរួមក្នុងការរៀបចំ ការអនុម័ត ការអនុវត្ត និងការត្រួត ពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ក្រោមជាតិ។ ដោយសារការមានកំហិតនៅក្នុង ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរបស់ប្រទេសកម្ពុជា ស្ថាប័ននីតិ ប្រតិបត្តិ រួមទាំងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិងក្រសួង ពាក់ព័ន្ធនានា ស្ថាប័ននីតិបញ្ញត្តិ អាជ្ញាធរ ជាតិសវនកម្ម និងរដ្ឋបាលថ្នាក់ក្រោមជាតិ គួរពិចារណាលើអនុសាសន៍ មួយចំនួនខាងក្រោម ដែលការអនុវត្តអនុសាសន៍ទាំងនេះអាចបង្កើនការចូលរួមជា សាធារណៈនៅប្រទេសកម្ពុជា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងកិច្ចការថវិកាផងដែរ។ អនុសាសន៍ ដើម្បីលើកកម្ពស់ឱកាស សម្រាប់ ការចូលរួមដោយការអញ្ជើញ (invited participation) នៅប្រទេសកម្ពុជា ខាងក្រោមនេះ គឺបានមកពីរ បកគំហើញនានាដែលបានមកពី (១) ការសិក្សាពិនិត្យឡើងវិញលើក្របខ័ណ្ឌ ច្បាប់និងគោលនយោបាយពាក់ព័ន្ធ (២) កិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធមួយចំនួន (៣) កិច្ចសម្ភាស ជាមួយអ្នកជំនាញ និងពាក់ព័ន្ធដទៃ ទៀត ដែលក្រុមអ្នកស្រាវជ្រាវទាំងពីរបានធ្វើ និង (៤) ការពិនិត្យ ឡើងវិញនៃការអនុវត្តនៅប្រទេសហ្វីលីពីន និង ប្រទេសឥណ្ឌូនេស៊ី ក្រោមលក្ខខណ្ឌនៃដែនកំណត់ ទាំងអស់ដែលបានពិភាក្សានៅក្នុងជំពូកទីមួយ។ អនុសាសន៍ ទាំងនេះ គឺបានសង្ខេបនៅក្នុងតារាងទី០៥ និងបានពន្យល់លម្អិតបន្ថែមនៅផ្នែកបន្តបន្ទាប់នេះ។ នៅក្នុងផ្នែកនេះ

រយៈពេលខ្លីសំដៅទៅលើរយៈពេល ចាប់ពីពេល បច្ចុប្បន្នរហូតដល់ប្រាំឆ្នាំទៀត និងរយៈពេលមធ្យមគឺពី៦ទៅ១០ ឆ្នាំទៀតយ៉ាងតិច។

**តារាងទី០៥: សកម្មភាពគន្លឹះៗដែលនឹងគួរអនុវត្ត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមពីសាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជា**

| ល | សកម្មភាព | ស្ថាប័ននាំមុខ | ពេលវេលា |
|---|---|---|---|
| ១ | ធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរដ្ឋសភា | ខ្លី |
| ២ | អនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន | ទីស្តីការគណរដ្ឋមន្ត្រី និងរដ្ឋសភា | ខ្លី |
| ៣ | ធ្វើឱ្យមានសង្គតភាពរវាងការអនុវត្តផែនការវិនិយោគថ្នាក់ឃុំ និងការរៀបចំថវិកាឃុំ/សង្កាត់ប្រចាំឆ្នាំ និងពង្រឹងការអនុវត្ត ការចូលរួមជាសាធារណៈនៅក្នុងការ គ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈនៅថ្នាក់ក្រោមជាតិ | ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ខ្លីទៅមធ្យម |
| ៤ | ចេញប្រកាសឬការជូនដំណឹងអំពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការរៀបចំ ថវិកាជាតិ និងការតាមដានការអនុវត្តរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មធ្យម |
| ៥ | ចេញអនុក្រឹត្យស្តីពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការរៀបចំថវិកាជាតិ និងការតាមដានការអនុវត្តនៃក្រសួងសំខាន់ៗមួយចំនួន | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទីស្តីការគណរដ្ឋមន្ត្រី (ព្រមទាំងក្រសួងពាក់ព័ន្ធ) | ខ្លីទៅមធ្យម |
| ៦ | ពិនិត្យកែលម្អឡើងវិញនូវបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និង ព្រឹទ្ធសភា ដើម្បីបញ្ចូលគោលការណ៍ណែនាំនិងនីតិវិធី សម្រាប់ការចូលរួមជាសាធារណៈ និងយន្តការផ្តល់មតិ ត្រលប់ | រដ្ឋសភានិងព្រឹទ្ធសភា | ខ្លី |
| ៧ | អនុវត្តការចូលរួមរបស់សាធារណជន និងអង្គការសង្គមស៊ីវិល នៅក្នុងការស៊ើបអង្កេតសវនកម្មសមិទ្ធិកម្មការងារតាមរយៈគម្រោងសាកល្បង | អាជ្ញាធរជាតិសវនកម្ម (ព្រមទាំងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ) | មធ្យមទៅវែង |

| | | | |
|---|---|---|---|
| ៨ | ធ្វើបច្ចុប្បន្នភាពនិងថែរក្សាវេបសាយ និងប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម និងបណ្តាញទំនាក់ទំនងបន្ទាន់ ប្រកបដោយប្រតិសកម្ម ដើម្បីឱ្យសាធារណជននិងអង្គការសង្គម ស៊ីវិល បានចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងថវិកា | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋសភា ព្រឹទ្ធសភា អាជ្ញាធរជាតិសវនកម្ម (និងក្រសួងពាក់ព័ន្ធនានា) | ខ្លីទៅមធ្យម |

១. ការដែលរាជរដ្ឋាភិបាលមានបំណងធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ អោយបានមុនឆ្នាំ ២០២០ គឺជាគំនិតផ្តួចផ្តើមនិងឱកាសដ៏ល្អនិងទាន់ពេលវេលា ហើយគួរតែមានការពិចារណាបញ្ចូល នូវការចែងអំពីការចូលរួមជាសាធារណៈ យ៉ាងហោចណាស់ក្នុងវដ្តថវិកានៅក្នុងច្បាប់ថ្មីនោះ។ ប្រទេស ហ្វីលីពីន គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយ ព្រោះវាបានទទួលពិន្ទុពេញឬលើមធ្យម សម្រាប់ការចូលរួម ជាសាធារណៈ ពីព្រោះច្បាប់ និងគោលនយោបាយនានារបស់ប្រទេសនេះមានបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ហើយបញ្ញត្តិទាំងនេះត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋសភា និងព្រឹទ្ធសភា គឺជាតួអង្គយ៉ាងសំខាន់នៅក្នុងការអនុវត្តគំនិតផ្តួចផ្តើមធ្វើវិសោធនកម្មច្បាប់នេះ[23]។

២. ការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជានឹងអាចទទួលបានអត្ថប្រយោជន៍ ពីការអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធទទួលបានព័ត៌មាន ដែលកំពុងរង់ចាំចំណាត់ការបន្តនៅទីស្តីការគណៈរដ្ឋមន្ត្រី។ ជាបទពិសោធន៍ពីប្រទេសឥណ្ឌូនេស៊ី ការចូលរួមជាសាធារណៈរបស់ប្រទេសនេះ មានការប្រសើរឡើងខ្លះៗ បន្ទាប់ពីមានការចេញច្បាប់បែបនេះ។ ក្នុងន័យនេះ គណៈរដ្ឋមន្ត្រីគួរតែជំរុញដំណើរការសេចក្តីព្រាងច្បាប់ នេះបន្តទៀត និងឈានដល់ការអនុម័តនិងអនុវត្តច្បាប់នេះឱ្យបានខ្ជាប់ខ្ជួន។

៣. ខណៈដែលថាការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវការពេលវេលាច្រើន នៅ ក្នុងដំណាក់កាលនេះ ជំហានដែលអាចធ្វើទៅបាន ដែលអាចជួយបង្កើនពិន្ទុការចូលរួមជាសាធារណៈរបស់ ប្រទេសកម្ពុជានៅក្នុងការស្ទង់មតិ OBS ក្នុងរយៈពេលខ្លីទៅមធ្យម ក៏ដូចជាដើម្បីធ្វើឱ្យប្រសើរឡើ

[23] បណ្តាប្រទេសមួយចំនួនបានបញ្ចូលការចូលរួមជាសាធារណៈនៅក្នុងច្បាប់ហិរញ្ញវត្ថុសាធារណៈរបស់ពួកគេ។ ប្រទេសកម្ពុជាអាចដកស្រង់មេរៀនល្អៗពីប្រទេសទាំងនេះ (សូមមើល de Renzio & Kroth, 2011)។ យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការធ្វើវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុនាពេលខាងមុខនឹងផ្តោតជាសំខាន់ទៅលើគណនេយ្យភាពសង្គម និងថវិកាផ្អែកលើសម្មិទ្ធិកម្មការងារ។ ប្រសិនបើការចូលរួមជាសាធារណៈ មិនត្រូវបានគ្របដណ្តប់នៅក្នុងកំណែទម្រង់ខាង មុខនេះទេ ជម្រើសមួយទៀតគឺការចេញនូវអនុក្រឹត្យមួយស្តីពីការចូលរួមជាសាធារណៈនៅក្នុងការ គ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ដែលជាការអនុវត្តជាក់ស្តែងនៅប្រទេសហ្វីលីពីន ដែលថ្មីៗនេះប្រទេសនេះថែមទាំងបាន និងកំពុងព្រាង ច្បាប់មួយស្តីពីការចូលរួមជាសាធារណៈ ហើយដែលនឹងត្រូវអនុម័តនាពេលអនាគតឆាប់ៗនេះ។

ងនូវ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានការចូលរួម គឺការពង្រឹងនិងពង្រីកយន្តការនានាដែលមានស្រាប់។ ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីនបានប្រើប្រាស់យន្តការស្រដៀងនេះដើម្បីបង្កើនការ ចូលរួមជាសាធារណៈរបស់ខ្លួន។ ខាងក្រោមនេះ គឺជាវិធានការដែល អាចហុចផលបានភ្លាមៗ។

នៅថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល មានលំហច្បាប់និងគោលនយោបាយច្រើនក្នុងការចូលរួមការរៀបចំផែនការអភិវឌ្ឍន៍ ការរៀបចំថវិកា និងក្នុងកម្រិតណាមួយ ការតាមដាននិងវាយតម្លៃការអនុវត្ត។ ការអនុវត្តមួយចំនួននៃច្បាប់និងគោលនយោបាយ ដែលមានការចូលរួមបែបនេះបានធ្វើឡើង នៅក្នុងឃុំនិងសង្កាត់មួយចំនួន ដែលមានគម្រោងរបស់ក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាលមួយ ចំនួន។ ឧទាហរណ៍ល្អមួយ គឺការចូលរួមពីសាធារណជនក្នុងការរៀបចំផែនការវិនិយោគឃុំ និងថវិកាឃុំ នៅតាមតំបន់មួយចំនួន។ តម្រូវការសម្រាប់ការចូលរួមជាសាធារណៈក្នុងការបង្កើតសំណើគម្រោង សម្រាប់ គម្រោងវិនិយោគថ្នាក់ក្រោមជាតិ (នៅថ្នាក់ស្រុក) គឺជាបំណងល្អមួយទៀតរបស់រាជរដ្ឋាភិបាលក្នុងការ ជម្រុញការចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ ក្នុងការគ្រប់គ្រងថវិកាសាធារណៈ តាមរយៈការប្រើ ប្រាស់មូលនិធិដែលផ្អែកលើសមិទ្ធិកម្មការងារ។ ការអនុវត្តល្អៗដែលមានស្រាប់អាចត្រូវបន្តអនុវត្ត និង ពង្រីកជាលំដាប់។ ទោះជាយ៉ាងណាក៏ដោយ ជាការអនុវត្តជាក់ស្តែង ដោយសារការរៀបចំផែនការវិនិយោគ ឃុំ និងដំណើរការរៀបចំថវិកាប្រចាំឆ្នាំត្រូវបានអនុវត្តដាច់ដោយឡែកពីគ្នាក្នុងករណីភាគច្រើន គួរមានការ ចេញប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីគោលការណ៍ណែនាំ និង នីតិវិធីក្នុងការសម្រួលការចូលរួមជាសាធារណៈ នៅក្នុងកិច្ចការថវិកាថ្នាក់ក្រោមជាតិ និងការរៀបចំផែនការ វិនិយោគឃុំសង្កាត់។ ក្នុងពេលបច្ចុប្បន្ន ការគាំទ្រនិងការណែនាំបន្ថែមទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុង ការអនុវត្តគោលការណ៍ណែនាំនិងបទបញ្ញត្តិថ្មីៗនានា គឺជាការចាំបាច់។

៤. និង ៥. មេរៀនមួយដែល ថ្នាក់ជាតិអាចរៀនសូត្រពីថ្នាក់ក្រោមជាតិ ដូចដែលបានពិភាក្សានៅក្នុង អនុសាសន៍ទី ៣ ខាងលើ គឺការប្រើប្រាស់ក្រុមការងារបច្ចេកទេសតាមក្រសួងនានា និង/ឬ អនុក្រុមការងាបច្ចេកទេសតាមអនុវិស័យ និងក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ជាយន្តការដើម្បីពង្រឹងនិងពង្រីកការចូលរួមជាសាធារណៈ នៅក្នុងដំណើរការថវិកា ។ ខាងក្រោមនេះ គឺជាគំនិតពីរដែលគួរពិចារណាៈ

ទីមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចជម្រុញការចូលរួមយ៉ាងសកម្មរបស់តំណាងប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទូទាំងវដ្តថវិកា និងលើសពីនេះ តាមរយៈ ការប្រើប្រាស់ក្រុមការងារបច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានស្រាប់ ឬយន្តការ ផ្សេងទៀតដែលសមស្របទៅនឹងគោលបំណងនេះ។ ជាការអនុវត្តជាក់ស្តែង តួនាទីរបស់ក្រុមការងារ បច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានស្រាប់នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺ សម្រាប់តែគាំទ្រដល់ការរៀបចំថវិកា និងមិនមែនសម្រាប់ការពិភាក្សាលើបញ្ហាថវិកានិងការសម្រេចចិត្តលើ បញ្ហានេះទេ។

ទោះបីជាយ៉ាងណាក៏ដោយ ជាមួយនឹងការចូលរួមរបស់តំណាងសាធារណជននិងអង្គការ សង្គមស៊ីវិល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដឹងឮពីកង្វល់និងអាទិភាពរបស់ពួកគេ ដែលអាចយកទៅប្រើ សម្រាប់ការកំណត់អាទិភាពថវិកាប្រចាំឆ្នាំ។ មេរៀនដែលទទួលបានពីការចូលរួមរបស់តំណាង សាធារណជននិងអង្គការសង្គមស៊ីវិល នៅក្នុងក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការរៀបចំ ថវិកា អាចត្រូវបានពង្រីក ដើម្បីជម្រុញការចូលរួមរបស់សាធារណជន នៅក្នុងផ្នែកផ្សេងទៀតនៃវិស័យហិរញ្ញវត្ថុសាធារណៈ ដូចជាការត្រួតពិនិត្យការអនុវត្តថវិកា និងការផ្ដល់មតិត្រលប់ជាដើម។ ក្នុងប្រការដែលថា យន្តការក្រុមការងារបច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនមែនជា យន្តការមិនសមស្រប ក្រសួងអាចប្រើប្រាស់ឬពង្រឹងបន្ថែមយន្តការដែលមានស្រាប់រួចហើយ ឬគួរបង្កើតនូវយន្តការសមស្របថ្មីផ្សេងទៀត ដើម្បីគាំទ្រគំនិតផ្ដួចផ្ដើមនៃការចូលរួមជាសាធារណៈនេះ។ ដើម្បី សម្រេច គោលដៅទាំងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញជាប្រកាសឬការជូនដំណឹងអំពីគោលការណ៍ ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការរៀបចំថវិកា និងការត្រួតពិនិត្យការអនុវត្ត ថវិកា។

ទី ២ អង្គការសង្គមស៊ីវិលអាចចូលរួមជាមួយក្រសួងពាក់ព័ន្ធនានានិងមន្ទីរជំនាញថ្នាក់ខេត្ត តាម រយៈយន្តការដែលមានស្រាប់។ ជាកាលានុវត្តភាពល្អមួយ នៅតាមក្រសួងពាក់ព័ន្ធ និងមន្ទីរជំនាញ ថ្នាក់ខេត្ត ដែលអនុវត្តកម្មវិធីថវិកា ក្រុមការងារបច្ចេកទេសតាមក្រសួងនានា និងអនុក្រុមការងារបច្ចេកទេស តាមអនុវិស័យនៃក្រសួងសាមី និងក្រុមការងារបច្ចេកទេសរបស់មន្ទីរជំនាញនៅថ្នាក់ ខេត្ត និង/ឬយន្តការ សមស្របដទៃទៀតបាននិងកំពុងដំណើរការជាស្រេច។ ជាមួយនឹងយន្តការដែលមានស្រាប់នេះ សាធារណជននិង អង្គការសង្គមស៊ីវិល អាចចូលរួមជាមួយក្រសួងនិងមន្ទីរបច្ចេកទេសពាក់ព័ន្ធនៅតាមខេត្ត ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាឧទាហរណ៍ លើការចាត់អាទិភាពថវិកា តាំងពីដើមខ្សែមក ជាពិសេសសម្រាប់វិស័យឬក្រសួងអាទិភាពមួយចំនួន។

អំណេះតទៅមុខ រាជរដ្ឋាភិបាល ក្រោមការផ្ដួចផ្ដើមគំនិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាច ចេញអនុក្រឹត្យមួយ ស្ដីពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈក្នុងការរៀបចំ ថវិកា និងការតាមដានការអនុវត្តការចំណាយថវិការបស់ក្រសួងនានា ហើយសាកល្បងគំនិតថ្មីនេះជាមួយ ក្រសួងអាទិភាពមួយចំនួន ដូចជាក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាលជាដើម។ អនុក្រឹត្យ នេះ ក្រសួងក៏អាចពិចារណាបញ្ចូលការចូលរួមរបស់តំណាងសាធារណជន និងអង្គការសង្គមស៊ីវិលថ្នាក់ ខេត្ត ក្នុងការរៀបចំ និងការត្រួតពិនិត្យការអនុវត្តថវិការបស់មន្ទីរពាក់ព័ន្ធនានាផងដែរ។

៦. អង្គនីតិប្បញ្ញត្តិនៃប្រទេសឥណ្ឌូណេស៊ីនិងប្រទេសហ្វីលីពីន ទទួលបានពិន្ទុខ្ពស់ជាងមុនបន្ទាប់ពី ការរៀបចំសវនាការជាសាធារណៈ ដែលនីតិប្រតិបត្តិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋអាចចូលរួមក្នុង ការសម្រេចចិត្តរបស់ខ្លួន និងផ្ដល់ធាតុចូលដល់ការងារត្រួតពិនិត្យថវិការបស់ពួកគេ ឬការបង្ហាញសំណើ ថវិកាជំនួស។ អង្គនីតិបញ្ញត្តិរបស់ប្រទេសកម្ពុជា ក៏អាចប្រើប្រាស់សវនាការសាធារណៈបែបនេះ ជា មធ្យោបាយដ៏មានសក្ដានុពល ដើម្បីបង្កើនការចូលរួមជាសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ ខ្លួនផងដែរ។

ក្នុងករណីសំណើរថវិកាប្រចាំឆ្នាំ រដ្ឋសភានិងព្រឹទ្ធសភា អាចពិចារណាការពិភាក្សា ជាមួយអង្គការសង្គមស៊ីវិល និងសាធារណជន មុនពេលសេចក្តីព្រាងច្បាប់ថវិកាជាតិត្រូវបានបញ្ជូនមកដល់ស្ថាប័នខ្លួន ដូចដែលបានអនុវត្តនៅក្នុងប្រទេសហ្វីលីពីនក៏បាន។ ជាការអនុវត្តជាក់ស្តែង រដ្ឋសភាកម្ពុជា បានប្រើប្រាស់ពេលវេលា តិចជាងរយៈពេល ៧សប្តាហ៍ (ពេលវេលាអតិបរមាដូចដែលកំណត់ដោយច្បាប់) សម្រាប់ការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ថវិកាជាតិ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៥) ដូច្នេះ អង្គនីតិបញ្ញត្តិ គឺមានពេល វេលាគ្រប់គ្រាន់សម្រាប់ការចូលរួមជាសាធារណៈ ហើយពេលវេលាដែលមាននេះ អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនេះ។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានិងព្រឹទ្ធសភា អាចត្រូវបាន កែសម្រួលឡើងវិញ ដើម្បីបញ្ចូលគោលការណ៍ណែនាំ និងនីតិវិធីនានាសម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងសវនាការរបស់ខ្លួន និងយន្តការផ្តល់មតិត្រលប់ដល់សាធារណជន និងអង្គការសង្គមស៊ីវិល។ ក្នុង ន័យនេះ វិទ្យាស្ថានសភាកម្ពុជា (PIC) អាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ជូនរដ្ឋសភានិងព្រឹទ្ធសភា នូវព័ត៌មានសមស្រប តាមរយៈការស្រាវជ្រាវរបស់ខ្លួន។

៧. អាជ្ញាធរសវនកម្មកំពូលរបស់ប្រទេសឥណ្ឌូនេស៊ីនិងប្រទេសហ្វីលីពីន ទទួលបានពិន្ទុខ្ពស់ជាងមុន ដោយសារការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យា។ អាជ្ញាធរសវនកម្មប្រទេសទាំងពីរនេះបានប្រើប្រាស់ វេបសាយរបស់ខ្លួន ក៏ដូចជាវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម និងបណ្តាញទូរស័ព្ទបន្ទាន់ដើម្បី ទទួលពាក្យ បណ្តឹងនិងមតិយោបល់របស់សាធារណជន និងដើម្បីផ្តល់មតិត្រឡប់ទៅសាធារណជនវិញ សម្រាប់កម្មវិធីសវនកម្មនិងការស៊ើបអង្កេតរបស់ពួកគេ។ ក្នុងរយៈពេលខ្លីទៅមធ្យម អាជ្ញាធរសវនកម្ម ជាតិនៃកម្ពុជាអាចពិចារណាកែលម្អវេបសាយរបស់ខ្លួន និងមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត ដើម្បីបង្កើន ការទាក់ទងជាមួយសាធារណជននិងអង្គការសង្គមស៊ីវិល ជាឧទាហរណ៍ ដើម្បីទទួលនូវធាតុចូលសម្រាប់ កម្មវិធីសវនកម្មរបស់ខ្លួន ក៏ដូចជាដើម្បីផ្តល់មតិត្រលប់ទៅពួកគេវិញ។ ក្នុងរយៈពេលវែង អាជ្ញាធរ សវនកម្មជាតិ អាចចេញនូវគោលការណ៍ណែនាំមួយ ដែលអាចឱ្យសាធារណជននិងអង្គការសង្គមស៊ីវិល ចូលរួមក្នុងសវនកម្មសមិទ្ធិផលការងាររបស់ខ្លួន ហើយការនេះអាចចាប់ផ្តើមជាគម្រោងសាកល្បងមួយ លើវិស័យអទិភាពណាមួយ ដូចជាវិស័យអប់រំ ឬសុខាភិបាលជាដើម។

៨. នៅប្រទេសកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រើប្រាស់គណនីហ្វេសប៊ុករបស់សម្តេច ដើម្បីទទួល និងឆ្លើយតបចំពោះពាក្យបណ្តឹងនិងសំណូមពរនានាពីប្រជាពលរដ្ឋ ក៏ដូចជាដើម្បីកែប្រែគោលនយោបាយ មួយចំនួនក៏មាន (Vong & Hok, 2018) ។ ជាការពិតស្ទើរតែគ្រប់ស្ថាប័នរដ្ឋ ទាំងអស់នៅប្រទេសកម្ពុជា មានវេបសាយនិងគណនីហ្វេសប៊ុកផ្ទាល់ខ្លួន។ ហេតុដូច្នេះ ក្រៅពីអាជ្ញាធរជាតិ សវនកម្ម ក្រសួងពាក់ព័ន្ធនានា រដ្ឋសភា និងព្រឹទ្ធសភាកម្ពុជា អាចទាញផលប្រយោជន៍ពីការប្រើប្រាស់ បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) ដែលមានប្រសិទ្ធិភាពនិងចំណាយទាបនានាបែបនេះ ដើម្បីឱ្យមាន ការចូលរួមពីសំណាក់

សាធារណជននិងអង្គការសង្គមស៊ីវិល នៅក្នុងកិច្ចការរបស់ពួកគេ នៅដំណាក់កាល នានានៃវដ្តថវិកា ក៏ ដូចជាការរៀបចំ និងអនុវត្តផែនការឬយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការផ្តល់សេវារបស់ខ្លួន។ ក្នុងករណីនេះ វេបសាយរបស់ពួកគេ ត្រូវការការធ្វើបច្ចុប្បន្នភាពនិងការថែទាំជាប្រចាំ ហើយវេទិកាប្រព័ន្ធ ផ្សព្វផ្សាយសង្គមរបស់ពួកគេ ចាំបាច់ត្រូវបានប្រើប្រាស់ ដើម្បីឱ្យមានការចូលរួមពីសាធារណជន និងអង្គការ សង្គមស៊ីវិល។

ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិសវនកម្ម រដ្ឋសភា និងព្រឹទ្ធសភា អាចឆ្លើយតបបានល្អប្រសើរជាងពេលបច្ចុប្បន្ន ជាពិសេសតាមរយៈការប្រើប្រាស់បណ្តាញព័ត៌មានថ្មីនិងបណ្តាញសង្គមនានា និងដើម្បីឱ្យមានការចូលរួមយ៉ាងសកម្មពីសាធារណជន និងអង្គការសង្គមស៊ីវិល នៅក្នុងសកម្មភាពថវិការបស់ពួកគេ រួមទាំងនៅក្នុងវដ្តថវិកាទាំងមូល វាជាការចាំបាច់ដែលត្រូវមានការកសាងសមត្ថភាពបុគ្គលិករបស់ពួកគេ ជាពិសេសលើជំនាញលើកកម្ពស់តម្លាភាពថវិកា ទំនាក់ទំនងសាធារណៈ និងការប្រើប្រាស់និងថែរក្សាឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា។ ក្នុងរយៈពេលខ្លីទៅមធ្យម ស្ថាប័នទាំងនេះអាចពិចារណាបញ្ចូលការកសាងសមត្ថភាពបុគ្គលិកនេះ ទៅក្នុងផែនការការងារប្រចាំឆ្នាំ និងផែនការរយៈពេលខ្លីរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ប្រហែលជាអាចជាដៃគូរក្នុងការគាំទ្រ ស្ថាប័នទាំងនេះនៅក្នុងរឿងនេះ។

# ឯកសារយោង

Ahmad, R., & Weiser, E. T. (2006). *Fostering public participation in budget-making*. Metro Manila/San Francisco: The Asia Foundation.

Baimyrzaeva, M., & Kose, H. O. (2014). The Role of Supreme Audit Institutions in Improving Citizen Participation in Governance. *International Public Management Review*, *15*(2).

Capistrano, F. Y. (2017). *The road to fiscal transparency in the Philippines*. The Global Initiative for Finscal Traparency.

Chan, S. (2017). Capacity Need Assessment of BWG Members and Partners Working on Budget Awareness Assessment of Provincial Network NGOs, Media, and Youth/Citizens: NGO Forum on Cambodia.

de Renzio, P., & Kroth, V. (2011). *Transparency and Participation in Public Financial Management: What Do Budget Laws Say?*. Washington D.C.: IBP.

General Secretariat of Public Financial Management Reform Program Steering Committee (GSPFMRPSC). (2018). Results of 2018 Mid-term Progress Monitoring of the Performance Assessment Framework of the EU-funded Project. Phnom Penh: GSPFMRPSC.

GIFT. (2018). The High-Level Principles on Fiscal Transparency, Participation & Accountability: Expanded Version: Global Initiative for Fiscal Transparency

Heng, S., Kim, S., & So, S. (2011). "Decentralised Governance in Hybrid Polity: Localisation of Decentralisation and Deconcentration (D&D) Reform in Cambodia". Working Paper No.63. Cambodia Development Resource Institute, Phnom Penh.

House of Senate. (2018). [Draft] Act Institutionalizing People’s Participation in the Budget Process, Appropriating Funds thereof, and for Other Purposes. Manila: House of Senate.

Hughes, C., & Un, K. (2011). Cambodia's Economic Transformation: Historical and Theoretical Frameworks. In C. Hughes & K. Un (Eds.), *Cambodia's Economic Transformation*. Compenhagen: Nias Press.

IBP. (2006a). Open Budget Index 2006: Indonesia.

IBP. (2006b). Open Budget Index 2006: The Philippines.

IBP. (2008a). Open Budget Index 2008: Cambodia.

IBP. (2008b). Open Budget Index 2008: Indonesia.

IBP. (2008c). Open Budget Index 2008: The Philippines.

IBP. (2010a). Open Budget Index 2010: Cambodia.

IBP. (2010b). Open Budget Index 2010: Indonesia.

IBP. (2010c). Open Budget Index 2010: The Philippines.

IBP. (2012a). Open Budget Index 2012: Cambodia.

IBP. (2012b). Open Budget Index 2012: Indonesia.

IBP. (2012c). Open Budget Index 2012: The Philippines.

IBP. (2015a). Open Budget Index 2015: Cambodia.

IBP. (2015b). Open Budget Index 2015: Indonesia.

IBP. (2015c). Open Budget Index 2015: The Philippines.

IBP. (2017a). Open Budget Index 2017: Cambodia.

IBP. (2017b). Open Budget Index 2017: Indonesia.

IBP. (2017c). Open Budget Index 2017: The Philippines.

IBP. (2006c). Open Budget Survey 2006: Indonesia.

IBP. (2006d). Open Budget Survey 2006: The Philippines.

IBP. (2008d). Open Budget Survey 2008: Cambodia.

IBP. (2008e). Open Budget Survey 2008: Indonesia.

IBP. (2008f). Open Budget Survey 2008: The Philippines.

IBP. (2010d). Open Budget Survey 2010: Cambodia.

IBP. (2010e). Open Budget Survey 2010: Indonesia.

IBP. (2010f). Open Budget Survey 2010: The Philippines.
IBP. (2012d). Open Budget Survey 2012: Cambodia.
IBP. (2012e). Open Budget Survey 2012: Indonesia.
IBP. (2012f). Open Budget Survey 2012: The Philippines.
IBP. (2015d). Open Budget Survey 2015: Cambodia.
IBP. (2015e). Open Budget Survey 2015: Indonesia.
IBP. (2015f). Open Budget Survey 2015: The Philippines.
IBP. (2017d). Open Budget Survey 2017. Phnom Penh: NGO Forum on Cambodia.
IBP. (2017e). Open Budget Survey 2017: Indonesia.
IBP. (2017f). Open Budget Survey 2017: The Philippines.
NA. (2014a). Internal Regulation of the National Assembly. Phnom Penh: NA.
NA. (2014b). Decision on Roles and Responsibilities of Commission on Economy, Finance, Banking and Audit of the National Assembly. Phnom Penh: NA.
Kang, C., & Liv, D. (2011). Multi-Level Citizen & Councilor Survey: An Index to Measure Sub-National Democratic Accountability in Cambodia: Technical Report. Phnom Penh: Cambodia Institute of Development Study.
Kim, S., & Öjendal, J. (2007). *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* Working Paper 35. Cambodia Development Resource Institute
Kristiansen, S., Dwiyanto, A., Pramusinto, A., & Putranto, E. A. (2009). Public sector reforms and financial transparency: Experiences from Indonesian districts. *Contemporary Southeast Asia*, 64-87.
Magno, F. A. (2015). *Public participation and fiscal transparency in the Philippines*. The Global Initiative for Fiscal Transparency.
Marchessault, L. (n.d.) Public participation and the budget cycle: Lessons from country examples. The Global Initiative for Fiscal Transparency.
Office of the President. (n.d.) *State Audit Code of the Philippines*. Manila: Office of the President.
Petrie, M. (2018, December 19, 2018). The 2017 Open Budget Survey: What the results for public participation mean. Retrieved from http://www.fiscaltransparency.net/use/the-2017-open-budget-survey-what-the-results-for-public-participation-mean/
Plummer, J., & Tritt, G. (2012). Voice, Choice, and Decision: A Study of Local Governance Processes in Cambodia. Phnom Penh: The World Bank and Asia Foundation.
Reuy, R. (2013, February 14, 2013). Ecotourism in Cambodia up 9.7 per cent, *The Phnom Penh Post*. Retrieved from https://www.phnompenhpost.com/business/ecotourism-cambodia-97-cent
RGC. (2015). *Report of the Evaluation on the Public Financial Management System of Cambodia: Based on Public Expenditure and Financial Accountability Methodology*. Phnom Penh: RGC
RGC. (2018). Rectangular Strategy: Phase IV. Phnom Penh: RGC.
Rith, S. O., Williams, P. W., & Neth, B. (2009). Emerging Trends, Challenges and Innovations Community Based Natural Resource Management (CBNRM) in Cambodia. In C. LI (Ed.), *Community-Based Ecotourism and Rural Livelihood Diversifi cation: Reframing the Approach* (2 ed.). Phnom Penh: CBNRM Learning Institute.
Sopanah, A. (2012). Ceremonial budgeting: public participation in development planning at an Indonesian local government authority. *Journal of Applied Management Accounting Research*, *10*(2), 73.
Senate. (2014). Internal Regulation of the Senate. Phnom Penh: Senate.
Thon, V., Ou, S., Eng, N., & Ly, T. (2009). *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces. Working Paper Series No. 42*. Phnom Penh, Cambodia: CDRI

Ven, S. (2016). Residents' Participation, Perceived Impacts, and Support for Community-based Ecotourism in Cambodia: A Latent Profile Analysis. *Asia Pacific Journal of Tourism Research, 21*(8), 836-861.

Vong, M., & Hok, K. (2018). Facebooking: Youth's Everyday Politics in Cambodia. In S. McCarthy (Ed.), *'Contemporary Research Challenges in South East Asia," Edited Workshop Papers*. Queensland: The Griffith Asia Institute.

World Bank (2018) Social Accountability and Service Delivery in Rural Cambodia: A Report on the Results of the Social Accountability Framework Inpact [sic] Evaluation Baseline Survey.

"Action Plan to Improve OBS Score".

# ឧបសម្ព័ន្ធ

## ១.ច្បាប់និងគោលនយោបាយដែលត្រូវបានត្រួតពិនិត្យ

**ថ្នាក់ជាតិ:**

- រដ្ឋធម្មនុញ្ញ (១៩៩៣ និងធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩)
- ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (១៩៩៨ និងធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៨)
- ច្បាប់សវនកម្ម (២០០០)
- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ២០១២)
- ច្បាប់ប្រឆាំងអំពើពុករលួយ (២០១០)
- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ២០១២)
- ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (សេចក្តីព្រាង)
- បទបញ្ជាផ្ទៃក្នុងរដ្ឋសភា (២០១៤)
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា(២០១៤)
- សេចក្តីសម្រេចអំពីតួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្មរបស់រដ្ឋសភា(២០១៤)
- ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម (២០១៦)

*អនុក្រឹត្យ គោលនយោបាយ និងឯកសារពាក់ព័ន្ធនានា:*

- យុទ្ធសាស្ត្រចតុកោណ (ដំណាក់កាលទី១: ឆ្នាំ២០០៤ ដំណាក់កាលទី២: ឆ្នាំ២០០៨ ដំណាក់កាលទី៣: ឆ្នាំ ២០១៣ ដំណាក់កាលទី៤: ឆ្នាំ ២០១៨)
- កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) (២០០៤ និង ២០០៨)
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំនៃ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២០០៧)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP: 2006-2010 និងការធ្វើបច្ចុប្បន្នភាព: ២០០៩-២០១៣ និង ២០១៤-២០១៨)
- យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា (២០១៧) (២០១៧-២០២៥) (សេចក្តីព្រាង)
- ស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា (២០១១)

**ថ្នាក់ក្រោមជាតិ:**

- ច្បាប់ស្តីពីរបបគ្រប់គ្រងទ្រព្យសម្បត្តិនិងថវិកាខេត្តនិងក្រុង (១៩៩៨)
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ (២០០១)

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ (២០០៨)
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ (២០១១)

*អនុក្រឹត្យ គោលនយោបាយ និងឯកសារពាក់ព័ន្ធនានា:*

- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) (២០១០)
- ផែនការអនុវត្តបីឆ្នាំរំកិល (IP3) (ដំណាក់កាលទី I, II, និង III នៃ NP-SNDD) ឯកសារចុងក្រោយបង្អស់: IP3 III: ២០១៨- ២០២០
- អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ / សង្កាត់ (២០០២)
- អនុក្រឹត្យស្តីពីមូលនិធិឃុំ / សង្កាត់ (២០០២)
- ក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ (២០០៥)
- អនុក្រឹត្យស្តីពីតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាល (២០០៩)
- អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុងនិងស្រុក (២០១២)
- ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌ (២០១២)
- សេចក្តីប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងការអនុវត្តថវិកាឃុំសង្កាត់ (២០០២)
- សេចក្តីណែនាំស្តីពីការរៀបចំ ការអនុម័ត និងការអនុវត្តមូលនិធិស្រុក / ក្រុង (២០១៣)
- ប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ឃុំ (២០១៦)
- ប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ស្រុក (២០១៦)
- ប្រកាសរួមស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំនិងបង្កើតកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ខេត្ត (២០១៦)

## ២. និន្នាការទូទៅនៃការចូលរួមរបស់សាធារណជនក្នុងការស្ទង់មតិចំហថវិកា ឬ Open Budget Survey

លទ្ធផលនៅក្នុងការស្ទង់មតិចំហថវិកានេះ គឺមិនអាចប្រៀបធៀបគ្នាពីមួយឆ្នាំទៅមួយឆ្នាំបានទេ។ ហេតុដូច្នេះ យើងមិនអាចបង្ហាញពីលទ្ធផលស្ទង់មតិ (ជាចំណុចៗ) នៃប្រទេសទាំងបី ដើម្បីឱ្យឃើញនូវនិន្នាការរួមទូទៅនៃ បញ្ហានេះទេ។ ជារួម តាំងពីឆ្នាំ២០០៦មក ចំនុចស្នូលនៃការស្ទង់មតិមិនមានការផ្លាស់ប្តូរនោះទេ តែសំណួរក្នុង ការស្ទង់មតិមានការផ្លាស់ប្តូរច្រើន។ តាំងពីឆ្នាំ២០០៦មក កម្រងសំណួរស្ទង់មតិត្រូវបានកែប្រែ៣ ដងហើយ។ នៅក្នុងការស្ទង់មតិពីរលើកដំបូង (គឺឆ្នាំ២០០៦ និង ឆ្នាំ២០០៨) ការចូលរួមជាសាធារណៈ មិនត្រូវបានស្ទង់មតិ ជាផ្នែកមួយដោយឡែកទេ។ រហូតដល់ឆ្នាំ២០១០ ទើបផ្នែកមួយដែលមានចំណងជើងថា "ការចូលរួមជាសាធារណៈ" ត្រូវបានបង្កើតឡើង ហើយវាត្រូវបានកែលម្អជាបន្តបន្ទាប់ គឺនៅឆ្នាំ២០១២ម្តង និងនៅឆ្នាំ២០១៧ម្តងទៀត។

ទោះបីសំនួរមានការផ្លាស់ប្តូរក៏ដោយ ក៏ការផ្តោតជាស្នូលនៅក្នុងការស្ទង់មតិ មិនបានផ្លាស់ប្តូរច្រើនទេ។ ផ្នែក "ការចូលរួមជាសាធារណៈ" នេះ ផ្តោតជាសំខាន់ទៅលើឱកាសសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការសំរេច ចិត្តលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការចេញផ្សាយព័ត៌មានសាធារណៈ និងលទ្ធភាព ទទួលបានព័ត៌មាន ជាពិសេសព័ត៌មានហិរញ្ញវត្ថុ ពីផ្នែកទាំងបីនៃរដ្ឋ គឺអង្គនីតិប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និង ស្ថាប័នសវនកម្មកំពូល។ អ្វីដែលបានផ្លាស់ប្តូរច្រើននោះ គឺទម្ងន់នៃការយកចិត្តទុកដាក់នៃអនុផ្នែកនីមួយៗ ជាពិសេសការផ្តោតលើការ ទទួលបានព័ត៌មាន ត្រូវបានកាត់បន្ថយក្នុងការស្ទង់មតិ៣ លើកចុងក្រោយ។

មានចំណុចមួយចំនួន អំពីការស្ទង់មតិ OBS ដែលគួរឱ្យកត់សម្គាល់។ ទី១ គឺការស្ទង់មតិ ឆ្នាំ ២០០៦ ឆ្នាំ ២០០៨ និងឆ្នាំ២០១០ ផ្តោតសំខាន់ទៅលើការចូលរួមរបស់សាធារណជន ក្នុងសកម្មភាពគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ របស់អង្គនីតិបញ្ញត្តិ (ដែលមានសំណួរចំនួន ១០ ធៀបនឹងសំណួរចំនួន ៤ ដែល ផ្តោតលើអង្គនីតិប្បញ្ញត្តិ និងមួយឬពីរទៅលើស្ថាប័នសវនកម្មកំពូល)។ ទី២ គឺមានការកែសម្រួលកម្រង សំណួរស្ទង់មតិឡើងវិញយ៉ាងច្រើននៅឆ្នាំ២០១២។ នៅឆ្នាំ២០១២នេះ មានការកែសម្រួលឡើងវិញទាំង ស្រុងនូវសំណួរស្តីពីអង្គនីតិប្រតិបត្តិ និងការកែសម្រួលគួរសមទៅលើសំណួរអំពីស្ថាប័នសវនកម្មកំពូល។ ហេតុដូច្នេះ មានតុល្យភាពជាងមុន នូវចំនួនសំណួររវាងស្ថាប័នទាំងបីនេះ។ ចាប់ពីឆ្នាំ២០១២មក មានការ ប្រើប្រាស់នូវ "សង្វាក់សំណួរ" (សរសេរជាអក្សរទ្រេតនៅក្នុងតារាងខាងក្រោម) ពោលគឺសំណួរដែលមាន ការពាក់ព័ន្ធគ្នា និងដែលចម្លើយសម្រាប់សំនួរដំបូងៗអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើពិន្ទុនៃសំណួរពាក់ព័ន្ធ ជាបន្តបន្ទាប់ទៀត។ ទី៣ គឺមានការផ្លាស់ប្តូរគួរឱ្យកត់សំគាល់ចំនួនពីរនៅឆ្នាំ២០១៥ គឺថាមានការកាត់ បន្ថយនិងលុបសំណួរស្តីពីអង្គនីតិប្រតិបត្តិ និងការបន្ថែមសំនួរមួយស្តីពីស្ថាប័នសវនកម្មកំពូល។ ទី៤ គឺមានការ កែសម្រួលយ៉ាងទូលំទូលាយ នៅឆ្នាំ២០១៧ ហើយការកែសម្រួលនោះអនុលោមទៅតាមគោលការណ៍នៃការ ចូលរួមជាសាធារណៈ ដែលបានបង្កើតឡើងដោយគំនិតផ្តួច

ផ្ដើមសកលសម្រាប់តម្លាភាព សារពើពន្ធ ឬ GIFT ។ ដូចជាការស្ទង់មតិឆ្នាំ២០០៦ដែរ វាបានផ្ដោតជាសំខាន់ទៅលើអង្គនីតិប្រតិបត្តិ (សំណួរចំនួន១១ ក្នុងចំណោមសំនួរ១៨)។ ការកែសម្រួលនេះ គឺធ្វើឱ្យមានការសរសេរឡើងវិញនូវសំណួរ ជាច្រើនស្ទើរតែទាំង ស្រុង ដោយក្នុងនោះមានការប្រើសំណួរខ្សែសង្វាក់យ៉ាងទូលំទូលាយជាងមុន ការផ្ដោត ទៅលើដំណើរការ ទាំងមូលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការដាក់បញ្ចូលការវាយតម្លៃលើការពិគ្រោះ យោបល់ជាមួយ ជនដែលងាយរងគ្រោះ និងមិនមានតំណាងគ្រប់គ្រាន់។ ទិដ្ឋភាពទូទៅនៃផ្នែកការចូលរួម ជាសាធារណៈនេះ គឺមានដូចខាងក្រោម៖

***<u>ការស្ទង់មតិនៅឆ្នាំ២០០៦ ឆ្នាំ២០០៨ និងឆ្នាំ២០១០</u>***

តារាងខាងក្រោមនេះ ស្រង់សំនួរទាក់ទងនឹងការចូលរួមជាសាធារណៈ នៅក្នុងការស្ទង់មតិ OBS ។

| | |
|---|---|
| ***អង្គនីតិប្រតិបត្តិ*** | |
| ១ | ចេញផ្សាយឯកសារស្ដីពីថវិកាប្រជាពលរដ្ឋ |
| ២ | ចេញផ្សាយសន្ទានុក្រមស្ដីពីនិយមន័យពាក្យគន្លឹះសម្រាប់ជនសាមញ្ញ |
| ៣ | ដាក់បញ្ចូលសិទ្ធិទទួលបានព័ត៌មានរដ្ឋាភិបាលទៅក្នុងច្បាប់ |
| ៤ | ទទួលបានព័ត៌មានហិរញ្ញវត្ថុស្ដីពីចំណាយរបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្ដាលនីមួយៗ |
| ៥ | ទទួលបានព័ត៌មានមិនមែនហិរញ្ញវត្ថុស្ដីពីចំណាយរបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្ដាលនីមួយៗ |
| ៦ | បញ្ចេញកាលវិភាគស្ដីពីការរៀបចំសំណើរថវិកា |
| ៧ | ពិភាក្សាជាមួយសាធារណជនទៅលើការកំណត់អទិភាពថវិកា |
| ៨ | (ពេលវេលានៃការ) ចេញផ្សាយសេចក្ដីព្រាងរបាយការណ៍ថវិកា |
| ៩ | ចេញផ្សាយរបាយការណ៍ក្នុងឆ្នាំស្ដីពីការចំណាយជាក់ស្ដែង (ភាពញឹកញាប់) |
| ១០ | ចេញផ្សាយរបាយការណ៍ស្ដីពីជំហានដែលបានអនុវត្ត ដើម្បីដោះស្រាយរបកគំហើញឬអនុសាសន៍សវនកម្ម |
| ***អង្គនីតិបញ្ញត្តិ (គណៈកម្មាធិការនីតិបញ្ញត្តិ)*** | |
| ១១ | រៀបចំសវនាការជាសាធារណៈ ស្ដីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ ជាមួយនឹងសក្ខីកម្មពី អង្គនីតិប្រតិបត្តិនិងសាធារណជន |
| ១២ | រៀបចំសវនាការជាសាធារណៈ ស្ដីពីថវិការបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្ដាលនីមួយៗ ដោយមាន សក្ខីកម្មពីអង្គនីតិប្រតិបត្តិ |

| | |
|---|---|
| ១៣ | រៀបចំសវនាការជាសាធារណៈ ស្តីពីថវិការបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាលនីមួយៗ ដោយមាន សក្ខីកម្មពីសាធារណជន |
| ១៤ | ចេញផ្សាយសេចក្តីប្រកាសព័ត៌មានស្តីពីសវនាការជាសាធារណៈ |
| ***ស្ថាប័នសវនកម្មកំពូល*** | |
| ១៥ | រក្សាយន្តការទំនាក់ទំនងផ្លូវការ ដើម្បីឱ្យសាធារណជនចូលរួមកម្មវិធីសវនកម្ម* |
| ១៦ | ចេញផ្សាយរបាយការណ៍តាមដានជំហានដែលអនុវត្តដោយអង្គនីតិប្រតិបត្តិ ដើម្បីដោះស្រាយអនុសាសន៍សវនកម្ម (ដោយស្ថាប័នសវនកម្មកំពូលឬអង្គនីតិប្បញ្ញត្តិ) |

* មិនមានសំណួរនេះទេ នៅក្នុងការស្ទង់មតិឆ្នាំ២០០៦។

***<u>ការស្ទង់មតិ នៅឆ្នាំ២០១២</u>***

| | |
|---|---|
| ***អង្គនីតិប្រតិបត្តិ*** | |
| ១ | *ផ្តល់ព័ត៌មានលម្អិតក្នុងឯកសារ 'ថវិកាពលរដ្ឋ' [សំនួរកែសម្រួល]* |
| ២ | ផ្សព្វផ្សាយឯកសារ "ថវិកាពលរដ្ឋ" ទៅដល់សាធារណជន (របៀប) [សំនួរថ្មី] |
| ៣ | ពិចារណាពីអាទិភាពរបស់សាធារណជន អំពីព័ត៌មានថវិកាក្នុងការធ្វើសេចក្តីព្រាងឯកសារ "ថវិកា ពលរដ្ឋ" [សំនួរថ្មី] |
| ៤ | បោះពុម្ពឯកសារ 'ថវិកាពលរដ្ឋ' នៅទូទាំងដំណើរការថវិកា (ភាពញឹកញាប់) [សំនួរថ្មី] |
| ៥ | *តម្រូវឱ្យមានជាផ្លូវការនូវការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា [សំនួរថ្មី]* |
| ៦ | បង្ហាញនូវគោលបំណងច្បាស់លាស់និងទាន់ពេលវេលា នៃការចូលរួមជាសាធារណៈ ក្នុងអំឡុងពេលរៀបចំនិងអនុវត្តថវិកា [សំនួរថ្មី]** |
| ៧ | បង្កើតយន្តការជាក់ស្តែងនិងអាចរកបាន ដើម្បីកំណត់ទស្សនរបស់សាធារណជន អំពីអាទិភាពថវិកា [សំនួរថ្មី] |
| ៨ | បង្កើតយន្តការជាក់ស្តែងនិងអាចរកបាន ដើម្បីកំណត់ទស្សនរបស់សាធារណជន អំពីការអនុវត្តថវិកា [សំនួរថ្មី] |
| ៩ | ផ្តល់មតិត្រលប់ជាផ្លូវការនិងលំអិត ចំពោះការប្រើប្រាស់ធាតុចូលក្នុងការអភិវឌ្ឍនិងអនុវត្តផែនការថវិកា [សំនួរថ្មី] |
| ***អង្គនីតិបញ្ញត្តិ (គណៈកម្មាធិការនីតិបញ្ញត្តិ)*** | |

| | |
|---|---|
| ១០ | រៀបចំសវនាការជាសាធារណៈ ស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ ជាមួយនិងសក្ខីកម្មពីអង្គ នីតិប្រតិបត្តិនិងសាធារណជន |
| ១១ | រៀបចំសវនាការជាសាធារណៈ ស្តីពីថវិការបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាលនីមួយៗ ដោយមាន សក្ខីកម្មពីអង្គនីតិប្រតិបត្តិ |
| ១២ | រៀបចំសវនាការជាសាធារណៈ ស្តីពីថវិការបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាលនីមួយៗ ដោយមាន សក្ខីកម្មពីសាធារណជន |
| ១៣ | ចេញផ្សាយសេចក្តីប្រកាសព័ត៌មានស្តីពីសវនាការជាសាធារណៈ |
| *ស្ថាប័នសវនកម្មកំពូល* | |
| ១៤ | រក្សាយន្តការទំនាក់ទំនងជាផ្លូវការ ដើម្បីឱ្យសាធារណជនចូលរួមក្នុងដំណើរការសវនកម្ម [ប្តូរពីកម្មវិធី មកជាដំណើរការ] |
| ១៥ | រក្សាការប្រាស្រ័យទាក់ទងជាសាធារណៈ អំពីរបាយការណ៍សវនកម្ម លើសពីការធ្វើឱ្យវាមាន ជាសាធារណៈ [សំណួរថ្មី] |
| ១៦ | ផ្តល់មតិត្រលប់ជាផ្លូវការនិងលម្អិត អំពីការប្រើប្រាស់ធាតុចូលដែលទទួលបាន សម្រាប់កម្មវិធីឬ របាយការណ៍សវនកម្ម [សំណួរថ្មី] |

** សំនួរនេះ ត្រូវបានចែកចេញជាពីរសំនួរ នៅក្នុងការស្ទង់មតិ ឆ្នាំ២០១៥។

***<u>ការស្ទង់មតិ នៅឆ្នាំ២០១៥</u>***

| | |
|---|---|
| ***អង្គនីតិប្រតិបត្តិ*** | |
| ១ | ចេញផ្សាយសន្ទានុក្រមស្តីពីនិយមន័យពាក្យគន្លឹះសម្រាប់ជនសាមញ្ញ [សំណួរ ឆ្នាំ២០១០] |
| ២ | *តម្រូវជាផ្លូវការឱ្យមានការចូលរួមជាសាធារណៈ ក្នុងការរៀបចំនិងអនុវត្តថវិកា [សំណួរកែសម្រួល]* |
| ៣ | បង្ហាញពីគោលបំណងនៃការចូលរួម និងផ្តល់ព័ត៌មានគ្រប់គ្រាន់ជាមុន ក្នុងការរៀបចំថវិកា [សំនួរកែសម្រួល] |
| ៤ | បរិយាយគោលបំណងនៃការចូលរួម និងផ្តល់ព័ត៌មានគ្រប់គ្រាន់ជាមុន ក្នុងអំឡុងពេលប្រតិបត្តិថវិកា [សំនួរកែសម្រួល] |
| ៥ | បង្កើតយន្តការជាក់ស្តែងនិងអាចរកបាន ដើម្បីកំណត់ទស្សនរបស់សាធារណជន អំពីអាទិភាពថវិកា |
| ៦ | បង្កើតយន្តការជាក់ស្តែង និងអាចរកបាន ដើម្បីកំណត់ទស្សនរបស់សាធារណជន អំពីការអនុវត្តថវិកា |

| | |
|---|---|
| ៧ | ផ្តល់មតិត្រលប់ជាផ្លូវការនិងលម្អិត ចំពោះការប្រើប្រាស់ធាតុចូលក្នុងការរៀបចំនិងអនុវត្តផែនការ ថវិកា |
| *នីតិបញ្ញត្តិ (គណៈកម្មាធិការនីតិបញ្ញត្តិ)* | |
| ៨ | រៀបចំសវនាការជាសាធារណៈ ស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ ជាមួយនិងសក្ខីកម្មពី អង្គនីតិប្រតិបត្តិនិងសាធារណជន |
| ៩ | រៀបចំសវនាការជាសាធារណៈ ស្តីពីថវិការបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាលនីមួយៗ ដោយមាន សក្ខីកម្មពីអង្គនីតិប្រតិបត្តិ |
| ១០ | រៀបចំសវនាការជាសាធារណៈ ស្តីពីថវិការបស់ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាលនីមួយៗ ដោយមាន សក្ខីកម្មពីសាធារណជន |
| ១១ | ចេញផ្សាយសេចក្តីប្រកាសព័ត៌មានស្តីពីសវនាការជាសាធារណៈ |
| *ស្ថាប័នសវនកម្មកំពូល* | |
| ១២ | រក្សាយន្តការទំនាក់ទំនងជាផ្លូវការ ដើម្បីឱ្យសាធារណជនចូលរួមកម្មវិធីសវនកម្ម [ប្តូរពីដំណើរការទៅ ជាកម្មវិធីវិញ] |
| ១៣ | រក្សាយន្តការទំនាក់ទំនងផ្លូវការ ដែលសាធារណជនអាចចូលរួមស៊ើបអង្កេតសវនកម្ម [សំនួរថ្មី] |
| ១៤ | រក្សាការប្រាស្រ័យទាក់ទងជាសាធារណៈ អំពីរបាយការណ៍សវនកម្ម លើសពីការធ្វើឱ្យវាមាន ជាសាធារណៈ |
| ១៥ | ផ្តល់មតិត្រលប់ជាផ្លូវការនិងលម្អិត អំពីការប្រើប្រាស់ធាតុចូលដែលទទួលបាន សម្រាប់កម្មវិធីឬ របាយការណ៍សវនកម្ម |

<u>*ការស្ទង់មតិ នៅឆ្នាំ២០១៧*</u>

| | |
|---|---|
| *អង្គនីតិប្រតិបត្តិ* | |
| 1 | *ប្រើយន្តការចូលរួម សម្រាប់ឱ្យសាធារណជនផ្តល់ធាតុចូលទៅក្នុងការរៀបចំថវិកាប្រចាំឆ្នាំ [សំនួរថ្មី]* |
| 2 | ចាត់វិធានការជាក់ស្តែង ដើម្បីឱ្យជនដែលងាយរងគ្រោះនិងតំណាងមិនគ្រប់គ្រាន់ បានចូលរួមរៀបចំ ថវិកា [សំនួរថ្មី] |
| 3 | [ចំនួន] ប្រធានបទ ដែលគ្របដណ្តប់ក្នុងពេលពិភាក្សារៀបចំថវិកា [សំនួរថ្មី] |
| 4 | ផ្តល់មតិយោបល់ត្រលប់លើការប្រើប្រាស់ធាតុចូលរបស់ពលរដ្ឋក្នុងការរៀបចំថវិកា [សំនួរថ្មី] |

| | |
|---|---|
| 5 | យន្តការចូលរួមត្រូវបានបញ្ចូលទៅក្នុងកាលវិភាគសម្រាប់ការរៀបចំសំណើរថវិកា [សំនួរថ្មី] |
| 6 | *ប្រើប្រាស់យន្តការចូលរួម សម្រាប់សាធារណជនផ្តល់ធាតុចូលក្នុងការតាមដានត្រួតពិនិត្យ ការអនុវត្ត ថវិកា [សំនួរថ្មី]* |
| 7 | ចាត់វិធានការជាក់ស្តែង ដើម្បីទទួលបានធាតុចូលពីប្រជាពលរដ្ឋដែលងាយរងគ្រោះនិងមិនសូវមានតំណាង ក្នុងការអនុវត្តថវិកា [សំនួរថ្មី] |
| 8 | [ចំនួន] ប្រធានបទដែលគ្របដណ្តប់ ក្នុងពេលពិភាក្សាពីការអនុវត្តថវិកា [សំនួរថ្មី] |
| 9 | ផ្តល់ព័ត៌មានជាមុនអំពីដំណើរការចូលរួម [សំនួរថ្មី] |
| 10 | ផ្តល់ព័ត៌មានអំពីការប្រើប្រាស់ធាតុចូលរបស់ប្រជាពលរដ្ឋ ក្នុងការតាមដានការអនុវត្តថវិកា [សំនួរថ្មី] |
| 11 | ក្រសួងនានាប្រើយន្តការចូលរួម សម្រាប់សាធារណជនផ្តល់យោបល់ក្នុងអំឡុងពេលរៀបចំឬអនុវត្ត ថវិកា [សំណួរថ្មី] |
| ***អង្គនីតិបញ្ញត្តិ (គណៈកម្មាធិការនីតិបញ្ញត្តិ)*** | |
| 12 | រៀបចំសវនាការ និង/ឬ ប្រើប្រាស់យន្តការចូលរួមដទៃទៀត សម្រាប់សាធារណៈផ្តល់ធាតុចូលក្នុង អំឡុងពេលពិគ្រោះយោបល់សាធារណៈស្តីពីការរៀបចំថវិកា [សំនួរថ្មី] |
| 13 | [ចំនួន] ប្រធានបទ ដែលមានក្នុងការពិភាក្សា [សំនួរថ្មី] |
| 14 | ផ្តល់មតិយោបល់ត្រលប់ លើការប្រើប្រាស់ធាតុចូលរបស់ប្រជាពលរដ្ឋ ក្នុងអំឡុងពេលពិភាក្សា [សំនួរថ្មី] |
| 15 | រៀបចំសវនាការ និង/ឬ ប្រើប្រាស់យន្តការចូលរួមដទៃទៀត សម្រាប់សាធារណជនផ្តល់ធាតុចូលក្នុង អំឡុងពេលការពិភាក្សាលើរបាយការណ៍សវនកម្ម [សំនួរថ្មី] |
| ***ស្ថាប័នសវនកម្មកំពូល*** | |
| 16 | រក្សាយន្តការជាផ្លូវការ សម្រាប់សាធារណជនផ្តល់យោបល់អំពីបញ្ហា/ប្រធានបទ សម្រាប់កម្មវិធី សវនកម្ម [សំនួរកែសម្រួលបន្តិចបន្តួច] |
| 17 | ផ្តល់មតិយោបល់ត្រលប់ជាផ្លូវការនិងលម្អិត អំពីការប្រើប្រាស់ធាតុចូលដែលទទួលបាន សម្រាប់កម្មវិធី សវនកម្ម [លុបឃ្លារបាយការណ៍សវនកម្ម] |
| 18 | រក្សាយន្តការទំនាក់ទំនងផ្លូវការ ដែលសាធារណជនអាចចូលរួមស៊ើបអង្កេតសវនកម្ម |

## ៣. តារាងអ្នកដែលត្រូវបានសម្ភាសសំខាន់ៗ និងស្ថាប័នរដ្ឋដែលបានពិគ្រោះយោបល់ជាមួយ

| លេខរៀង | | កាលបរិច្ឆេទនៃបទសម្ភាសន៍ | កូដនៃបទសម្ភាសន៍ | ចំនួន |
|---|---|---|---|---|
| អ្នកដែលត្រូវបានសម្ភាសបែងចែកជាក្រុម | | | | |
| ១ | អ្នកជំនាញការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ / អ្នកពិគ្រោះការពាក់ព័ន្ធ | ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩ | បទសម្ភាសន៍ទី១, PFM, ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី២, PFM, ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី៣, PFM, ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩ | ៣ |
| ២ | បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី ៧ ខែមករា ឆ្នាំ២០១៩ | បទសម្ភាសន៍ទី៤, NGO, ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី៥, NGO, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី៦, NGO, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី៧, NGO, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី៨, NGO, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ | ៥ |
| ៣ | បុគ្គលិកដៃគូអភិវឌ្ឍន៍ | ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br>ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ | បទសម្ភាសន៍ទី៩, DP, ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី១០, DP, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី១១, DP, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br>បទសម្ភាសន៍ទី១២, DP, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ | ៤ |
| ៤ | មន្ត្រីរាជរដ្ឋាភិបាល | ថ្ងៃទី១០ ខែមករា | បទសម្ភាសន៍ទី១៣, GO, ថ្ងៃទី១០ ខែមករា | ២ |

| | | | | |
|---|---|---|---|---|
| | | ឆ្នាំ២០១៩<br>ថ្ងៃទី១១ ខែមករា<br>ឆ្នាំ២០១៩ | ឆ្នាំ ២០១៩<br>បទសម្ភាសន៍ទី១៤, GO, ថ្ងៃទី១១ ខែមករា<br>ឆ្នាំ២០១៩ | |
| ៥ | ប្រជាពលរដ្ឋមូលដ្ឋាន | ថ្ងៃទី១០ ខែមករា<br>ឆ្នាំ២០១៩ | បទសម្ភាសន៍ទី១៥, LC, ថ្ងៃទី១០ ខែមករា<br>ឆ្នាំ២០១៩ | ៥ |
| ៦ | មន្ត្រីរាជរដ្ឋាភិបាលនៅមូលដ្ឋាន | ថ្ងៃទី១១ ខែមករា<br>ឆ្នាំ២០១៩ | បទសម្ភាសន៍ទី១៦, LGO, ថ្ងៃទី១១ ខែមករា<br>ឆ្នាំ២០១៩ | ១ |
| សរុប | | | | **២០** |

| **ស្ថាប័នរដ្ឋដែលបានពិគ្រោះយោបល់ជាមួយ** | | | | |
|---|---|---|---|---|
| ១ | អាជ្ញាធរសវនកម្មជាតិ | ថ្ងៃទី១៥ ខែមករា<br>ឆ្នាំ២០១៩ | កិច្ចប្រជុំពិគ្រោះយោបល់ទីមួយជាមួយតំណាងអាជ្ញាធរសវនកម្មជាតិ | ៧ |
| ២ | គណៈកម្មាធិការដឹកនាំកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ថ្ងៃទី២៨ ខែមករា<br>ឆ្នាំ២០១៩ | កិច្ចប្រជុំពិគ្រោះយោបល់ទីពីរជាមួយតំណាងគណៈកម្មាធិការដឹកនាំកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៨ |
| ៣ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | |

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*The NGO Forum on Cambodia*

អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន
រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ៖ ២២៩៥, រាជធានីភ្នំពេញ-៣
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh